# ពីការផ្ដោតលើ ប្រតិបត្តិការទៅជាការគិតគូរ លើផលប្រយោជន៍របស់កុមារ



តើមជ្ឈមណ្ឌលច្រកចេញចូល
តែមួយអាចបំពេញចន្លោះ
ខ្វះខាតក្នុងការឆ្លើយតបចំពោះ
កុមាររងគ្រោះដោយអំពើរំលោភបំពាន
និងកេងប្រវ័ញ្ចផ្លូវភេទនៅ
ប្រទេសកម្ពុជាដែរឬទេ ?


ការសិក្សាដោយៈ
អង្គការសកម្មភាពដើម្បីកុមារ


APLE

**© រក្សាសិទ្ធិដោយអង្គការសកម្មភាពដើម្បីកុមារ (APLE Cambodia) 2020**

ឯកសារស្រាវជ្រាវនេះត្រូវបានរៀបចំ និងសរសេរឡើងដោយលោកស្រី **Avigal Orha** សម្រាប់ អង្គការសកម្មភាពដើម្បីកុមារ ( APLE Cambodia ) និងគាំទ្រថវិកាដោយអង្គការ ECPAT Sweden។

ទស្សនៈនានាដែលបានបង្ហាញនៅក្នុងរបាយការណ៍នេះគឺជាទស្សនៈរបស់អ្នកនិពន្ធ និងមិនឆ្លុះបញ្ចាំងពីទស្សនៈ របស់របស់អង្គការសកម្មភាពដើម្បីកុមារ ( APLE Cambodia ) ឬ អង្គការ ECPAT Sweden នោះទេ។

# មាតិកា


អក្សរកាត់ និងពាក្យសរសេរកាត់ ៥

សេចក្តីថ្លែងអំណរគុណ ៦

សន្ទានុក្រម ៧

មូលសង្ខេប ៩

សេចក្តីផ្តើម ១១

ផលប៉ះពាល់នៃការរំលោភបំពាននិងកេងប្រវ័ញ្ច ផ្លូវភេទលើកុមារ(CSAE) ១១

សិទ្ធិក្នុងការទទួលបានយុត្តិធម៌ ១២

វឌ្ឍនភាព និងកង្វះខាតនៅក្នុងប្រទេសកម្ពុជា ១៤

គោលបំណងនៃការសិក្សា ១៦

វិធីសាស្រ្ត ១៨

ការបដិសេធទទួលខុសត្រូវ និងដែនកំណត់ ២១

របកគំហើញ ២២

ផ្នែកទី១៖ ទិដ្ឋភាពទូទៅនៃនីតិវិធីយុត្តិធម៌ព្រហ្មទណ្ឌសម្រាប់ជនរងគ្រោះដោយអំពើរំលោភបំពាន និងប្រវ័ញ្ចផ្លូវភេទកុមារ ២២

មន្ត្រីអនុវត្តច្បាប់ ២២

ការពិនិត្យកោសលវិច្ឆ័យវេជ្ជសាស្រ្ត ២៩

ជំនួយ និងសេវាគាំទ្រផ្នែកចិត្តសាស្រ្តសង្គម ៣៣

ការទទួលសេវាកម្មផ្លូវច្បាប់ និងយុត្តិធម៌ ៣៦

# មាតិកា


**ផ្នែកទី២៖ ផលប៉ះពាល់នៃការប្រតិបត្តិរបស់ទីភ្នាក់ងារ ដាច់ដោយឡែកពីគ្នា** ៤១

ការកើនឡើងនូវហានិភ័យនៃការធ្វើឱ្យរងគ្រោះឡើងវិញ ដោយសារការរំឭកអំពីរឿងហេតុ ៤៣

ផលប៉ះពាល់លើប្រសិទ្ធភាពនៃការទាក់ទងគ្នា និងការសម្របសម្រួលសេវាកម្ម ៤៣

ផលប៉ះពាល់លើភាពជោគជ័យនៃលទ្ធផល យុត្តិធម៌ព្រហ្មទណ្ឌ ៤៥

**ផ្នែកទី៣៖ មជ្ឈមណ្ឌលច្រកចេញចូលតែមួយ - ការឆ្លើយតប របស់ពហុភាគី** ៤៦

មជ្ឈមណ្ឌលច្រកចេញចូលតែមួយ ៤៦

ឧបសគ្គ និងដែនកំណត់ចំពោះការអនុវត្តគំរូ ៥០

មជ្ឈមណ្ឌលច្រកចេញចូលតែមួយក្នុងបរិបទប្រចាំតំបន់ - ឧទាហរណ៍អាស៊ីអាគ្នេយ៍ ៥២

**ការពិភាក្សា** ៥៨

**សេចក្តីបញ្ចប់ និងអនុសាសន៍** ៦០

**ឧបសម្ព័ន្ធ** ៦៧

# អក្សរកាត់ និងពាក្យសរសេរកាត់

| | | |
|---|---|---|
| AHC | – | មន្ទីរពេទ្យកុមារអង្គរ |
| AHTJPD | – | នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន |
| CCWC | – | គណៈកម្មការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ/សង្កាត់ |
| CSAE | – | ការរំលោភបំពាន និងកេងប្រវ័ញ្ចផ្លូវភេទកុមារ |
| CWCC | – | អង្គការកម្ពុជាដើម្បីជួយស្ត្រីមានវិបត្តិ |
| DoSVY | – | មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា |
| DoWA | – | មន្ទីរកិច្ចការនារី |
| GBV | – | អំពើហិង្សាផ្អែកលើយេនឌ័ |
| GDP | – | ផលិតផលក្នុងស្រុកសរុប |
| HIC | – | ប្រទេសដែលមានប្រាក់ចំណូលខ្ពស់ |
| LMIC | – | ប្រទេសដែលមានប្រាក់ចំណូលមធ្យមកម្រិតទាប |
| MoH | – | ក្រសួងសុខាភិបាល |
| MoI | – | ក្រសួងមហាផ្ទៃ |
| MoEYS | – | ក្រសួងអប់រំ យុវជន និងកីឡា |
| MoJ | – | ក្រសួងយុត្តិធម៌ |
| MoLVT | – | ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ |
| MoSVY | – | ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា |
| MoU | – | អនុស្សរណៈយោគយល់គ្នា |
| MoWA | – | ក្រសួងកិច្ចការនារី |
| NAPVAW | – | ផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រី |
| OSSC | – | មជ្ឈមណ្ឌលច្រកចេញចូលតែមួយ |
| PDoWA | – | មន្ទីរកិច្ចការនារីខេត្ត |
| RGC | – | រាជរដ្ឋាភិបាលកម្ពុជា |
| SEA | – | អាស៊ីអាគ្នេយ៍ |
| SWG-GBV - Sub | – | អនុក្រុមការងារលើអំពើហិង្សាផ្អែកលើយេនឌ័ |
| TWGG-GBV | – | ក្រុមការងារបច្ចេកទេសទាក់ទងនឹងយេនឌ័ - អំពើហិង្សាទាក់ទងនឹងយេនឌ័ |
| UNCRC | – | អនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិកុមារ |
| UNICEF | – | មូលនិធិអង្គការសហប្រជាជាតិដើម្បីកុមារ |
| VAC | – | អំពើហិង្សាលើកុមារ |
| VAW | – | អំពើហិង្សាលើស្ត្រី |
| WCCC | – | គណៈកម្មាធិការពិគ្រោះយោបល់ស្ត្រី និងកុមារ |

# សេចក្តីថ្លែងអំណរគុណ

សូមថ្លែងអំណរគុណយ៉ាងស្មោះស្ម័គ្រចំពោះម្ចាស់ជំនួយ Postcode តាមរយៈអង្គការ ECPAT Sweden ដែលបានផ្តល់ការគាំទ្រផ្នែកហិរញ្ញវត្ថុរួមជាមួយនឹងការរួមចំណែកយ៉ាងធំធេងរបស់ពួកគេ ដែលបានធ្វើឱ្យការស្រាវជ្រាវនេះលេចចេញជារូបរាង។

សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះស្ថាប័នរដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាល និងអ្នកផ្តល់សេវាទាំងអស់ដែលបានចូលរួមចំណែកក្នុងការស្រាវជ្រាវនេះ និងលះបង់ពេលវេលាក្នុងការផ្តល់បទសម្ភាសដើម្បីផ្តល់ជាគំនិតប្រកបដោយវិជ្ជាជីវៈ និងការចូលរួមដ៏មានតម្លៃ និងអ្នកដែលបានបង្ហាញទឹកចិត្តរបស់ខ្លួនចំពោះការកែលម្អនូវការឆ្លើយតបចំពោះកុមារដែលរងការប៉ះពាល់ដោយអំពើរំលោភបំពាន និងកេងប្រវ័ញ្ចផ្លូវភេទ ដែលត្រូវចូលរួមក្នុងនីតិវិធីយុត្តិធម៌ព្រហ្មទណ្ឌនៅកម្ពុជា។

អ្នកទាំងនោះរួមមានតំណាងមកពី៖ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា មន្ទីរ កិច្ចការនារី ក្រសួងសុខាភិបាល គ្រូពេទ្យមកពីមន្ទីរពេទ្យបង្អែករាជធានីភ្នំពេញ និងខេត្តសៀមរាប អគ្គស្នងការដ្ឋាន នគរបាលជាតិ ស្នងការដ្ឋាននគរបាលខេត្តសៀមរាប និងខេត្តកណ្តាល ចៅក្រម ព្រះរាជអាជ្ញា និងតួអង្គយុត្តិធម៌ផ្សេងទៀតនៅក្នុងសាលាដំបូងរាជធានីភ្នំពេញ និងតំណាងពីអង្គការមិនមែនរដ្ឋាភិបាល៖ មូនីធិ A២១, មន្ទីរពេទ្យកុមារអង្គរ អង្គការ ARM អង្គការកម្ពុជាដើម្បីជួយស្ត្រីមានវិបត្តិ ( CWCC ) អង្គការជំហ៊ានដំបូងកម្ពុជា ( FSC ) អង្គការហាការអន្តរជាតិ ( Hagar ) និងអង្គការដែនដីមនុស្សហ្វូឡង់ដ៏ ( TdHNL )។

សូមអរគុណដល់បុគ្គលិកអង្គការសកម្មភាពដើម្បីកុមារ ( APLE Cambodia ) ទាំងអស់ដែលបានលះបង់ ពេលវេលា និងជួយសម្របសម្រួលក្នុងការសម្ភាសន៍ និងការជួបប្រជុំ ព្រមទាំងការកត់ត្រាជាលាយលក្ខណ៍អក្សរ និងការបកប្រែ ព្រមទាំងផ្តល់នូវការរួមចំណែក និងការណែនាំប្រកបដោយជំនាញវិជ្ជាជីវៈ។ ទាំងនេះរួមមាន លោក សំលៀង សីលា លោក ខឹម វ៉ាន់ដូ លោកស្រី ហ៊ឹម សោភ័ណ្ឌ លោក ផៃ សុភ័ក្រ កញ្ញា យ៉េន ស្រីលាភ លោក ញ៉ែម ពិសិដ្ឋ កញ្ញា ទុយ និមល និងលោក កែវ វ៉ាន់ចា ។

ខ្ញុំក៏សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះលោក Alastair Hilton ចំពោះការណែនាំ ការពិនិត្យ ការផ្តល់យោបល់ និងព័ត៌មានដ៏មានសារៈប្រយោជន៍ដើម្បីគាំទ្ររបាយការណ៍ស្រាវជ្រាវនេះ។

ហើយជាពិសេស ខ្ញុំសូមសម្តែងការដឹងគុណ និងអរគុណដល់កុមាររងគ្រោះ និងក្រុមគ្រួសាររបស់ពួកគេដែលបានអនុញ្ញាតឱ្យអង្គការសកម្មភាពដើម្បីកុមារ ( APLE Cambodia ) ជួយពួកគេក្នុងការស្តារនីតិសម្បទា និងមានភាពក្លាហានក្នុងការចែករំលែកបទពិសោធន៍ក្នុងនីតិវិធីយុត្តិធម៌ព្រហ្មទណ្ឌរបស់ពួកគេ។

# សន្ទានុក្រម

**កុមារ៖** នៅក្នុងរបាយការណ៍នេះ កុមារត្រូវបានសំដៅដល់បុគ្គលគ្រប់រូបដែលមានអាយុក្រោម១៨ ឆ្នាំ។

**ការផ្ដោតលើកុមារ៖** មានន័យថាផ្ដល់អាទិភាពដល់អ្វីដែលជាផលប្រយោជន៍ និងសេចក្ដីត្រូវការរបស់កុមារលើចំណុចផ្សេងៗទៀត។

**នីតិវិធីកុមារមេត្រី៖** ដូចកំណត់ក្នុងច្បាប់ស្ដីពីយុត្តិធម៌អនីតិជន[1] សំដៅលើ "រាល់ដំណើរការ និងនីតិវិធីដែលលើកទឹកចិត្តឱ្យមានការចូលរួមពេញលេញពីអនីតិជន តាមយៈការប្រើប្រាស់ភាសា អាកប្បកិរិយាសមស្របទៅតាមការយល់ដឹងរបស់អនីតិជន និងក្នុងបរិយាកាសដែលមានសុវត្ថិភាព សន្តិសុខ ការគោរពសិទ្ធិ និងការបំពេញតម្រូវការជាមូលដ្ឋាន"។

**យុត្តិធម៌កុមារមេត្រី៖** អនុលោមតាមមាត្រាII(គ) នៃសេចក្ដីណែនាំរបស់ក្រុមប្រឹក្សាអឺរ៉ុបស្ដីពីយុត្តិធម៌កុមារមេត្រី "យុត្តិធម៌កុមារមេត្រី" សំដៅទៅលើប្រព័ន្ធយុត្តិធម៌ដែលធានានូវការគោរព និងការអនុវត្តសិទ្ធិកុមារទាំងអស់ប្រកបដោយប្រសិទ្ធភាពខ្ពស់បំផុតតាមដែលអាចធ្វើទៅបាន ដែលពិចារណាយ៉ាងត្រឹមត្រូវលើកម្រិតនៃភាពពេញវ័យ និងការយល់ដឹងរបស់កុមារ និងស្ថានភាពនៃករណីនោះ។ ជាពិសេសវាសំដៅដល់យុត្តិធម៌ដែលអាចទទួលបាន សមស្របតាមអាយុ មានល្បឿនលឿន មានលក្ខណៈយកចិត្តទុកដាក់ដែលសម្របទៅតាមនិងផ្ដោតលើតម្រូវការ និងការគោរពសិទ្ធិរបស់កុមារ ដែលរួមបញ្ចូលទាំងសិទ្ធិក្នុងការចូលរួមក្នុងនីតិវិធី និងសិទ្ធិទទួលការយល់ដឹងអំពីនីតិវិធីជម្រះក្ដី គោរពជីវិតឯកជន និងគ្រួសារ និងសុចរិតភាព និងសេចក្ដីថ្លៃថ្នូរ។"

**ដំណើរការយុត្តិធម៌ព្រហ្មទណ្ឌ៖** ដូចបានកំណត់ក្នុងកថាខណ្ឌ ៩(គ) នៃសេចក្ដីណែនាំរបស់អង្គការសហប្រជាជាតិស្ដីពីកុមាររងគ្រោះ និងសាក្សី[2] "ដំណើរការយុត្តិធម៌ព្រហ្មទណ្ឌ" រួមបញ្ចូល "ការកំណត់ បទល្មើស ការដាក់បណ្ដឹង ការស៊ើបអង្កេត ការផ្ដន្ទាទោស ការជំនុំជម្រះក្ដី និងនីតិវិធីក្រោយការជំនុំជម្រះក្ដី ដោយមិនគិតថារឿងក្ដីនេះត្រូវបានដោះស្រាយនៅក្នុងប្រព័ន្ធតុលាការព្រហ្មទណ្ឌថ្នាក់ជាតិ ថ្នាក់អន្តរជាតិ ឬថ្នាក់តំបន់សម្រាប់មនុស្សពេញវ័យ ឬអនីតិជន ឬនៅក្នុងប្រព័ន្ធតុលាការ ឬក្រៅផ្លូវការឡើយ។"

---

[1] MoSVY (2016) Law on Juvenile Justice https://www.sithi.org/admin/upload/law/Law-on-Juvenile-Justice%202016-English-Final-Version.pdf

[2] ECOSOC (2005/20) "Guidelines on justice in Matters involving Child Victims and Witnesses of Crime" https://www.un.org/en/ecosoc/docs/2005/resolution%202005-20.pdf

**ការរំលោភបំពាន និងកេងប្រវ័ញ្ចផ្លូវភេទកុមារ៖** ដូចដែលបានកំណត់នៅក្នុងគោលការណ៍ណែនាំទាក់ទងនឹងប្រជុំសព្ទបច្ចេកទេស សម្រាប់ការពារកុមារពីការកេងប្រវ័ញ្ចផ្លូវភេទ[3] និងការរំលោភបំពានផ្លូវភេទ ការរំលោភបំពានផ្លូវភេទកុមារគឺជា "ទម្រង់នៃអំពើហិង្សាផ្លូវភេទទៅលើកុមារដែលមិនចាំបាច់មានការដោះដូរអ្វីមួយឡើយ និងអាចកើតឡើងក្នុងគោលបំណងដើម្បីបំពេញចំណង់ផ្លូវភេទរបស់បុគ្គលដែលប្រព្រឹត្តអំពើនោះ។ ការរំលោភបំពានបែបនេះអាចត្រូវបានប្រព្រឹត្តដោយគ្មានការបង្ខំជាក់លាក់ ឬដោយមានហេតុផលផ្សេងទៀត ដូចជាសិទ្ធិអំណាច អំណាច ឬឧបាយកលដែលជាកត្តាចម្បង...ការកេងប្រវ័ញ្ចផ្លូវភេទលើកុមារត្រូវបានសម្គាល់នូវភាពខុសគ្នាពីការរំលោភបំពានផ្លូវភេទលើកុមារតាមរយៈសញ្ញាណនៃការដោះដូរជាអំណោយ វត្ថុមានតម្លៃ ឬការចំណេញខាងសេដ្ឋកិច្ច ដែលកើតមានក្នុងការកេងប្រវ័ញ្ច"។

**ពហុទីភ្នាក់ងារ៖** ការចូលរួមសហប្រតិបត្តិការពីបណ្តាអង្គការមួយចំនួន ជាពិសេសក្នុងការបង្ការបទល្មើសកម្មវិធីសុខមាលភាពសង្គម ឬការស្រាវជ្រាវ [4]។

**ការផ្តោតលើប្រតិបត្តិការ៖** សំដៅលើការសម្រេចបាន ឬការបំពេញសកម្មភាពមួយឱ្យបានជោគជ័យ។

**សំណង៖** មាត្រា១៩ នៃសេចក្តីប្រកាសអំពីគោលការណ៍យុត្តិធម៌ជាមូលដ្ឋានសម្រាប់ជនរងគ្រោះនៃបទល្មើសនិងការរំលោភបំពានអំណាច[5] ចែងថាជនរងគ្រោះនៃបទល្មើសមានសិទ្ធិទទួលបានសំណងស្របច្បាប់ដែលរួមមានសំណងជួសជុលតាមទម្រង់ដូចខាងក្រោម៖ បដិទាន សំណងជម្ងឺចិត្ត ការស្តារនីតិសម្បទាការធ្វើបំពេញចិត្ត និងការធានាថានឹងមិនធ្វើម្តងទៀត

**ជនរងគ្រោះ៖** ដូចបានកំណត់និយមន័យដោយមាត្រា១៨ នៃសេចក្តីប្រកាសស្តីពីគោលការណ៍យុត្តិធម៌ជាមូលដ្ឋានសម្រាប់ជនរងគ្រោះនៃបទល្មើស និងការរំលោភបំពានអំណាច[6] ជនរងគ្រោះមានន័យថា "បុគ្គលគ្រប់រូប ដាច់ដោយឡែកឬជារួម បានរងការធ្វើបាបដែលមានការរងរបួសរាងកាយ ឬផ្លូវចិត្ត ការធ្វើបាបផ្នែកអារម្មណ៍ ការបាត់បង់ផ្នែកសេដ្ឋកិច្ច ឬសិទ្ធិជាមូលដ្ឋានរបស់ខ្លួនមានលក្ខណៈមិនគ្រប់គ្រាន់ តាមរយៈសកម្មភាព ឬកំហុសស្រាលៗដែលមិនទាន់បានបង្កើតជាការរំលោភច្បាប់ព្រហ្មទណ្ឌជាតិទេ ប៉ុន្តែរំលោភវិធានដែលត្រូវបានទទួលស្គាល់ជាអន្តរជាតិទាក់ទងនឹងសិទ្ធិមនុស្ស"។

---

[3] Interagency Working Group (2016), "Terminology Guidelines for the Protection of Children from Sexual Exploitation and Sexual Abuse". http://luxembourgguidelines.org/english-version/

[4] As defined by Oxford dictionary https://www.lexico.com/definition/multi-agency

[5] UN General Assembly (1985) "The Declaration of Basic Principles of Justice for Victims of Crime and Abuse of Power" https://www.un.org/ga/search/view_doc.asp?symbol=a/res/40/34

[6] ibid

# មូលសង្ខេប



**កុមារដែលរងការប៉ះពាល់ដោយអំពើរំលោភបំពាន និងកេងប្រវ័ញ្ចផ្លូវភេទទទួលរងនូវបទពិសោធន៍ឈឺចាប់ ដែលអាចមានទាំងផលវិបាករយៈពេលខ្លី និងរយៈពេលវែងទៅលើសុខុមាលភាព និងសមត្ថភាពរបស់ពួកគេក្នុងការរស់នៅប្រកបដោយសុខភាពល្អ។ ការស្វែងរកយុត្តិធម៌បន្ទាប់ពីការរងគ្រោះជាដំណាក់កាលសំខាន់មួយក្នុងការស្តារឡើងវិញសម្រាប់កុមារកុមារដែលពួកគេអាចទទួលបានសិទ្ធិក្នុងការទទួលបានសំណងចំពោះការរំលោភសិទ្ធិរបស់ពួកគេ។ ប៉ុន្តែនៅពេលដែលការទទួលបានយុត្តិធម៌ត្រូវបានសម្របសម្រួល និងការយកចិត្តទុកដាក់នៅមានកម្រិតក្នុងនីតិវិធីយុត្តិធម៌ព្រហ្មទណ្ឌកុមារនៅតែប្រឈមនឹងការរងគ្រោះ ឬការប៉ះទង្គិចផ្លូវអារម្មណ៍ឡើងវិញ។**

នីតិវិធីយុត្តិធម៌ព្រហ្មទណ្ឌពឹងផ្អែកលើកិច្ចសហការពេញលេញរវាងភាគីពាក់ព័ន្ធ និងទីភ្នាក់ងារផ្សេងៗគ្នាជាច្រើនដែលផ្តល់សេវាកម្ម រួមមានដូចជាមន្ត្រីអនុវត្តច្បាប់ និងអាជ្ញាធរមូលដ្ឋាន អ្នកផ្តល់សេវាសុខភាព អ្នកជំនាញក្នុងការផ្តល់ការគាំទ្រផ្នែកចិត្តសាស្ត្រសង្គម និងតួអង្គផ្នែកច្បាប់នៅក្នុងនីតិវិធីរបស់តុលាការ។

ការឆ្លើយតបរបស់ពហុភាគីចំពោះកុមាររងគ្រោះដោយហិង្សាគឺត្រូវបានពិចារណាថាជា "វិធានអនុវត្តល្អបំផុត" ដែលបង្កើនកិច្ចសហប្រតិបត្តិការ និងការសម្របសម្រួលរវាងអ្នកផ្តល់សេវា និងលើកកម្ពស់ការទទួលបានសេវាគាំទ្រសំខាន់ និងចាំបាច់សំរាប់ជនរងគ្រោះ[7]។ មជ្ឈមណ្ឌលច្រកចេញចូលតែមួយគឺជាគំរូមួយនៃការឆ្លើយតប ពហុភាគី ដែលបានរួមបញ្ចូលភ្នាក់ងារសំខាន់ៗ និងសេវាចាំបាច់ សំរាប់ជនរងគ្រោះដោយអំពើហិង្សានៅក្នុងកន្លែងតែមួយដោយធានាបាននូវវិធានដែលពេញលេញ និងគិតគូអំពីជនរងគ្រោះក្នុងការទទួលបានយុត្តិធម៌ និងសេវាគាំទ្រប្រសើរ ។

បំរែបំរួល និងការកែប្រែកើតមាននៅទីកន្លែងផ្សេងៗគ្នា ដែលកន្លែងខ្លះបង្កើតមជ្ឈមណ្ឌលច្រកចេញចូលតែមួយឡើង ដើម្បីឆ្លើយ តបទៅនឹងតម្រូវការជាក់លាក់របស់កុមារ និងខ្លះទៀតបង្កើត ឡើងដើម្បីឆ្លើយតបទៅនឹងកុមារ និងមនុស្សពេញវ័យ។ កត្តាទាំងនេះអាស្រ័យលើបំរែបំរួល និងភាពចាំបាច់។

នៅប្រទេសកម្ពុជា ទោះបីមានព័ត៌មានអំពីកិច្ចសហការរវាងពហុភាគីក៏ដោយ ក៏ភាគីភាគច្រើនប្រតិបត្តិដាច់ដោយឡែកពីគ្នា និងតាមវិធាននិងគោលនយោបាយរបស់ពួកគេរៀងៗខ្លួន។ ក្នុងដំណាក់កាលនីមួយៗនៃដំណើរការនេះកុមារអាចតម្រូវឱ្យនិយាយ ឬរំឭកឡើងវិញនូវបទពិសោធន៍នៃការរំលោភបំពានរបស់ពួកគេចំពោះអ្នកផ្តល់សេវានីមួយៗ ដែលអាចមានការប៉ះទង្គិចផ្លូវចិត្តរបស់ពួកគេ ហានិភ័យនៃការរងគ្រោះឡើងវិញ និងប៉ះពាល់ដល់សមត្ថភាពរបស់ពួកគេក្នុងការជាសះស្បើយ។

---

[7] WHO (2016) "INSPIRE: Seven Strategies for Ending Violence Against Children" https://www.end-violence.org/sites/default/files/paragraphs/download/9789241565356-eng.pdf

គោលបំណងនៃការសិក្សានេះ គឺដើម្បីស្វែងយល់អំពីវិធានមានស្រាប់រវាងភាគីផ្សេងៗ និងកំណត់ភស្តុតាងពាក់ព័ន្ធនឹងចន្លោះខ្វះខាត និងការអនុវត្តជាវិជ្ជមាន ដើម្បីគាំទ្រការអនុវត្តនិងការបង្កើតសេវាកម្មដែលផ្តោតលើ និងធានាថាឧត្តមប្រយោជន៍ល្អបំផុតរបស់កុមារ ត្រូវបានគិតគូរក្នុងនីតិវិធីយុត្តិធម៌ព្រហ្មទណ្ឌ។ លើសពីនេះការសិក្សាស្រាវជ្រាវនេះក៏មានគោលបំណងពិនិត្យថាតើរបៀបនៃការឆ្លើយតបពហុភាគីដូចជាមជ្ឈមណ្ឌលច្រកចេញចូលតែមួយអាចឆ្លើយតប និងបំពេញចន្លោះខ្វះខាតដែរឬទេ។

ដើម្បីសម្រេចគោលបំណងខាងលើ ការសិក្សានេះបានប្រើវិធីសាស្ត្រស្រាវជ្រាវដែលមានលក្ខណៈគុណភាពនិងចម្រុះ ដើម្បីពិនិត្យមើលការទាក់ទងដែលកុមារមានជាមួយភ្នាក់ងារ និងអ្នកផ្តល់សេវាកម្មសំខាន់ៗនៅក្នុងប្រទេសកម្ពុជា ដែលមានកាតព្វកិច្ចផ្តល់ការគាំទ្រដល់ពួកគេនៅពេលដែលមានករណីនៃការរំលោភបំពាន និងការកេងប្រវ័ញ្ចផ្លូវភេទលើកុមារ។ ភ្នាក់ងារនិងអ្នកផ្តល់សេវាកម្មត្រូវបានគេវាយតម្លៃយោងទៅតាមកម្រិតដែលពួកគេបានយល់ និងអនុវត្តនីតិវិធីបែបកុមារមេត្រីក្នុងដំណើរការ តើផលប្រយោជន៍ដែលល្អបំផុតសម្រាប់កុមារកម្រិតណាត្រូវបានគេចាត់ទុកថាជាអាទិភាពនៅក្នុងសកម្មភាពរបស់ពួកគេ និងកម្រិតទូទៅនៃការទទួលបានយុត្តិធម៌ និងសំណងខូចខាតសម្រាប់ការសះស្បើយឡើងវិញ។

គំរូច្រកចេញចូលតែមួយត្រូវបានគេណែនាំថាជាដំណោះស្រាយដែលអាចធ្វើទៅបានដើម្បីបំពេញចន្លោះខ្វះខាតក្នុងនីតិវិធី និងធានាថាកុមារទទួលបានការឆ្លើយតបប្រកបដោយប្រសិទ្ធភាពនិងដែលកាត់បន្ថយ

ភាពងាយរងគ្រោះនិងការប៉ះទង្គិចផ្លូវចិត្តឡើងវិញផងដែរ។ អត្ថប្រយោជន៍ និងដែនកំណត់នៃគំរូនេះត្រូវបានពិភាក្សាដោយពិចារណាលើសមត្ថភាពបច្ចុប្បន្នរបស់ស្ថាប័ន រួមទាំងការពិនិត្យលើយន្តការសម្របសម្រួល និងសហការរវាងភ្នាក់ងារ និងភាពខ្លាំងដែលមានស្រាប់ និងឧបសគ្គដែលមាននៅក្នុងប្រព័ន្ធយុត្តិធម៌ដែលអាចធ្វើឱ្យការអនុវត្តគំរូនេះមានប្រសិទ្ធិភាព។

របកគំហើញសំខាន់ៗនៃការស្រាវជ្រាវនេះបានបង្ហាញថាទោះបីមានការកែលម្អដោយរាជរដ្ឋាភិបាលកម្ពុជា ភាគី និងតួអង្គពាក់ព័ន្ធក៏ដោយ ចន្លោះខ្វះខាតក្នុងការឆ្លើយតបចំពោះកុមារនៅមានទំហំធំដែលអាចប៉ះពាល់ដល់ការ ការអនុវត្តសិទ្ធិពេញលេញរបស់កុមារក្នុងនីតិវិធីយុត្តិធម៌ព្រហ្មទណ្ឌ និងដល់ការគាំទ្រផ្នែកចិត្តសង្គមដែលកុមារទទួលបាន។ ខណៈពេលដែលមជ្ឈមណ្ឌលច្រកចេញចូលតែមួយមានលទ្ធភាពបង្កើនការទទួលបានយុត្តិធម៌ និងការទទួលបានសេវាគាទ្រ ភស្តុតាងដែលបានប្រមូលពីការស្រាវជ្រាវនេះបង្ហាញថា សមត្ថភាពស្ថាប័នក្នុងការបង្កើតមជ្ឈមណ្ឌលនេះនៅមានកំណត់ និងតម្រូវឱ្យមានការពង្រឹងបន្ថែមក្នុងគោលបំណងធ្វើឱ្យមជ្ឈមណ្ឌលច្រកចេញចូលតែមួយអាចសម្រេចបានលទ្ធផលដ៏ជោគជ័យ។

អនុសាសន៍ទទួលបានពីការស្រាវជ្រាវនេះផ្តោតលើផ្នែកផ្សេងៗគ្នាដែលតម្រូវឱ្យមានជាចាំបាច់មុននឹងចាប់ផ្តើមបង្កើតមជ្ឈមណ្ឌលនេះ រួមមានការពង្រឹងសមត្ថភាពនៃប្រព័ន្ធ និងភាគីពាក់ព័ន្ធ និងធានាថានីតិវិធីគឺបែបកុមារមេត្រី និងឆ្លើយតបទៅនឹងតម្រូវការរបស់កុមារ។ កត្តាសំខាន់ៗរួមមានជាអាទិ៍៖ ការផ្តល់អាទិភាពយុទ្ធសាស្ត្រក្នុងការកសាងសមត្ថភាព ការបណ្តុះបណ្តាល និងការធានាឱ្យមានធនធានមនុស្សបច្ចេកទេស និងធនធានថវិការ ការពង្រឹងកិច្ចសម្របសម្រួលកិច្ចសហប្រតិបត្តិការ និងយន្តការបញ្ជូន ដែលរួមមានការបង្កើតក្រុមការងារបច្ចេក ទេសពហុភាគី, ការពង្រឹងលើការទទួលបានយុត្តិធម៌បែបកុមារមេត្រី និងការគិតគូរចម្បងអំពីផលប្រយោជន៍ល្អបំផុតសម្រាប់កុមារក្នុងអំឡុងនីតិវិធីយុត្តិធម៌ព្រហ្មទណ្ឌការពង្រឹង និងបង្កើនសេវាថែទាំវេជ្ជសាស្ត្រ និងកោសល្យវិច្ច័យវេជ្ជសាស្ត្រសំរាប់ការឈ្លើយតបសមស្របទៅនឹងតម្រូវការរបស់កុមារ និងការប្រមូលភស្តុតាងវេជ្ជសាស្ត្រ ការពង្រឹង និងបង្កើនការផ្តល់សេវាគាំទ្រផ្នែកចិត្តសង្គម តាមរយៈការបង្កើននូវការទទួលបានសេវាគាំទ្រលើផ្នែកសុខភាពផ្លូវចិត្តរយៈពេលខ្លី និងវែង និងការទទួលបានការគាំទ្របន្ទាន់ចាំបាច់នានា និងធានាការប្រមូលទិន្នន័យត្រឹមត្រូវ ការតាមដាន និងវាយតម្លៃលើនីតិវិធីសំរាប់ការរៀនសូត្រ និងការធ្វើឱ្យប្រសើរឡើង។

# សេចក្ដីផ្ដើម

## ផលប៉ះពាល់នៃការរំលោភបំពាន និងកេងប្រវ័ញ្ចផ្លូវភេទកុមារ



ការរំលោភបំពាន និងការកេងប្រវ័ញ្ចផ្លូវភេទកុមារគឺជាការរាតត្បាតជាសកលមួយដែលជះឥទ្ធិពលដល់ជីវិតក្មេងប្រុស និងក្មេងស្រីរាប់លាននាក់នៅទូទាំងពិភពលោក។ យោងតាមមូលនិធិអង្គការសហប្រជាជាតិដើម្បីកុមារនៅឆ្នាំ ២០១៨ នៅទូទាំងពិភពលោកយ៉ាងហោចណាស់មានក្មេងស្រី ១២០ លាននាក់ដែលមានអាយុក្រោម ២០ ឆ្នាំ (ប្រហែល ១នាក់ ក្នុង ១០នាក់) ត្រូវបានបង្ខំឱ្យចូលរួមក្នុងការរួមភេទ ឬធ្វើសកម្មភាពផ្លូវភេទផ្សេងទៀត[8] ។ មានរាប់លានទៀត រាប់បញ្ចូលទាំងក្មេងប្រុស មិនដែលប្រាប់នរណាម្នាក់ឡើយ[9] ។ ប្រទេសកម្ពុជាក៏ដូច្នោះដែរ មានក្មេងស្រី៤ ភាគរយ និងក្មេងប្រុស ៦ ភាគរយនៅក្នុងប្រទេសបានសារភាពថាពួកគេបានឆ្លងកាត់អំពើហិង្សាផ្លូវភេទយ៉ាងហោចណាស់មួយទម្រង់មុនអាយុ ១៨ ឆ្នាំ[10]។

**១២០ លាននាក់**

**នៅឆ្នាំ ២០១៨**

**ក្មេងស្រីដែលមានអាយុក្រោម ២០ឆ្នាំ**

ត្រូវបានបង្ខំឱ្យចូលរួមក្នុងការរួមភេទ ឬធ្វើសកម្មភាពផ្លូវភេទផ្សេងទៀត។

ការប៉ះទង្គិចផ្លូវចិត្តពីការរំលោភបំពាន និងការកេងប្រវ័ញ្ចផ្លូវភេទលើកុមារអាចមានផលវិបាកយ៉ាងធ្ងន់ធ្ងរក្នុងរយៈពេលជាច្រើនឆ្នាំបន្ទាប់ពីហេតុការណ៍កើតឡើង ហើយប៉ះពាល់ដល់កត្តាចិត្តសាស្ត្រសង្គម និងសេដ្ឋកិច្ចជាច្រើន។ ផលវិបាកសុខភាពផ្លូវចិត្តរយៈពេលវែងដូចជាការធ្លាក់ទឹកចិត្ត ភាពតានតឹងក្រោយពេលប៉ះទង្គិច ធ្វើបាបខ្លួនឯង អាកប្បកិរិយាធ្វើអត្តឃាត និងភាពងាយរងគ្រោះទៅនឹងការសេពសារធាតុញៀន។

ផលវិបាកសុខភាពផ្សេងទៀតអាចមានដូចជាការកើនឡើងនូវហានិភ័យនៃការរងគ្រោះផ្លូវភេទឡើងវិញ ការសម្រេចចិត្តលើ សុខភាពផ្លូវភេទមិនត្រឹមត្រូវដែលនាំឱ្យមានការកើនឡើងនូវ ភាពងាយរងគ្រោះពាក់ព័ន្ធនឹងជំងឺឆ្លងតាមការរួមភេទ និងការមានផ្ទៃពោះដែលមិនចង់បាន[11] ។ ទោះបីមានផលប៉ះពាល់ទាំងនេះក៏ដោយ កុមារ និងគ្រួសារជាច្រើនមិនស្វែងរកជំនួយបន្ទាប់ពីមានការរំលោភបំពាន ហើយមានកុមារ និងគ្រួសារតិចតួចប៉ុណ្ណោះបន្តចូលរួមក្នុងនីតិវិធីស្វែងរកយុត្តិធម៌ [12]។

ផលប៉ះពាល់ដល់សុខភាពផ្លូវកាយ និងផ្លូវចិត្តរយៈពេលខ្លី និងរយៈពេលវែងដោយអំពើរំលោភបំពាន និងកេងប្រវ័ញ្ចផ្លូវភេទលើកុមារជះឥទ្ធិពលដោយផ្ទាល់ដល់ការអប់រំ សុខភាព និងអនាគតការងារដែលនាំឱ្យមានបន្ទុកខាងសេដ្ឋកិច្ចដល់ប្រទេស[13]។

---

8 United Nations press release. "Deputy Secretary General Urges Governments to Invest in 2030 Agenda Targets, at Event on New Index Protecting Children from Sexual Abuse." October 3rd 2018. https://www.un.org/press/en/2018/dsgsm1230.doc.htm

9 ibid

10 MoWA (2014) "Findings from Cambodia's Violence against Children Survey" https://violenceagainstchildren.un.org/sites/violenceagainstchildren.un.org/files/documents/political_declarations/east_asia_and_pacific/cambodias_violence_against_children_survey.pdf

11 UNFPA (2010) "Addressing Violence Against Women and Girls in Sexual and Reproductive Health Services" https://www.unfpa.org/sites/default/files/pub-pdf/addressing_violence.pdf

12 MoWA (2014) "Findings from Cambodia's Violence against Children Survey" https://violenceagainstchildren.un.org/sites/violenceagainstchildren.un.org/files/documents/political_declarations/east_asia_and_pacific/cambodias_violence_against_children_survey.pdf

យោងតាម Xiangming ក្នុងឆ្នាំ ២០១៣ គេប៉ាន់ស្មានថា បន្ទុកខាងសេដ្ឋកិច្ចនៃផលវិបាកសុខភាពដោយសារអំពើហិង្សាលើកុមារតែមួយមុខនៅកម្ពុជាមានចំនួនសរុប១៦៨លានដុល្លារអាមេរិក ( ៧៦,៩ លានដុល្លារសម្រាប់ស្ត្រី និង ៩០,៩ លានដុល្លារសម្រាប់បុរស ) ដែលស្មើនឹង ១,១០ ភាគរយនៃផលិតផលក្នុងស្រុកសរុបរបស់ប្រទេស[13] ។ លើសពីនេះទៀត ការខាតបង់ផលិតភាពដោយសារអំពើហិង្សាក្នុងវ័យកុមារក្នុងឆ្នាំ ២០១៣ មានចំនួនសរុប ៨៣,៣ លានដុល្លារដែលស្មើនឹង ០,៥៥ ភាគរយនៃផលិតផលក្នុងស្រុកសរុប[14] ។ មានកុមារអាយុក្រោម ១៧ឆ្នាំ[15] ស្មើនឹងចំនួន ៣៧ ភាគរយនៃចំនួនប្រជាជននៅក្នុងប្រទេសកម្ពុជា ( ប្រហែល ៥,៩ លាន នាក់ ) វិធានការនានាគួរត្រូវពង្រឹងដើម្បីការពារ និងបង្ការកុមារពីការរំលោភបំពាន និងការកេងប្រវ័ញ្ចផ្លូវភេទ។

កុមារដែលជាជនរងគ្រោះនៃអំពើហិង្សា និងអំពើកេងប្រវ័ញ្ចត្រូវការការគាំទ្រ និងសេវាកម្មជាច្រើនដែលនឹងធានាថាពួកគេជាសះស្បើយឡើងវិញ និងទទួលបានយុត្តិធម៌តាមនីតិវិធីផ្លូវច្បាប់។ ទោះបីជាមានការខិតខំប្រឹងប្រែងដើម្បីផ្តល់ការគាំទ្រដល់កុមារ ដែលរងការប៉ះពាល់នៅក្នុងដំណើរការយុត្តិធម៌ក៏ដោយ ប្រព័ន្ធនានានៅតែផ្តោតលើការសម្រេចជោគជ័យនៃប្រតិបត្តិការ ដែលផ្តោតលើការទទួលបានភស្តុតាងសម្រាប់ការផ្តន្ទាទោសជនល្មើស ដោយទុកឱ្យកុមារធ្លាក់ក្នុងភាពងាយរងគ្រោះនៅពេលចូលរួមនីតិវិធីដែលបានបង្កើតឡើងសម្រាប់មនុស្សពេញវ័យ។ ការឆ្លើយតបមិនគ្រប់គ្រាន់ និងកង្វះការពិចារណាលើតម្រូវការជាក់លាក់របស់កុមារក្នុងនីតិវិធីយុត្តិធម៌ព្រហ្មទណ្ឌអាចបន្ថែមនូវផលប៉ះពាល់អវិជ្ជមានលើផលប៉ះពាល់នៃការរំលោភបំពាន ដែលអាចឈានដល់កង្វះទំនុកចិត្តលើប្រព័ន្ធយុត្តិធម៌ទៀតផង។

# សិទ្ធិទទួលបានយុត្តិធម៌ និងសេវាគាំទ្រនានា

ក្រៅពីសិទ្ធិជាមូលដ្ឋានរបស់កុមារ ការធ្វើឱ្យប្រសើរឡើងនូវសិទ្ធិទទួលបានយុត្តិធម៌ និងការពង្រឹងការឆ្លើយតប និងសេវាគាំទ្រដល់កុមារដែលរងគ្រោះដោយអំពើរំលោភបំពាន និងកេងប្រវ័ញ្ចផ្លូវភេទត្រូវបានរាប់បញ្ចូលជាយុទ្ធ សាស្ត្រមួយក្នុងយុទ្ធសាស្ត្រ INSPIRE ដែលជម្រុញដោយភាពជាដៃគូសកលដើម្បីបញ្ចប់អំពើហិង្សាលើកុមារ( Global Partnership to End Violence Against Children )។ យុទ្ធសាស្ត្រនេះត្រូវបានទទួលស្គាល់ជាសាកលថាជាដំណោះស្រាយដែលផ្អែកលើភស្តុតាងជាក់លាក់ដើម្បីបញ្ចប់អំពើហិង្សាលើកុមា ដែលនឹងនាំមកនូវផលចំណេញយ៉ាងច្រើនសម្រាប់ការវិនិយោគលើការអប់រំ និងសុខភាព[16] ។

សិទ្ធិទទួលបានយុត្តិធម៌សម្រាប់កុមារដូចដែលបានកំណត់និយមន័យតាមច្បាប់អន្តរជាតិគឺ “សមត្ថភាពក្នុងការទទួលបានការគាំពារប្រកបដោយយុត្តិធម៌ និងទាន់ពេលវេលាសម្រាប់ការរំលោភសិទ្ធិ [17]”។ សិទ្ធិទទួលបានយុត្តិធម៌ និងការគាំពារគឺជាការចាំបាច់ក្នុងការស្តារឡើងវិញបន្ទាប់ពីការរំលោភបំពាន និងការកេងប្រវ័ញ្ច និងត្រូវបានបង្កើតឡើងជាសិទ្ធិមនុស្សជាមូលដ្ឋានដែលកុមារគ្រប់រូបត្រូវទទួលបានដោយមិនគិតពីភេទ សញ្ជាតិ និងប្រវត្តិសង្គមសេដ្ឋកិច្ចឡើយ។ គោលគំនិតនៃសិទ្ធិទទួលបានយុត្តិធម៌សំរាប់កុមារទាមទារឱ្យមានការផ្តល់អំណាចផ្អែកច្បាប់ដល់កុមារទាំងអស់។

---

13 Xiangming, F. (2015) The Economic Burden of the Health Consequences of Violence Against Children in Cambodia, Ministry of Women's Affairs, UNICEF Cambodia, Phnom Penh. http://www.togetherforgirls.org/wp-content/uploads/CVAC__Cambodia-Full-Report__EN.pdf

14 ibid

15 UNICEF (2018) "A Statistical Profile of Child Protection in Cambodia" https://www.unicef.org/cambodia/media/711/file

16 WHO (2016) "INSPIRE: Seven Strategies for Ending Violence Against Children" https://www.end-violence.org/sites/default/files/paragraphs/download/9789241565356-eng.pdf

17 ECOSOC Resolution 2005/20 Guidelines on Justice in Matters involving Child Victims and Witnesses of Crime https://www.un.org/en/ecosoc/docs/2005/resolution%202005-20.pdf

ពួកគេគួរតែត្រូវបានអនុញ្ញាតឱ្យទទួលបានព័ត៌មានពាក់ព័ន្ធ និងការគាំពារដែលមានប្រសិទ្ធិភាពដើម្បីទាមទារសិទ្ធិរបស់ពួកគេ រួមទាំងសេវាគាំទ្រផ្នែកច្បាប់ និងសេវាផ្សេងៗ ការអប់រំពីសិទ្ធិកុមារ ការផ្តល់ប្រឹក្សាឬដំបូន្មាន និងការគាំទ្រពីមនុស្សពេញវ័យដែលមានចំណេះដឹង [18]។

ដើម្បីធានាថាប្រព័ន្ធយុត្តិធម៌មានលក្ខណៈគិតគូរពីតម្រូវការរបស់កុមារ និងតម្រូវការពិសេសនានា នីតិវិធីដើម្បីធានានូវ "យុត្តិធម៌បែបកុមារមេត្រី" ត្រូវបានកំណត់យោងតាមស្តង់ដារអន្តរជាតិ ដើម្បីដោះស្រាយនូវរាល់ចន្លោះខ្វះខាតក្នុងការឆ្លើយតបចំពោះកុមារ។ យោងតាមនិយមន័យមួយរបស់ក្រុមប្រឹក្សាអឺរ៉ុប “យុត្តិធម៌បែបកុមារមេត្រី” មានន័យថា “ការបង្កើតប្រព័ន្ធយុត្តិធម៌ដែលធានានូវការគោរព និងការអនុវត្តប្រកបដោយប្រសិទ្ធភាពនូវសិទ្ធិកុមារទាំងអស់ដោយពិចារណាត្រឹមត្រូវលើកម្រិត នៃភាពពេញវ័យ និងការយល់ដឹងរបស់កុមារ និងស្ថានភាពនៃករណីនោះ។ ជាពិសេសវាជាយុត្តិធម៌ដែលអាចទទួលបានសមស្របតាមអាយុ មានល្បឿនលឿន មានលក្ខណៈយកចិត្តទុកដាក់ដែលសម្របទៅតាមនិងផ្តោតលើតម្រូវការ និងសិទ្ធិរបស់កុមារ មានការគោរពសិទ្ធិរបស់កុមាររួមទាំងសិទ្ធិទទួលបាននីតិវិធីនៃចំណាត់ការ រួមបញ្ចូលទាំងការចូលរួម និងការស្វែងយល់ពីនីតិវិធីជម្រះរឿង ក្តី និងមានការគោរពជីវិតឯកជន និងគ្រួសារ និងសុចរិតភាព និងសេចក្តីថ្លៃថ្នូរ [19] ។

ទោះបីជាការគិតពីផលប្រយោជន៍ល្អបំផុតសំរាប់កុមារត្រូវបានគេចាត់ទុកថាជាគោលការណ៍មួយក្នុងចំណោមគោលការណ៍ស្នូល យោងតាមអនុសញ្ញាស្តីពីសិទ្ធិកុមារក៏ដោយ ( សូមមើលប្រអប់ទី១ ) ក៏វិធានការក្នុងការធានាអំពីការចូលរួមរបស់ពួកគេក្នុងនីតិវិធីយុត្តិធម៌ ព្រហ្មទណ្ឌជារឿយៗត្រូវបានគេមើលរំលង។ ដូចដែលបានរៀបរាប់នៅក្នុងសៀវភៅណែនាំសំរាប់អនុវត្តអនុសញ្ញាស្តីពីសិទ្ធិកុមារ [20] ដែលរាជរដ្ឋាភិបាលកម្ពុជាផ្តល់សច្ចាប័ន ការពិចារណាលើផលប្រយោជន៍ល្អបំផុតរបស់កុមារមានន័យថាវាគួរតែជាការពិចារណាចម្បង ទោះបីត្រូវចំណាយ ឬលះ បង់ផលប្រយោជន៍ផ្សេងទៀត ក៏ដោយ។ ឧទាហរណ៍ ក្នុងនីតិវិធីស្វែងរកយុត្តិធម៌កុមារត្រូវតែមានអារម្មណ៍សុវត្ថិភាព និងផាសុខាភាពអំឡុងពេលសម្ភាស ដូច្នេះ នគរបាល ឬតួអង្គយុត្តិធម៌ផ្សេងទៀតគប្បីសម្របអកប្បកិរិយា និងសកម្មភាពរបស់ពួកគេដើម្បីឆ្លើយតបនឹងតម្រូវការរបស់កុមារ។ វាតម្រូវឱ្យភាគីពាក់ព័ន្ធទាំងអស់ធានាឱ្យបាននូវសិទ្ធិទទួលបានយុត្តិធម៌សម្រាប់កុមារ និងការដាក់បញ្ចូលនីតិវិធីបែបកុមារមេត្រី នៅគ្រប់ដំណាក់កាលនីតិវិធីទាំងអស់។

## ប្រអប់ ១៖ ផលប្រយោជន៍ល្អបំផុតរបស់កុមារ - មាត្រា ៣នៃ អនុសញ្ញាស្តីពីសិទ្ធិកុមារ

១. ក្នុងវិធានការទាំងអស់ដែលពាក់ព័ន្ធនឹងកុមារ ទោះធ្វើឡើងដោយស្ថាប័នឯកជន ឬសធារណៈទទួលភារៈខាងសុខុមាលភាពសង្គមឬដោយតុលាការ ឬអាជ្ញាធររដ្ឋបាល ឬអង្គការនីតិបញ្ញត្តិក៏ដោយ ឧត្តមប្រយោជន៍របស់កុមារត្រូវតែយកចិត្តទុកដាក់ជាចម្បង។

២. រដ្ឋភាគីសន្យាធានាដល់កុមារនូវការការពារ និងការថែទាំចាំបាច់ដើម្បីសុខុមាលភាពរបស់កុមារដោយយកមកគិតនូវសិទ្ធិ និងករណីយកិច្ចរបស់ឪពុក-ម្តាយ អ្នកអាណាព្យាបាល ឬបុគ្គលផ្សេងទៀតដែលទទួលខុសត្រូវតាមផ្លូវច្បាប់ចំពោះកុមារ និងដើម្បីសម្រេចទិសដៅនេះរដ្ឋភាគីត្រូវចាត់វិធានការខាងនីតិបញ្ញាតិ និងរដ្ឋបាលដែលសមស្របទាំងអស់។

៣. រដ្ឋភាគីត្រូវធានាថា ស្ថាប័ន សេវាកម្ម និងគ្រឹះស្ថានដែលមានបន្ទុកថែទាំ ឬការការពារកុមារ ត្រូវគោរពតាមបទដ្ឋានដែលកំណត់ដោយអាជ្ញាធរមានសមត្ថកិច្ចជាពិសេសនៅក្នុងវិស័យនៃសុវត្ថិភាព សុខភាព អំពីចំនួន និងភាពសមស្របនៃបុគ្គលិក ព្រមទាំងសមត្ថកិច្ចគ្រប់គ្រង។

---

18 UN Common Approach to Justice for Children (2008) ,http://dag.un.org/bitstream/handle/11176/400572/UN%20Common%20Approach%20to%20Justice%20for%20Children%202008.pdf?sequence=52&isAllowed=y p. 4

19 Guidelines of the Committee of Ministers of the Council of Europe on Child-Friendly Justice, article II.a https://rm.coe.int/16804b2cf3

20 UNICEF (2007) “Implementation Handbook for the Convention on the Rights of the Child” https://www.unicef.org/Implementation__Handbook__for__the__Convention__on__the__Rights__of__the__Child.pdf

# វឌ្ឍនភាព និងចន្លោះខ្វះខាតនៅប្រទេសកម្ពុជា

នៅឆ្នាំ ១៩៩២ រាជរដ្ឋាភិបាលកម្ពុជាបានផ្តល់សច្ចាប័នលើអនុសញ្ញាស្តីពីសិទ្ធិកុមារ និងបានប្តេជ្ញាគោរពសិទ្ធិ កុមារ និងប្តេជ្ញាលើកកម្ពស់សិទ្ធិរបស់កុមារនៅក្នុងរបៀបវារៈមុនគេបង្អស់របស់ពួកគេ។ ចាប់តាំងពីពេលនោះមករាជរដ្ឋាភិបាលកម្ពុជាបានខិតខំប្រឹងប្រែងយ៉ាងខ្លាំងដើម្បីលើកកម្ពស់ច្បាប់ និងការអនុវត្តការការពារកុមារ ធ្វើឱ្យប្រសើរឡើងនូវប្រព័ន្ធយុត្តិធម៌សម្រាប់កុមារ និងធានាថាសិទ្ធិកុមារត្រូវបានការពារ។ នៅឆ្នាំ ២០១៩ ប្រទេសកម្ពុជាបានក្លាយជាសមាជិកទី ២៦ នៃភាពជាដៃគូរពិភពលោកដើម្បីបញ្ចប់អំពើហិង្សាលើកុមារ [21] ។ តាមរយៈការ ផ្តល់សច្ចាប័ន រាជរដ្ឋាភិបាលកម្ពុជាបានបង្ហាញការប្តេជ្ញាចិត្តរបស់ខ្លួនចំពោះការអនុវត្តច្បាប់ និងគោលនយោបាយពាក់ព័ន្ធនឹងការការពារកុមារ និងទម្រង់ផ្សេងទៀតនៃការរំលោភបំពាន និងការកេងប្រវ័ញ្ចលើកុមារនិងឆ្ពោះទៅរកការសម្រេចបានគោលដៅអភិវឌ្ឍប្រកបដោយចីរភាពត្រឹមឆ្នាំ២០៣០។

**ប្រទេសកម្ពុជាគឺជាប្រទេសដំបូងគេនៅអាស៊ីអាគ្នេយ៍ ដែលបានធ្វើការអង្កេតថ្នាក់ជាតិស្តីពីអំពើហិង្សាលើកុមារក្នុងឆ្នាំ ២០១៣[22]។ ការអង្កេតថ្នាក់ជាតិនេះបានចូលរួមចំណែកក្នុងការអភិវឌ្ឍផែនការសកម្មភាពជាតិ ដើម្បីបង្ការ និងឆ្លើយតបចំពោះអំពើហិង្សាលើកុមារសម្រាប់ឆ្នាំ ២០១៧-២០២១[23] ហើយគណៈកម្មាធិការនៅត្រូវបានបង្កើតឡើងដោយក្រសួងកិច្ចការនារីក្នុងឆ្នាំ២០១៩ ដើម្បី ដឹកនាំ និងសម្របសម្រួលការអនុវត្តផែនការជាតិ[24]នេះ។**

នៅឆ្នាំ ២០១៩ រាជរដ្ឋាភិបាលកម្ពុជាបានបង្កើតគោលនយោបាន និងបទដ្ឋានអប្បបរមាសម្រាប់ការការពារសិទ្ធិរបស់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស[25] ហើយថ្មីៗនេះរាជរដ្ឋាភិបាលកម្ពុជាប្រកាសថានឹងធ្វើការពិនិត្យឡើងវិញ និងធ្វើបច្ចុប្បន្នភាពគោលនយោបាយដើម្បីធានាឱ្យបាននូវការគោរពសិទ្ធិរបស់ជនរងគ្រោះ[26] ។ ក្នុងឆ្នាំ២០២០ រាជរដ្ឋាភិបាលកម្ពុជាបានផ្សព្វផ្សាយគោលនយោបាយស្តីពីប្រព័ន្ធកិច្ចការពារកុមារ ដែលរួមបញ្ចូលផែនការសកម្មភាព១០ឆ្នាំ (២០១៩-២០២៩) ដើម្បីធានាឱ្យបានថាកុមារគ្រប់រូបមានសិទ្ធិស្មើគ្នារួមទាំងសិទ្ធិរស់រាន មានជីវិតសិទ្ធិទទួលបានការការពារ សិទ្ធិអភិវឌ្ឍ និងសិទ្ធិចូលរួម។ គោលនយោបាយនេះផ្តោតលើសសរស្តម្ភចំនួន៣៖ ការបង្ការ អន្តរាគមន៍ និងការផ្តល់សេវាកម្ម ដើម្បីធានាការឆ្លើយតបមានលក្ខណៈពេញលេញនិងជាប្រព័ន្ធសំដៅកុមារគ្រប់រូបទទួលបានការការពារ [27]។

---

21 The Global Partnership to End Violence Against Children (2019) "Cambodia Becomes the 26th Pathfinding Country. Accessed at https://www.end-violence.org/articles/cambodia-becomes-worlds-26th-pathfinding-country
MoWA (2014) "Findings from Cambodia's Violence against Children Survey" https://violenceagainstchildren.un.org/sites/violenceagainstchildren.un.org/files/documents/political_declarations/east_asia_and_pacific/cambodias_violence_against_children_survey.pdf

22 MoWA (2014) "Findings from Cambodia's Violence against Children Survey" https://violenceagainstchildren.un.org/sites/violenceagainstchildren.un.org/files/documents/political_declarations/east_asia_and_pacific/cambodias_violence_against_children_survey.pdf

23 The Steering Committee on Violence Against Women and Violence Against Children (2017), "Action Plan to Prevent and Respond to Violence Against Children 2017-2021" Accessed at https://www.unicef.org/cambodia/reports/action-plan-prevent-and-respond-violence-against-children-2017-2021

24 RGC (2019) "Cambodia's Voluntary National Review 2019 on the Implementation of the 2030 Agenda for Sustainable Development" https://sustainabledevelopment.un.org/content/documents/23603Cambodia_VNR_PublishingHLPF.pdf

25 RGC (2009)"Policy and Minimum Standards for Protection of the Rights of Victims of Human Trafficking" http://un-act.org/publication/view/cambodias-policy-and-minimum-standards-for-protection-of-the-rights-of-victims-of-human-trafficking-2009/

26 Vanyuth, C. and Soco R.M (2021) "Cambodia Reviews 11-year old Policy on Rights of Human Trafficking Victims" https://www.khmertimeskh.com/50806976/cambodia-reviews-11-year-old-policy-on-rights-of-human-trafficking-victims/ Press release January 26, 2021

27 RGC (2020) "National Policy on Child Protection to Provide Equal Opportunities to All Children". Press release July 30, 2020 https://www.khmertimeskh.com/50750079/national-policy-on-child-protection-to-provide-equal-opportunities-to-all-children/

នៅក្នុងការសិក្សាស្រាវជ្រាវមួយដែលសំដៅលើការលើកកម្ពស់ចំណេះដើម្បីឆ្លើយតបទៅនឹងការរំលោភបំពាន និងកេងប្រវ័ញ្ចផ្លូវភេទក្នុងប្រទេសចំនួន៦០[28] ប្រទេសកម្ពុជាស្ថិតក្នុងចំណាត់ថ្នាក់ ៥៩.៧ យោងតាមការប្តេជ្ញាចិត្ត និងសមត្ថភាពរបស់រាជរដ្ឋាភិបាលក្នុងការដោះស្រាយ និងឆ្លើយតបលើអំពើរំលោភបំពាន និងកេងប្រវ័ញ្ចផ្លូវភេទលើកុមារ។ លំដាប់ថ្នាក់នេះខ្ពស់ជាងប្រទេសមានចំណូលខ្ពស់មួយចំនួន ដូចជាប្រទេសបារាំង ( ៥៤,៦ ) ឬប្រទេសជប៉ុន( ៥២,១ ) និងកម្ពុជាមានចំណាត់ថ្នាក់ខ្ពស់ជាងគេបង្អស់នៅអាស៊ីអាគ្នេយ៍[29] ។ ភស្តុតាងនៃសមត្ថភាព និងការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាលចំពោះការទប់ស្កាត់អំពើរំលោភបំពាន និងកេងប្រវ័ញ្ចផ្លូវភេទលើកុមារ ត្រូវបានកំណត់នៅពេលកិច្ចខិតខំប្រឹងប្រែង គោរពតាមលក្ខណៈវិនិច្ឆ័យចំពោះការប្រមូលទិន្នន័យដែលត្រូវប្រើជាយុទ្ធសាស្ត្រដើម្បីធ្វើការសម្រេចចិត្ត និងពេលមានកិច្ចការបង្ការ និងសេវាគាំពារចំពោះកុមារដែលងាយរងគ្រោះដោយអំពើហិង្សាផ្លូវភេទ[30] ។ កត្តានេះបង្ហាញថា បើទោះបីមានការប្រឈមផ្នែកសេដ្ឋកិច្ចដែលប្រទេសមានចំណូលមធ្យមកំរិតទាបកំពុងជួបប្រទះក៏ដោយ ការសម្រេចបាន និងការរីកចំរើននៅតែអាចធ្វើទៅបាន។ ធនធានហិរញ្ញវត្ថុគឺគ្រាន់តែជាសុច្ចនាករមួយក្នុងចំណោមសុច្ចនាករដទៃដែលរួមមានសមត្ថភាព និងកម្រិតនៃការវិវឌ្ឍសំរាប់រាជរដ្ឋាភិបាលដើម្បីធានាឱ្យបាននូវការគោរពសិទ្ធិកុមារ។

ខណៈពេលដែលប្រទេសកម្ពុជាបានបង្ហាញវឌ្ឍនភាពក្នុងប៉ុន្មានឆ្នាំនេះ កង្វះខាតជាច្រើនសម្រាប់ការពារកុមារជាពិសេសទាក់ទងនឹងការរំលោភបំពាន និងការកេងប្រវ័ញ្ចផ្លូវភេទលើកុមារនៅតែមាន។ មកដល់បច្ចុប្បន្ននេះ មិនទាន់មានច្បាប់ស្តីពីកិច្ចការការពារកុមារដែលធានាការការពារពេញលេញចំពោះកុមារពីការកេងប្រវ័ញ្ចគ្រប់ទម្រង់ដែលរួមមានហិង្សា ការរំលោភបំពាន ការព្រងើយកន្តើយ ឬការកេងប្រវ័ញ្ច ដូចបានកំណត់តាមមាត្រា១៩ នៃអនុសញ្ញាស្តីពីសិទ្ធិកុមារនៅឡើយទេ។ ទោះបីជាមានច្បាប់ និងគោលនយោបាយជាច្រើនដែលរួមបញ្ចូលបញ្ហាពាក់ព័ន្ធនឹងកិច្ចការពារកុមារ[31] ក៏ដោយ ភាគច្រើនគ្រាន់តែគ្របដណ្តប់លើបញ្ហាមួយផ្នែក ដោយមិនឆ្លើយតបនឹងការដោះស្រាយបញ្ហាទាំងមូល ហើយមានការផ្តោតតិចតួចលើការឆ្លើយតបចំពោះជនរងគ្រោះនៃការរំលោភបំពាន និងការកេងប្រវ័ញ្ចផ្លូវភេទ[32] ។

លើសពីនេះទៅទៀត ការអនុវត្តមិនមានភាពស៊ីសង្វាក់ចំពោះច្បាប់គោលនយោបាយ ឬគោលការណ៍ណែនាំដែលមានស្រាប់ពាក់ព័ន្ធនឹងកិច្ចការពារកុមារធ្វើឱ្យអាក់ខានដល់ការការពារជាទូទៅដែលត្រូវផ្តល់ដល់កុមារ ដោយសារកង្វះគោលការណ៍ណែនាំការអនុវត្ត និងនីតិវិធីដែលត្រូវអនុវត្តតាមដោយបុគ្គលិករដ្ឋាភិបាល ឬភាគីអនុវត្តផ្សេងទៀត ក៏ដូចជាកង្វះចំណេះដឹង និងការបណ្តុះបណ្តាលបច្ចេកទេសទាក់ទងនឹងច្បាប់ថ្មីៗផងដែរ។

នីតិវិធីយុត្តិធម៌ព្រហ្មទណ្ឌគឺជាផ្នែកមួយដែលកុមារនៅតែស្ថិតក្នុងស្ថានភាពងាយរងគ្រោះ ខណៈដែលនៅមានកង្វះខាតច្រើនក្នុងការឆ្លើយតបនឹងការការពារ និងការស្តារឡើងវិញរបស់ពួក។ ក្នុងដំណើរការយុត្តិធម៌ព្រហ្មទណ្ឌ តួអង្គផ្សេងៗគ្នាជាច្រើនដូចជាមន្ត្រីអនុវត្តច្បាប់ និងអាជ្ញាធរមូលដ្ឋានអ្នកផ្តល់សេវា សុខភាពវេជ្ជសាស្ត្រ អ្នកវិជ្ជាជីវៈផ្តល់ការគាំទ្រផ្នែកចិត្តសាស្ត្រ សង្គម និងតួអង្គផ្នែកច្បាប់នៅក្នុងនីតិវិធីរបស់តុលាការសុទ្ធតែមានការពាក់ព័ន្ធ។ នៅប្រទេសកម្ពុជា បើទោះបីជាមានភស្តុតាងបញ្ជាក់ពីកិច្ចសហប្រតិបត្តិការក៏ដោយ ទីភ្នាក់ងារនីមួយៗនៅតែអនុវត្តដាច់ដោយឡែកពីគ្នា និងប្រតិបត្តិតាមស្តង់ដារវិធានច្បាប់ និងគោលនយោបាយរបស់ពួកគេរៀងៗខ្លួន ដែលបានបង្កើតឡើងដាច់ដោយឡែកពីគ្នា និងមិនបានឆ្លុះបញ្ចាំងរួមអំពីឧត្តមប្រយោជន៍របស់កុមារ។ បន្ថែមលើនេះ ភស្តុតាងនៃការប្រគួតប្រជែងរវាងភ្នាក់ងារមួយ ឬអ្នកផ្តល់សេវាមួយ និងភ្នាក់ងារ ឬអ្នកផ្តល់សេវាផ្សេងទៀត និងធនធាន អាចជាយន្តការផុយស្រួយក្នុងការផ្តល់សេវាកម្មដល់ជនរងគ្រោះ។

---

28 The Economist (2020) "Out of the Shadows: Shining Light on the Response to Child Sexual Abuse and Exploitation" https://outoftheshadows.eiu.com/wp-content/uploads/2020/04/Out-of-the-Shadows__whitepaper__60-countries__2020.pdf

29-30 ibid

31 To name a few, laws and procedures that address child protection issues are included under: The Constitution of the Kingdom of Cambodia, The Civil Code and the Civil Procedure Code, The Criminal Code and the Criminal Procedure Code, The Law on Prevention of Domestic Violence and Protection of Victims, The Law on Suppression of Human Trafficking and Sexual Exploitation, The Juvenile Justice Law

32 RGC (2009)"Policy and Minimum Standards for Protection of the Rights of Victims of Human Trafficking" http://un-act.org/publication/view/cambodias-policy-and-minimum-standards-for-protection-of-the-rights-of-victims-of-human-trafficking-2009/

33 Reimer, J.K.(2015). A SYSTEM JUST FOR CHILDREN: Voices of child victims and witnesses about their experiences in the Cambodian Criminal Justice System. Hagar, Phnom Penh, Cambodia. https://hagarinternational.org/wp-content/uploads/2018/04/Hagar-Research-A-System-Just-for-Children.pdf

ក្នុងដំណាក់កាលនេះ មិនទាន់មានក្រុមឆ្លើយតបពហុភាគីដែលផ្ដល់សេវាគាំទ្រដល់កុមារដែលរងគ្រោះដោយហិង្សានៅក្នុងដំណើរការនីតិវិធីព្រហ្មទណ្ឌនៅឡើយទេ។ ការយល់ដឹង និងការអនុវត្តនីតិវិធីកុមារមេត្រីដែលនៅមានកម្រិតធ្វើឱ្យកុមារងាយរងគ្រោះជាពិសេសនៅក្នុងដំណើរ ការនីតិវិធីនេះ។ នៅក្នុងការសិក្សារបស់ Reimer[33] ជាឧទាហរណ៍ កុមារចំនួន៥៤ ដែលជាជនរងគ្រោះនៃអំពើហិង្សាត្រូវបានគេសម្ភាស និងបានរៀបរាប់បទពិសោធន៍របស់ពួកគេនៅក្នុងនីតិវិធីយុត្តិធម៌ព្រហ្មទណ្ឌ។ ពួកគេបានរៀបរាប់អំពីការលំបាកយ៉ាងខ្លាំង និងកង្វះការគិតគូរលើតម្រូវការផ្លូវចិត្ត និងសុវត្ថិភាពរាងកាយរបស់ពួកគេ។ ពួកគេត្រូវនិយាយឡើងវិញនៅដំណាក់កាលនីមួយៗនៃដំណើរការដែលពេលខ្លះពួកគេប្រាប់ថាត្រូវបាននគរបាលសើចចំអក ពួកគេត្រូវបានសម្ភាសដោយមានវត្តមានមនុស្សផ្សេងទៀតនៅក្នុងបន្ទប់ ដោយមិនគិតពីឯកជនភាព និងការសម្ងាត់របស់គេឡើយ។ មានករណីខ្លះទៀត កុមាររងគ្រោះត្រូវប្រឈមមុខនឹងជនល្មើសរបស់ពួកគេនៅក្នុងនីតិវិធីរបស់តុលាការ។ ១/៥នៃកុមារទាំងអស់ បានប្រាប់ថាខ្លួនត្រូវបានស្នើសុំឱ្យបង់ប្រាក់ក្រៅផ្លូវការបន្ថែមពីលើការបង់ប្រាក់ប្រដាប់ក្ដីធម្មតា[34] ។

# គោលបំណងនៃការសិក្សា

ការរាយការណ៍ដដែលៗអំពីបទពិសោធន៍របស់កុមារដែលចូលរួមក្នុងនីតិវិធីយុត្តិធម៌ព្រហ្មទណ្ឌបានលើកឡើងក្នុងអំឡុងពេលអង្គការសកម្មភាពដើម្បីកុមារធ្វើការជាមួយពួកគេបានបង្ហាញពីភាពចាំបាច់ក្នុងការពិចារណាលើ និងប្រព័ន្ធឆ្លើយតបថ្មីប្រសើរជាងមុននៅក្នុងប្រទេសកម្ពុជា ដែលអាចបំពេញតម្រូវការរបស់ពួកគេបានកាន់តែប្រសើរ និងកែលម្អការគាំទ្រក្នុងដំណើរការនីតិវិធីយុត្តិធម៌ព្រហ្មទណ្ឌសំរាប់កុមារដែលរងគ្រោះដោយអំពើរំលោភបំពាន និងកេងប្រវ័ញ្ចផ្លូវភេទ ។

យុទ្ធសាស្ត្រដែលត្រូវបានគេចាត់ទុកថាជាការអនុវត្តល្អបំផុតដើម្បីកាត់បន្ថយហានិភ័យនៃការរងគ្រោះឡើងវិញ និងធានាថាសិទ្ធិរបស់កុមារត្រូវបានគោរពក្នុងនីតិវិធីយុត្តិធម៌ព្រហ្មទណ្ឌ គឺការបង្កើតក្រុមឆ្លើយតបពហុភាគី[35]។ សេចក្ដីអត្ថាធិបាយដោយអគ្គលេខាធិការរងនៃអង្គការសហប្រជាជាតិ Amina Mohammed បានចង្អុលបង្ហាញ និងរៀបរាប់អំពីយន្តការនេះថា៖




"ទិន្នន័យច្បាស់លាស់អំពីវិសាលភាព និងផលប៉ះពាល់នៃអំពើហិង្សាផ្លូវភេទលើកុមារបានធ្វើឱ្យយើងយល់ដឹងកាន់តែស៊ីជម្រៅអំពីកិច្ចការដែលធ្វើឱ្យសង្គមមានសុវត្ថិភាពសម្រាប់កុមារ។ ឧទាហរណ៍ យើងដឹងហើយថាការបញ្ចប់អំពើហិង្សាផ្លូវភេទ គឺពឹងផ្អែកលើសកម្មភាពជាតិដែលមានការសម្របសម្រួលពីពហុវិស័យ ឬពហុភាគីដោយផ្អែកលើភស្តុតាង...។ នៅថ្នាក់ជាតិ នេះមានន័យថាជាក្របខណ្ឌច្បាប់ និងគោលនយោបាយ ប្រព័ន្ធ និងស្ថាប័នដែលកាន់តែរឹងមាំដើម្បីធានានូវការរាយការណ៍ ការគាំពារជនរងគ្រោះប្រកបដោយការយកចិត្តទុកដាក់ពីមន្ត្រីអនុវត្តច្បាប់ និងប្រព័ន្ធយុត្តិធម៌ និងការគាំទ្រខាងផ្លូវកាយ និងផ្លូវចិត្តនិងសង្គមពីប្រព័ន្ធសុខាភិបាល និងសេវាសង្គមកិច្ច "[36] ។

---

34 ibid

35 WHO (2016) “INSPIRE: Seven Strategies for Ending Violence Against Children” https://www.end-violence.org/sites/default/files/paragraphs/download/9789241565356-eng.pdf

36 United Nations press release. “Deputy SecretaryGeneral Urges Governments to Invest in 2030 Agenda Targets, at Event on New Index Protecting Children from Sexual Abuse.” October 3rd 2018. https://www.un.org/press/en/2018/dsgsm1230.doc.htm

មជ្ឈមណ្ឌលច្រកចេញចូលតែមួយ គឺជាគំរូនៃការឆ្លើយតបរបស់ពហុភាគីដែលផ្តល់អាទិភាពលើតំរូវការរបស់ជនរងគ្រោះ។ នៅក្នុងមជ្ឈមណ្ឌលច្រកចេញចូលតែមួយ នគរបាល និងមន្ត្រីអនុវត្តច្បាប់ អ្នកផ្តល់សេវាសុខភាព បុគ្គលិកសង្គម គ្រូពេទ្យព្យាបាល និងអ្នកផ្តល់ជំនួយផ្នែកច្បាប់ ទាំងអស់សហការគ្នានៅក្នុងកន្លែងតែមួយ ដើម្បីផ្តល់ការគាំទ្រពេញលេញដល់ជនរងគ្រោះ និងផ្តោតលើឧត្តមប្រយោជន៍ជនរងគ្រោះជាចំបង។

## ដូចនេះ គោលបំណងនៃការសិក្សានេះត្រូវបានចែកចេញជាពីរគឺ៖

១. ដើម្បីពិនិត្យមើលថាតើឧត្តមប្រយោជន៍របស់កុមារត្រូវបានពិចារណាជាអាទិភាពកម្រិតណាក្នុងដំណើរការនីតិវិធីព្រហ្មទណ្ឌ និងសេវាគាំទ្រដែលផ្តល់ដល់ជនរងគ្រោះក្នុងដំណើរការដូចគ្នានេះ ព្រមទាំងពិនិត្យមើលថាតើមជ្ឈមណ្ឌលច្រកចេញចូលតែមួយអាចឆ្លើយតបនឹងតម្រូវការ និងបំពេញចន្លោះខ្វះខាតក្នុងការផ្តល់សេវាដែលជាតម្រូវការរបស់កុមារដែរឬទេ។

២. ដើម្បីវាយតម្លៃលើភាពខ្លាំង សក្តានុពល និងដែនកំណត់សម្រាប់ការអនុវត្តមជ្ឈមណ្ឌលច្រកចេញចូលតែមួយនៅក្នុងសមត្ថភាពបច្ចុប្បន្នរបស់ស្ថាប័នដើម្បីកំណត់លទ្ធភាពនៃការអនុវត្តរបស់មជ្ឈមណ្ឌលច្រកចេញចូលតែមួយ ឬជម្រើសផ្សេងទៀតដែលអាចផ្តល់អាទិភាពខ្លាំងដល់ឧត្តមប្រយោជនរបស់កុមារ។

ទោះនេះមិនមែនជាការសិក្សាលើកដំបូងក្នុងការពិនិត្យតម្រូវការ និងលទ្ធភាពសម្រាប់មជ្ឈមណ្ឌលច្រកចេញចូលតែមួយនៅប្រទេសកម្ពុជាសម្រាប់ជនរងគ្រោះដោយសារអំពើរំលោភបំពាន និងកេងប្រវ័ញ្ច ក៏ការស្រាវជ្រាវ និងការពិចារណាពីមុនៗបានផ្តោតសំខាន់លើជនរងគ្រោះដោយសារអំពើហិង្សាផ្អែកលើយេនឌ័រ និងគិតគូរពីតម្រូវការរបស់ស្ត្រី និងក្មេងស្រីដោយពុំផ្តោតលើតម្រូវការពិសេសរបស់កុមារ និងថាតើសិទ្ធិរបស់ពួកគេត្រូវបានគោរពបែបណានៅក្នុងការអនុវត្តបែបនេះទេ[37] ។ ការផ្តោតលើជនរងគ្រោះដោយសារអំពើហិង្សាផ្អែកលើយេនឌ័រក៏មិនយកចិត្តទុកដាក់ចំពោះតម្រូវការរបស់ជនរងគ្រោះជាក្មេងប្រុស និងបុរសដែលបច្ចុប្បន្នទទួលបានការឆ្លើយតបតិចតួចពីអ្នកផ្តល់សេវា។

ការសិក្សានេះគឺជាការសិក្សាដំបូងគេមួយនៅក្នុងប្រទេសកម្ពុជា ដើម្បីពិចារណាលើការកសាងមជ្ឈមណ្ឌលច្រកចេញចូលតែមួយដែលជាការឆ្លើយតបដែលមានលក្ខណៈប្រសើរចំពោះជនរងគ្រោះដោយអំពើរំលោភបំពានដែលផ្តោតលើឧត្តមប្រយោជន៍កុមារអាទិភាពនៅក្នុងរាល់ចំណាត់ការទាំងអស់។

[37] MoWA (2012) Feasibility Study for One Stop Service Centers. Phnom Penh

# វិធីសាស្ត្រ

ការសិក្សានេះត្រូវបានធ្វើឡើងនៅចន្លោះ ខែកក្កដា ឆ្នាំ ២០២០ ដល់ ខែធ្នូ ឆ្នាំ ២០២០ ។ វិធីសាស្ត្រដែលត្រូវបានប្រើប្រាស់សម្រាប់សម្រេចគោលបំណងនៃការសិក្សានេះ គឺផ្អែកលើវិធីសាស្ត្រស្រាវជ្រាវដែលមានលក្ខណៈគុណភាព និងមានបញ្ចូលយុទ្ធសាស្ត្រដូចខាងក្រោម៖

## ការពិនិត្យស្រាវជ្រាវឯកសារដែលមានស្រាប់

បណ្តុំឯកសារសកល ក្នុងតំបន់ និងក្នុងស្រុកដែលមានស្រាប់ទាក់ទងនឹងមជ្ឈមណ្ឌលច្រកចេញចូលតែមួយ និងនីតិវិធីបច្ចុប្បន្នដែលកុមាររងគ្រោះចូលរួមក្នុងដំណើរការនីតិវិធីយុត្តិធម៌ព្រហ្មទណ្ឌត្រូវបានពិនិត្យ និងវិភាគ។ ការពិនិត្យ និងវិភាគនេះត្រូវបានប្រើជាមូលដ្ឋានសម្រាប់កំណត់ការអនុវត្តល្អបំផុតអនុទ្ទេសតាមស្តង់ដារអន្តរជាតិ ដោយពិចារណាលើតម្រូវការ និងបរិបទបច្ចុប្បន្ននៅក្នុងប្រទេសកម្ពុជា។

ការពិនិត្យស្រាវជ្រាវឯកសារដែលមានស្រាប់ រួមបញ្ចូលការពិនិត្យលើការសិក្សាស្រាវជ្រាវស្តីពីមជ្ឈមណ្ឌលច្រកចេញចូលតែមួយ និងបម្រែបម្រួលនៃគំរូនានានៅទូទាំងពិភពលោក ករណីសិក្សា ការពិនិត្យលើច្បាប់ជាតិ គោលនយោបាយ និងបញ្ញត្តិ និងនីតិវិធីដែលមានស្រាប់នៅកម្ពុជាដែលពាក់ព័ន្ធនឹងកិច្ចការពារកុមារ និងការផ្តល់សេវាដល់កុមាររងគ្រោះដោយអំពើរំលោភបំពាន និងឯកសារ និងរបាយការណ៍ពាក់ព័ន្ធផ្សេងទៀត។

## បទសម្ភាសន៍របស់អ្នកពាក់ព័ន្ធ

បទសម្ភាសន៍ពាក់កណ្តាលផ្លូវការ និងបទសម្ភាសន៍ស៊ីជម្រៅសរុបចំនួន ២៨ ត្រូវបានធ្វើឡើងជាមួយអ្នកជំនាញមកពីស្ថាប័នរាជរដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាល និងអ្នកពាក់ព័ន្ធនានាពីទីភ្នាក់ងារ និងអ្នកផ្តល់សេវាសំខាន់ៗដែលមានកាតព្វកិច្ច និងតម្រូវឱ្យឆ្លើយតបនឹងកុមាររងគ្រោះដោយសារការរំលោភបំពានដែលចូលក្នុងនីតិវិធីយុត្តិធម៌ព្រហ្មទណ្ឌ។ ទាំងនេះរួមបញ្ចូលទាំងនគរបាល តួអង្គតុលាការអ្នកផ្តល់សេវាច្បាប់ អ្នកផ្តល់ការគាំទ្រផ្នែកកិច្ចការសង្គម និង សុខភាពផ្លូវចិត្ត និងអ្នកជំនាញវេជ្ជសាស្ត្រដែលទាក់ទងនឹង ការធ្វើកោសល្យវិច្ច័យបន្ទាប់ពីការរំលោភបំពាន។ (សម្រាប់បញ្ជីពេញលេញនៃក្រុមអ្នកចូលរួមដែលបែងចែកដោយក្រុមអ្នកពាក់ព័ន្ធ សូមពិនិត្យមើលឧបសម្ព័ន្ធ)។

បទសម្ភាសន៍ត្រូវបានធ្វើឡើងជាភាសាអង់គ្លេស ដោយមានជំនួយពីអ្នកបកប្រែភាសាអង់គ្លេសទៅខ្មែរ និងពីខ្មែរទៅអង់គ្លេស។ លិខិតយល់ព្រមជាលាយលក្ខណ៍អក្សរ និងដែលបានជូនដំណឹងបានទទួលពីអ្នកផ្តល់បទសម្ភាសន៍ និងត្រូវបានដាក់លេខកូដចំណាំ។ ខ្សែអាត់សំឡេងក៏ត្រូវបានថតទុកផងដែរក្នុងអំឡុងពេលធ្វើបទសម្ភាសន៍នៅពេលមានការយល់ព្រម ប៉ុន្តែជាងពាក់កណ្តាលនៃអ្នកដែលផ្តល់បទសម្ភាស (៦៤%) មិនបានផ្តល់ការយល់ព្រមឱ្យថតសំឡេងទេ ដូច្នេះត្រូវកត់ត្រានៅពេលសម្ភាសន៍។ ខ្សែអាត់សំឡេងត្រូវបានចម្លងចេញជាលាយលក្ខណ៍អក្សរ និងបកប្រែ។

អ្នកចូលរួមត្រូវបានជ្រើសរើសចេញពីរាជធានីភ្នំពេញ និងខេត្តសៀមរាបដែលជាខេត្តសំខាន់ពីរដែល អង្គការសកម្មភាពដើម្បីកុមារធ្វើប្រតិបត្តិការនៅទីនោះ ហើយក៏ត្រូវបានគេចាត់ទុកថាមានសមត្ថភាពផ្នែកស្ថាប័នរឹងមាំជាងគេផងដែរ។ ការលើកលែងមួយត្រូវបានធ្វើឡើងដោយមានការបញ្ចូលអ្នកចូលរួមពីរនាក់ពីមន្ត្រីអនុវត្តច្បាប់នៅក្នុងខេត្តកណ្តាល ដែលត្រូវបានជ្រើសរើសដោយសារតែពួកគេបានចូលរួមក្នុងដំណើរទស្សនកិច្ចសិក្សាទៅមជ្ឈមណ្ឌលច្រកចេញចូលតែមួយនៅប្រទេសហ្វីលីពីន កាលពីឆ្នាំ២០១៩ ជាមួយបុគ្គលិករបស់អង្គការសកម្មភាពដើម្បីកុមារ និងអាចមានសមត្ថភាពផ្តល់នូវទស្សនៈ និងការយល់ដឹងរបស់ពួកគេដោយពិចារណាទៅលើបទពិសោធន៍របស់ពួកគេនៅបរទេស។

### បទសម្ភាសន៍ជាមួយអ្នកពាក់ព័ន្ធនីមួយៗបានផ្តោតលើចំណុចសំខាន់ចំនួនពីរ៖

១. **ការយល់ដឹងអំពីតម្រូវការ៖** សំណួរនៅក្នុងចំណុចនេះត្រូវបានផ្តោតលើការពិនិត្យមើលនីតិវិធីនាពេលបច្ចុប្បន្នដែលធ្វើឡើងដោយអ្នកផ្តល់សេវាកម្ម និងទីភ្នាក់ងារសំខាន់ៗ ការយល់ដឹង និងការអនុវត្តនីតិវិធីបែបកុមារមេត្រីអំឡុងពេលដំណើរការ និងថាតើឧត្តមប្រយោជន៍របស់កុមារត្រូវបានចាត់ទុកថាជាអាទិភាព ឬអត់។

២. **ស្វែងយល់ពីលទ្ធភាពអាចធ្វើទៅបាននៃការអនុវត្តមជ្ឈមណ្ឌលច្រកចេញចូលតែមួយ៖** ដើម្បីវាយតម្លៃចំណុចនេះ សំណួរផ្តោតលើសមត្ថភាពស្ថាប័នបច្ចុប្បន្នសម្រាប់ការអនុវត្ត រួមមានដូចជាធនធានហិរញ្ញវត្ថុ និងធនធានមនុស្សដែលមានស្រាប់ ឧបករណ៍ចាំបាច់ ការសម្របសម្រួល និងកិច្ចសហប្រតិបត្តិការរវាងអ្នកផ្តល់សេវា ការបណ្តុះបណ្តាល និងច្បាប់ និងបទបញ្ញត្តិ គោលនយោបាយដែលមានស្រាប់ដែលអាចគាំទ្រ ឬផ្ទុយទៅនឹងការបង្កើតបែបនេះ។

គោលគំនិតរួមដែលទទួលបានពីកិច្ចសម្ភាសន ត្រូវបានចងក្រង ពិនិត្យ និងវិភាគ ដើម្បីកំណត់អំពីអន្តរបញ្ហានៅក្នុងវិស័យផ្សេងៗគ្នា ។ ធាតុចូលដែលទទួលបានពីកិច្ចសម្ភាសន៍ត្រូវបានធ្វើការប្រៀបធៀប និងបូកបញ្ចូលជាមួយទិន្នន័យដែលបានលើកឡើងក្នុងអំឡុងពេលពិនិត្យស្រាវជ្រាវឯកសារដែលមានស្រាប់ និងរបាយការណ៍ពាក់ព័ន្ធនឹងបទពិសោធន៍របស់កុមារ ដើម្បីពង្រឹងការពិនិត្យឱ្យបានគ្រប់ជ្រុងជ្រោយ ។

## ការវិភាគលើទិន្នន័យបន្ទាប់បន្សំនៃបទពិសោធន៍របស់កុមារ

សកម្មភាពដាច់ដោយឡែកមួយដែលធ្វើឡើងដោយអង្គការសកម្មភាពដើម្បីកុមារ ក្រោមគម្រោងមួយដែលផ្តល់ថវិកាដោយអង្គការ ECPAT Sweden ក្នុងអំឡុងឆ្នាំ ២០១៩-២០២០ មានគោលបំណងដើម្បីពិនិត្យមើលលើការអនុវត្តបែបកុមារមេត្រីនៅក្នុងនីតិវិធីយុត្តិធម៌ព្រហ្មទណ្ឌ និងថាតើសិទ្ធិកុមារត្រូវបានគោរពឬទេ យោងតាមទស្សនៈរបស់កុមារ។ កុមារចំនួន ៤៣ នាក់ (ប្រុស២១នាក់ និង ស្រី ២៣នាក់) មកពីរាជធានីភ្នំពេញ ខេត្តសៀមរាប និងខេត្តកណ្តាលបានចូលរួមក្នុងការពិភាក្សាជាក្រុមដែលពួកគេបានចែករំលែកគោលគំនិតរបស់ពួកគេ និងបានឆ្លុះបញ្ចាំងពីបទពិសោធន៍របស់ពួកគេក្នុងដំណាក់កាលនគរបាលយុត្តិធម៌ ដំណាក់កាលពិនិត្យកោសល្យវិច្ច័យវេជ្ជសាស្ត្រ និងនៅគ្រប់ដំណាក់កាលនីតិវិធីតុលាការ (ព្រះរាជអាជ្ញា ចៅក្រមស៊ើបសួរ និងក្នុងអំឡុងពេលជំនុំជម្រះក្តី)។ សកម្មភាពឆ្លុះបញ្ចាំងទាំងនេះមិនបានផ្តោតលើការថែទាំផ្នែកចិត្តសង្គមដែលពួកគេ ទទួលពីបុគ្គលិកសង្គមកិច្ចក្នុងអំឡុងពេលដំណើរការនីតិវិធីខាងលើនេះទេ។

ក្នុងអំឡុងពេលធ្វើសកម្មភាពរបស់កុមារ សមាសភាគដែលពាក់ព័ន្ធនឹងកុមារមេត្រីត្រូវបានវាយតម្លៃនៅតាមដំណាក់កាលនីមួយៗដែលរួមមានឥរិយាបថ និងអាកប្បកិរិយារបស់អ្នកផ្តល់សេវា ការទទួលបានព័ត៌មានគ្រប់គ្រាន់របស់កុមារ នៅពេលពួកគេមកដល់ តម្រូវការបន្ទាន់របស់កុមារត្រូវបានដោះស្រាយឬអត់ ភេទរបស់បុគ្គលិកដែលបានសម្ភាសកុមារ ទីតាំងធ្វើបទសម្ភាសន៍ បុគ្គលិកពាក់ឯកសណ្ឋាន ឬអត់ ឯកជនភាព និងការសម្ងាត់របស់ពួកគេត្រូវបានរក្សាឬអត់ និងរយៈពេលនៃដំណើរការ។ នៅពេលធ្វើសកម្មភាពឆ្លុះបញ្ចាំងទាំងនេះ កុមារបានផ្តល់មតិរបស់ពួកគេលើចំណុចអវិជ្ជមាន និងវិជ្ជមាន ក្នុងអំឡុងពេលដំណើរការក៏ដូចជាយោបល់ និងគំនិតរបស់ពួកគេសម្រាប់ការផ្លាស់ប្តូរផងដែរ។

ដោយសារសកម្មភាពទាំងនេះត្រូវបានធ្វើឡើងក្នុងរយៈពេលមួយឆ្នាំមុនដែលមានគោលបំណងប្រហាក់ប្រហែលគ្នា និងដើម្បីបង្ការការប៉ះទង្គិច ឬរងគ្រោះឡើងវិញក្នុងពេលសម្ភាសន៍ ដោយពួកគេត្រូវរៀបរាប់ឡើងវិញនូវបទពិសោធន៍ដែលអាចនឹកឃើញដល់រឿងហេតុនៃការរំលោភបំពានរបស់លើពួកគេ ដូច្នេះការវិភាគបន្ទាប់បន្សំលើរបាយការណ៍ពីសកម្មភាពទាំងនេះត្រូវបានប្រើប្រាស់សម្រាប់ការសិក្សានេះ។ ទោះបីជាសកម្មភាពឆ្លុះបញ្ចាំងមិនត្រូវបានរចនាឡើងយ៉ាងពិសេសសម្រាប់ការស្រាវជ្រាវនេះក៏ដោយ ក៏ព័ត៌មានដែលដកស្រង់ចេញពីរបាយការណ៍ទាំងនេះ បានបង្ហាញនូវសមាសភាគចាំបាច់មួយដែលបង្ហាញយ៉ាងច្បាស់ពីដំណើរការនីតិវិធីដែលកុមារឆ្លងកាត់ គំនិតផ្ទាល់ខ្លួន និងបទពិសោធន៍របស់ពួកគេ និងចំណុចដែលពួកគេចង់ឃើញមានការផ្លាស់ប្តូរនៅក្នុងប្រព័ន្ធហើយត្រូវបានបញ្ចូលទៅក្នុងការវិភាគនៃវិស័យនីមួយៗនៅក្នុងនីតិវិធីយុត្តិធម៌ព្រហ្មទណ្ឌ។

## ការសង្កេតនៅទីតាំងផ្ទាល់

បុគ្គលិកពាក់ព័ន្ធមកពីអង្គការសកម្មភាពដើម្បីកុមារ រួមជាមួយតំណាងមកពី ការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជននៃស្នងការដ្ឋាននគរបាលខេត្តកណ្តាល បានចុះទស្សនកិច្ចសិក្សានៅប្រទេសហ្វីលីពីន និងតំណាងមកពីនាយដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃអគ្គស្នងការដ្ឋាននគរបាលជាតិ និងតំណាងមកពីការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជននៃស្នងការដ្ឋានរាជធានីភ្នំពេញ រួមទាំងតំណាងមកពីមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បានធ្វើទស្សនៈកិច្ចសិក្សានៅប្រទេសថៃ និងប្រទេសស៊ុយអែត ដើម្បីសង្កេតមើលគំរូដែលមានស្រាប់ ដែលកំពុងអនុវត្តដោយក្រុមការងារពហុភាគីសំដៅជួយកុមាររងគ្រោះដោយសារអំពើហិង្សា ដើម្បីរៀនសូត្រពីការអនុវត្តល្អបំផុត និងស្វែងយល់ពីបញ្ហាប្រឈមដែលមាននៅក្នុងបរិបទប្រចាំតំបន់ និងអន្តរជាតិ។ នៅប្រទេសហ្វីលីពីន ប្រតិភូបានទៅទស្សនាមជ្ឈមណ្ឌលច្រកចេញចូលតែមួយដែលបានស្ថាបនា និងដំណើរការនៅក្នុង មន្ទីរពេទ្យចំនួនពីរ ដែលមួយក្នុងចំណោមពីរប្រតិបត្តិក្នុងកំរិតថ្នាក់ក្រុង។ ក្រុមការងារពហុភាគីមួយទៀតនៅប្រទេសថៃគឺមជ្ឈមណ្ឌលតស៊ូមតិសម្រាប់កុមារ ( Child Advocacy Center ) នៅប៉ាតាយ៉ា ដែលបានធ្វើប្រតិបត្តិការដោយមូលនិធិA២១ ។ ដំណើរទស្សនកិច្ចសិក្សាដើម្បីស្វែងយល់ពីគំរូ Barnahus នៅក្នុងប្រទេសស៊ុយអែតបានផ្តល់ការយល់ដឹងបន្ថែមពីប្រព័ន្ធដែលបានបង្កើតឡើងជាពិសេសសម្រាប់កុមារដើម្បីធ្វើការប្រៀបធៀបគ្នា។ របាយការណ៍ពីការធ្វើទស្សនកិច្ចទាំងនេះត្រូវបានពិនិត្យ និងវិភាគ ហើយដំណើរទស្សនកិច្ចសិក្សាបន្ថែមទៅមជ្ឈមណ្ឌលតស៊ូមតិសម្រាប់កុមាររបស់មូលនិធីA២១ នៅខេត្តសៀមរាបត្រូវបានធ្វើឡើងជាពិសេសសម្រាប់ការស្រាវជ្រាវនេះ។

ដំណើរទស្សនកិច្ចសិក្សាបានផ្តល់នូវការយល់ដឹងដ៏មានតម្លៃលើបញ្ហាប្រឈម និងការអនុវត្តល្អបំផុតសម្រាប់ធ្វើការប្រៀបធៀប និងការវិភាគក៏ដូចជាបានជួយឱ្យមានការសង្កេតលើភាពខុសគ្នានៃទីតាំងដែលដឹកនាំ និងគ្រប់គ្រងដោយរដ្ឋាភិបាល( ក្នុងប្រទេសហ្វីលីពីន ) និងដោយអង្គការមិនមែនរដ្ឋាភិបាល (នៅប្រទេសថៃ និងខេតសៀមរាបប្រទេសកម្ពុជា )។ ទិន្នន័យទាំងនេះត្រូវបានប្រៀបធៀប និងបញ្ចូលទៅក្នុងរបកគំហើញពីការពិនិត្យឯកសារនៃគំរូមជ្ឈមណ្ឌលច្រកចេញចូលតែមួយនៅក្នុងប្រទេសដទៃទៀត។

# ការបដិសេធទទួលខុសត្រូវនិងដែនកំណត់នៃការសិក្សា



**ក្នុងនាមជាអ្នកស្រាវជ្រាវដែលមិននិយាយភាសាខ្មែរព័ត៌មានទទួលបានពីបទសម្ភាសន៍ ឯកសារ និងរបាយការណ៍ជាភាសាខ្មែរ ត្រូវពឹងផ្អែកលើការបកប្រែដែលអាចបណ្តាលឱ្យមានភាពខ្វះចន្លោះក្នុងការប្រើប្រាស់ភាសា និងការយល់។**

ការលំបាកផ្នែកបច្ចេកទេសពាក់ព័ន្ធនឹងការរៀបចំកាលវិភាគ និងការធ្វើឱ្យបទសម្ភាសន៍ដំណើរការរលូន បានធ្វើឱ្យមានការបន្ថយនូវទំហំសំណាកនៃអ្នកចូលរួមដែលបានគ្រោងទុកពីដំបូង។ មួយផ្នែកផ្សេងទៀតដោយសារតែការសិក្សានេះមានរយៈពេលខ្លី និងការស្នើសុំធ្វើការសម្ភាសជាមួយមន្ត្រីរាជរដ្ឋាភិបាលខ្លះមានការចំណាយពេលយូរ។ សំណើមួយចំនួនត្រូវបានច្រានចោលដោយទទួលបានចម្លើយ ដូចជាមិនមានពេលវេលា និងពុំទំនេរដើម្បីផ្តល់ការសម្ភាស ការមិនយល់ព្រមផ្តល់ព័ត៌មានដោយមិនមានចែងនៅក្នុងអនុស្សរណៈនៃការយោគយល់គ្នា និងការរាំងស្ទះមួយចំនួនពាក់ព័ន្ធនឹងស្ថានភាពជំងឺកូវីដ១៩។ លើសពីនេះទៀត ខណៈដែលការសិក្សាមានគោលបំណងធ្វើឱ្យមានតុល្យភាពចំនួនស្តីពីប្រភេទក្រុមគោលដៅ និងវិជ្ជាជីវៈផ្សេងៗគ្នា ដូច្នេះអ្នកចូលរួមមិនត្រូវបានជ្រើសរើសដោយចៃដន្យ ឬតាមភេទ ដែលមានលក្ខណៈសមតុល្យនោះទេ ផ្ទុយទៅវិញអ្នកចូលរួមត្រូវបានជ្រើសរើសដោយផ្អែកលើកម្រិតបទពិសោធន៍ដែលធ្វើការលើបញ្ហាដែលទាក់ទងនឹងកុមាររងគ្រោះដោយសារអំពើរំលោភបំពាន និងកេងប្រវ័ញ្ច និងផ្អែកលើឆន្ទៈក្នុងការចូលរួម។

ដោយសារវិសាលភាព និងដែនកំណត់នៃការសិក្សានេះ ការសិក្សានេះផ្តោតលើទីភ្នាក់ងារ និងសេវាកម្មដែលផ្តល់ជូនដល់កុមាររងគ្រោះដោយអំពើរំលោភបំពាន និងកេងប្រវ័ញ្ចផ្លូវភេទនៅថ្នាក់ខេត្ត និងនៅតាមទីតាំងកំណត់ ហើយមិនបានពិនិត្យហ្មត់ចត់លើការឆ្លើយតបពីខាងថ្នាក់ស្រុក និងឃុំឡើយ។ ការប្រែប្រួលខ្លាំងនៃការឆ្លើយតបទំនងជាកើតមានទៅតាមទីតាំងខុសៗគ្នា និងយោងតាមការឆ្លើយតបក្នុងមូលដ្ឋានដែលអាចបង្កើតជាការរឹតត្បិតក្នុងការឆ្លុះបញ្ចាំងពីលទ្ធផលនៃការស្រាវជ្រាវនេះនៅទូទាំងប្រទេស។

ដោយសារចក្ខុវិស័យ និងបេសកកម្មចម្បងរបស់អង្គការសកម្មភាពដើម្បីកុមារ ផ្តោតលើការការបង្ការ និងការពារកុមាររងគ្រោះដោយអំពើរំលោភបំពាន និងកេងប្រវ័ញ្ចផ្លូវភេទ ពួកគេគឺជាចំណុចផ្តោតសំខាន់នៃការស្រាវជ្រាវនេះ។ ទោះយ៉ាងណាបេកគំហើញនៃការស្រាវជ្រាវនេះគឺពាក់ព័ន្ធនឹងកុមារណាដែលរងគ្រោះដោយអំពើហិង្សាគ្រប់ទម្រង់ និងឆ្លងកាត់ដំណើរការនីតិវិធីយុត្តិធម៌ព្រហ្មទណ្ឌក្នុងនាមជាជនរងគ្រោះ ឬជាសាក្សី។ ការសិក្សានេះមិនមានរួមបញ្ចូលជនរងគ្រោះដោយអំពើកេងប្រវ័ញ្ចផ្លូវភេទតាមអនឡាញទេ ដូច្នេះការសិក្សាបន្ថែម ឬពាក់ព័ន្ធនឹងអនឡាញគឺចាំបាច់ដើម្បីពិនិត្យលើបទពិសោធន៍របស់កុមាររងគ្រោះក្នុងដំណើរនីតិវិធីយុត្តិធម៌ព្រហ្មទណ្ឌ។ លើសពីនេះទៀត ការសិក្សា និងការគិតគូរបន្ថែមគួរតែត្រូវបានធ្វើដើម្បីធ្វើឱ្យប្រសើរឡើងនូវដំណើរការនីតិវិធីយុត្តិធម៌ព្រហ្មទណ្ឌ និងសិទ្ធិដែលផ្តល់ដល់កុមារទំនាស់នឹងច្បាប់ផងដែរ។

# វិធីសាស្ត្រ



## ផ្នែកទី១៖ ទិដ្ឋភាពទូទៅនៃនីតិវិធី យុត្តិធម៌ព្រហ្មទណ្ឌសម្រាប់ជនរងគ្រោះ នៃអំពើរំលោភបំពាន និងកេងប្រវ័ញ្ចផ្លូវភេទលើកុមារ

### មន្ត្រីអនុវត្តច្បាប់ និងអាជ្ញាធរមូលដ្ឋាន

**កុមាររងគ្រោះដោយអំពើរំលោភបំពាន និងកេងប្រវ័ញ្ចផ្លូវភេទនឹងទទួលបានការយកចិត្តទុកដាក់ពីមន្ត្រីអនុវត្តច្បាប់តាមវិធីជាច្រើន។ នៅពេលមានបទល្មើសកើតឡើង ជាធម្មតាមន្ត្រីអនុវត្តច្បាប់ទទួលបានការរាយការណ៍ពីកុមារ ឬគ្រួសារ ឬតាមរយៈការបញ្ជូនរបស់សមាជិកក្រុមប្រឹក្សាទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ/សង្កាត់ ឬអាជ្ញាធរមូលដ្ឋាន ឬអង្គការក្រៅរដ្ឋាភិបាលផ្សេងទៀត។**

ម៉្យាងទៀតគឺក្នុងអំឡុងពេលស៊ើបអង្កេតរបស់នគរបាលដែលភស្តុតាងនៃការរំលោភបំពានលេចឡើង។ នៅពេលទទួលបានពាក្យបណ្តឹងនៅឯប៉ុស្តិ៍នគរបាល មន្ត្រីនគរបាលម្នាក់នឹងសម្ភាសកុមារ និងឪពុក/ម្តាយ ហើយបន្ទាប់មករាយការណ៍ទៅព្រះរាជអាជ្ញាដើម្បីទទួលបានការយល់ព្រមដើម្បីធ្វើការកោះហៅជនសង្ស័យមកសាកសួរ និង/ឬធ្វើការចោទប្រកាន់។

ក្នុងករណីបន្ទាន់ នគរបាលពេលខ្លះសម្រេចឃុំខ្លួនជនសង្ស័យក្នុងរយៈពេលកំណត់តាមនីតិវិធី (រហូតដល់ ៧២ ម៉ោង) មុននឹងបញ្ជូនរឿងក្តី និងជនសង្ស័យទៅព្រះរាជអាជ្ញា។

ភាពខុសគ្នាតែមួយរវាងដំណើរការដែលត្រូវបានធ្វើឡើងសម្រាប់កុមារ គឺការប្រើប្រាស់វិធីសាស្ត្របែបកុមារមេត្រីអំឡុងពេលសម្ភាសន៍នៅក្នុងបន្ទប់សម្ភាសកុមារមេត្រី (ប្រសិនបើមាន) ហើយកុមារនឹងត្រូវអមដោយបុគ្គលិកសង្គម និង/ឬ ឪពុកម្តាយ អាណាព្យាបាលម្នាក់។

ការសម្របសម្រួលនីតិវិធីទៅតាមអាយុ និងកម្រិតនៃការអភិវឌ្ឍរបស់កុមារដើម្បីធានាថានីតិវិធីគឺកុមារមេត្រី គឺពិតជាចាំបាច់ និងមានសារៈសំខាន់ខ្លាំងណាស់ពេលសម្ភាសកុមារ។ វាមិនត្រឹមតែធានាអំពីការគោរពសិទ្ធិរបស់កុមារទេ ថែមទាំងមានផលជះវិជ្ជមានដល់កុមារក្នុងការបង្ហាញប្រាប់ និងភាពត្រឹមត្រូវនៃព័ត៌មានដែលកុមារប្រាប់ផងដែរ។ នីតិវិធីបែបកុមារមេត្រីគឺជាទស្សនៈថ្មីមួយនៅក្នុងប្រទេសកម្ពុជាដែលទើបមានភាពប្រសើរឡើងបានមួយទសវត្សរ៍ចុងក្រោយនេះប៉ុណ្ណោះ ដោយបានបញ្ចូលទៅក្នុងនីតិវិធីយុត្តិធម៌ព្រហ្មទណ្ឌ។

អ្នកជំនាញធ្វើការសហការជាមួយនគរបាលរាយការណ៍ថា ឥរិយាបថ និងនីតិវិធីរបស់នគរបាលថ្នាក់ជាតិ និងខេត្តមានភាពប្រសើរឡើង បើប្រៀបធៀបទៅនឹងឆ្នាំថ្មីៗកន្លងទៅ ជាពិសេសទាក់ទងទៅនឹងការយល់ដឹងកាន់តែប្រសើរអំពីសារៈសំខាន់នៃការសម្ភាសបែបកុមារមេត្រី និងអំពីការអនុញ្ញាតឱ្យមានវត្តមានបុគ្គលិកសង្គម[38] ដើម្បីសម្រួលអារម្មណ៍ និងធានានូវការគោរពសិទ្ធិកុមារក្នុងពេលសម្ភាសៈ

"ករណីភាគច្រើន នៅពេលដែលបុគ្គលិកសង្គមកិច្ចមិនបានចូលរួមសម្ភាសពួកគេ (នគរបាល) មិនបានបង្ហាញការគោរពច្រើនទេ។ វាបានកើតឡើងកាលពីមុន ប៉ុន្តែឥលូវនេះពួកគេយល់ដឹងកាន់តែច្រើនអំពីនីតិវិធីបែបកុមារមេត្រី។ មកដល់ពេលនេះ ទោះបីគ្មានការស្នើសុំក៏ដោយ ក៏នគរបាលអំពាវនាវឱ្យមានការចូលរួមរបស់យើងដែរ។ ពួកគេបានផ្លាស់ប្តូរហើយ។ កាលពីមុនពួកគេមិនអនុញ្ញាតឱ្យ (បុគ្គលិកសង្គមកិច្ចចូលរួម) ជាមួយភារកិច្ចរបស់ពួកគេ ឬបើគ្មានភារកិច្ចឡើយ"។







"ខ្ញុំអាចមើលឃើញនូវកិច្ចសហការល្អរវាងនគរបាល និងមន្ត្រីសង្គមកិច្ចមកពីមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ទោះបីជាពួកគេរវល់ (ខ្លាំង) មិនអាចទាក់ទងគ្នាបាន (ដោយសារ) ទំនួលខុសត្រូវរបស់ពួកគេក៏ដោយ។ ប៉ុន្តែនៅពេលមានករណីកើតឡើង ពួកគេព្យាយាមមករួមគ្នា និងទៅរួមគ្នាដើម្បីចូលរួមក្នុងដំណើរការសម្ភាសជាពិសេសការសម្ភាសកុមារដែលគ្មានអាណាព្យាបាល"។

"ត្រង់ចំណុចនេះ យើងឃើញថាកុមារបាត់បង់អត្ថប្រយោជន៍ពីព្រោះពេលខ្លះបុគ្គលិកសង្គមកិច្ចមិនទាន់បានចូលរួមស៊ើបម្រាវនៅឡើយទេ។ តែពេលនេះ ពួកគេ (នគរបាល) ព្យាយាមធ្វើឱ្យ (បុគ្គលិកសង្គមកិច្ច) ចូលរួមឱ្យបានច្រើន"។




ការប្រតិបត្តិបែបនេះគឺឆ្លើយតបនឹងស្តង់ដារដែលបានកំណត់ក្នុងគោលការណ៍ណែនាំស្តីពី “ទម្រង់ និងនីតិវិធីសំរាប់ការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្សសំរាប់ការផ្តល់សេវាសមស្រប” ដែលគោលការណ៍នេះរៀបរាប់ថា “ប្រសិនបើជនរងគ្រោះជាអនីតិជន នីតិវិធីបែបកុមារមេត្រីគួរត្រូវបានអនុវត្ត ដោយមានការចូលរួម ឬវត្តមានរបស់ឪពុកម្តាយ អាណាព្យាបាល ឬមន្ត្រីដែលមានកាតព្វកិច្ចផ្លូវច្បាប់ ឬមនុស្សពេញវ័យដែលកុមារមានការទុកចិត្ត ដែលអ្នកទាំងនោះអាចបង្កបរិយាកាសមានផាសុខាភាព ប៉ុន្តែការឱ្យមានវត្តមានរបស់ជនសង្ស័យគឺគប្បីដាច់ខាតមិនមាន[39]។

---

38 RGC (2016) “Guidelines on the Forms and Procedures for Identification of Victims of Human Trafficking for Appropriate Service Provision” 17 http://un-act.org/wp-content/uploads/2016/08/ID_Guidelines_Cambodia.pdf

39 RGC

ភាពប្រសើរឡើងនេះភាគច្រើនបានមកពីការបណ្តុះបណ្តាល និងការកសាងសមត្ថភាពដែលមន្ត្រីនគរបាលទទួលបានស្តីពីនីតិវិធីបែបកុមារមេត្រី និងការគោរពសិទ្ធិកុមារដែលរៀបចំ និងគាំទ្រដោយអង្គការមិនមែនរដ្ឋាភិបាលជាច្រើន។ លើសពីនេះទៅទៀត នៅក្នុងផែនការជាតិរបស់រដ្ឋាភិបាលនាពេលថ្មីៗនេះ បានដាក់នូវនីតិវិធីបែបកុមារមេត្រីក្នុងរបៀបវារៈរបស់ពួកខ្លួន ដោយពង្រឹង និងបង្កើនការយល់ដឹងរបស់មន្ត្រីអនុវត្តច្បាប់អំពីសារៈសំខាន់នៃ និងពិចារណាអំពីការអនុវត្តនីតិវិធីបែបកុមារមេត្រីក្នុងការងាររបស់ពួកគេ។

ទោះបីជាមានភាពប្រសើរទាំងនេះក៏ដោយ ក៏ព័ត៌មានទទួលបានពីកុមារ និងអ្នកធ្វើការពាក់ព័ន្ធផ្សេងទៀតបង្ហាញថានីតិវិធីបែបកុមារមេត្រីនៅតែមិនត្រូវបានអនុវត្តជានិច្ចជាកាល ពិសេសក្នុងចំណោមមន្ត្រីនគរបាលស្រុក និងឃុំ។ នគរបាលថ្នាក់ស្រុក និងថ្នាក់ឃុំទទួលបានការផ្តោតយកចិត្តទុកដាក់ និងថវិកាតិចតួចសំរាប់ការបណ្តុះបណ្តាល និងការកសាងសមត្ថភាព ហើយភាពខុសគ្នាយ៉ាងខ្លាំងរវាងនគរបាលជាតិ និងនគរបាលខេត្តទៅនឹងនគរបាលស្រុក និងឃុំមានលក្ខណៈគួរឱ្យកត់សម្គាល់ផងដែរ។ នៅថ្នាក់ឃុំនៅតែខ្វះការយល់ដឹងអំពីនីតិវិធីបែបកុមារមេត្រី និងជាញឹកញយពួកគាត់ផ្តោតលើការផ្តន្ទាទោសជនល្មើសជាជាងផ្តល់អាទិភាពដល់ឧត្តមប្រយោជន៍របស់កុមារ។ ក្នុងគោលបំណងផ្ទៀងផ្ទាត់ព័ត៌មានលម្អិត អ្នកផ្តល់ព័ត៌មានម្នាក់បានរៀបរាប់ថា នគរបាលហៅជនសង្ស័យចូលទៅក្នុងបន្ទប់ហើយនៅចំពោះមុខកុមារ សួរជនសង្ស័យនូវសំណួរមួយចំនួនដូចជា “តើរឿងនេះពិតជាកើតឡើងមែនទេ ?” បុគ្គលិកសង្គមម្នាក់ទៀតមកពីអង្គការក្រៅរដ្ឋាភិបាលក៏បានបញ្ជាក់ ដែរថា៖

"ខ្ញុំធ្លាប់ធ្វើការយ៉ាងជិតស្និទ្ធជាមួយនគរបាល ដូចជាក្នុងករណីអំពើហិង្សាក្នុងគ្រួសារ ពួកគេចាត់វិធានការតែក្នុងករណីដែលមានស្ថានភាពធ្ងន់ធ្ងរប៉ុណ្ណោះ។ ខ្ញុំធ្លាប់ជម្រុញ និងពិភាក្សាជាមួយពួកគាត់ ប៉ុន្តែគ្មានអ្វីផ្លាស់ប្តូរទេ។ ក្នុងករណីរំលោភបំពានផ្លូវភេទ នគរបាលថ្នាក់ឃុំមិនហ៊ានធ្វើសកម្មភាពទេ ដូច្នេះករណីទាំងនោះត្រូវបានបញ្ជូនទៅការិយាល័យនៃស្នងការដ្ឋាននគរបាលខេត្ត។ ការិយាល័យនៃស្នងការដ្ឋានខេត្តយកចិត្តទុកដាក់ជាងលើករណីបែបនេះ ដូចជាការគោរពសិទ្ធិកុមារ-សិទ្ធិទទួលបានព័ត៌មាន និងការមិនប្រើពាក្យមិនសមរម្យ ហើយបន្ទប់របស់ពួកគេមានលក្ខណៈបែបកុមារមេត្រី... ប៉ុន្តែនៅពេលដែលខ្ញុំចូលរួមការសម្ភាសជាមួយនគរបាលថ្នាក់ឃុំ (ប៉ុស្តិ៍រដ្ឋបាល) គាត់បានសួរសំណួរដោយមិនរៀបចំកុមារជាមុនសិនទេ។ វាមើលទៅដូចជាការសួរចម្លើយ។ ខ្ញុំបានកត់សម្គាល់ថានៅពេលនោះកុមារភ័យខ្លាច និងនិយាយដោយភ័យញាប់ញ័រ"។



បុគ្គលិកសង្គមកិច្ច
អង្គការក្រៅរដ្ឋាភិបាល- S2

មន្ត្រីនគរបាលជាច្រើនកាន់តំណែងរបស់ពួកគេអស់រយៈពេលជាច្រើនឆ្នាំ ហើយការជ្រើសរើសមន្ត្រីថ្មីនៅមានកំរិតតិចតួចនៅក្នុងនាយកដ្ឋានឬការិយាល័យរបស់ពួកគេ។ អ្នកផ្តល់ព័ត៌មានខ្លះបានអះអាងថាកត្តានេះមានផលប៉ះពាល់ដល់ទឹកចិត្ត និងការបង្កើតថ្មីៗ ព្រមទាំងមានការលំបាកក្នុងការផ្លាស់ប្តូរទម្លាប់ការងារចាស់។ ជារឿយៗនៅពេលដែលមានករណីរំលោភបំពាន ការផ្តោតសំខាន់នៃប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌគឺផ្តោតលើការស្វែងរកជនល្មើសជាជាងការគាំទ្រជនរងគ្រោះ៖




"នៅក្នុងដំណាក់កាលស៊ើបអង្កេត ជាទូទៅមន្រ្តីនគរបាលតែងតែការពារអ្វីដែលពួកគេបានរកឃើញជាជាងអ្វីដែលកុមារនិយាយ ហើយបន្ទាប់មកព្យាយាមធ្វើឱ្យស៊ីគ្នាជាមួយអ្វីដែលពួកគេបានរកឃើញ។ កត្តានេះរារាំងកុមារពីការអនុវត្តសិទ្ធិរបស់ពួកគេក្នុងការនិយាយ"។

បញ្ហាប្រឈមជាក់លាក់ត្រូវបានលើកឡើងទាក់ទងនឹងកុមាមានពិការភាព ជាពិសេសកុមារដែលមានបញ្ហាខ្សោយខាងទំនាក់ទំនង។ នគរបាលមិនត្រូវបានបណ្តុះបណ្តាលពេញលេញក្នុងប្រាស្រ័យទាក់ទងជាមួយកុមារដែលត្រូវការជំនួយពិសេសបែបនេះទេ ហើយពួកគេកម្រនឹងសហការជាមួយអ្នកឯកទេសសម្រាប់បញ្ហានេះណាស់។ មន្រ្តីនគរបាលម្នាក់បានបញ្ជាក់ថាក្នុងករណីបែបនេះ វាពិតជាលំបាកសម្រាប់ពួកគេក្នុងការទទួលបានព័ត៌មានត្រឹមត្រូវ ដូច្នេះពួកគេត្រូវសម្ភាសច្រើនដងដើម្បីបញ្ជាក់ឱ្យច្បាស់ ពេលខ្លះពួកគេនឹងស្នើសុំឱ្យកុមារគូសអ្វីដែលបានកើតឡើង ឬស្នើសុំឱ្យកុមារនាំពួកគេទៅទីតាំងនៃការរំលោភបំពាន និងឱ្យកុមារចង្អុលបង្ហាញពីអ្វីដែលបានកើតឡើង។ ការសិក្សាសកលបានបង្ហាញថាកុមារដែលមានពិការភាពក្នុងប្រភេទណាមួយអាចងាយរងគ្រោះពីគ្រប់ទម្រង់នៃការរំលោភបំពាន ហើយពួកគេ និងគ្រួសារប្រឈមនឹងការរាំងស្ទះក្នុងការទទួលបានសេវា និងយន្តការគាំទ្រកុមារនានា[40]។ កម្រិតនៃបទពិសោធន៍ធ្វើការជាមួយកុមារដែលមានពិការភាព និងកង្វះជំនាញ និងវិធីសាស្រ្តក្នុងការទទួលបានព័ត៌មានជាក់លាក់ និងត្រឹមត្រូវ ជាពិសេសក្នុងករណីដែលមានតម្រូវការពិសេស អាចបង្កើនហានិភ័យនៃការរងគ្រោះឡើងវិញ ឬការប៉ះទង្គិចផ្លូវចិត្តឡើងវិញ។

បច្ចុប្បន្នពុំមានគោលការណ៍ណែនាំច្បាស់លាស់ពីរាជរដ្ឋាភិបាលស្តីពីទីតាំងដែលកុមារគួរត្រូវសម្ភាសដោយនគរបាលឡើយ។ បើគ្មានគោលការណ៍ណែនាំច្បាស់លាស់ទេ នគរបាលអាចសម្រេចចិត្តសម្ភាសកុមារនៅកន្លែងណាដែលងាយស្រួលបំផុតសម្រាប់ពួកគេជាជាងកន្លែងដែលនឹងស័ក្តិសមល្អបំផុតសម្រាប់កុមារ។ ពេលខ្លះនគរបាលអញ្ជើញកុមារទៅប៉ុស្តិ៍នគរបាល ប៉ុន្តែនឹងសម្ភាសកុមារនៅក្នុងបន្ទប់ដែលមិនត្រូវបានរៀបចំឡើងសម្រាប់គោលបំណងសម្ភាសន៍នេះទេ។ កុមារម្នាក់បានចែករំលែកបទពិសោធន៍របស់គាត់ដោយនិយាយថាគាត់ត្រូវបានគេហៅទៅប៉ុស្តិ៍នគរបាល ប៉ុន្តែត្រូវបានគេសម្ភាសនៅក្រោមដើមឈើមួយនៅខាងក្រៅការិយាល័យ ដោយមាននគរបាលពីរបីនាក់ផ្សេងទៀតដើរជុំវិញពេលនាងត្រូវបានគេសម្ភាស។ នាងបានបញ្ជាក់ថាក្រៅពីនាងទទួលរងឥទ្ធិពលពីវត្តមានរបស់មន្រ្តីផ្សេងទៀតដែលដើរជុំវិញ នាងមានអារម្មណ៍មិនស្រួលចិត្តដែលត្រូវនិយាយខ្លាំងៗនៅក្នុងកន្លែងបើកចំហអំពីអ្វីដែលបានកើតឡើងចំពោះនាង និងការព្រួយបារម្ភណ៍អំពីការស្តាប់ឮរឿងរ៉ាវរបស់នាង។ បទពិសោធន៍ផ្សេងទៀតរួមមានការសម្ភាសន៍ជាមួយមន្រ្តីនគរបាលដែលមិនពាក់ព័ន្ធផ្សេងទៀតនៅក្នុងបន្ទប់ ឬមានមនុស្សចេញចូលបន្ទប់ដែលរំខានដល់សមត្ថភាពក្នុងការនិយាយស្តីដោយសេរី។

ការសម្ភាសន៍នៅខាងក្រៅប៉ុស្តិ៍នគរបាលពេលខ្លះត្រូវបានគេមើលឃើញថាជាចំណុចវិជ្ជមាន ដោយអ្នកផ្តល់ព័ត៌មានមួយចំនួន និងកុមារមួយចំនួនផងដែរ ដោយសារតែការលើកឡើងថាពេលខ្លះកុមារខ្លាចមិនហ៊ានមកជួបនគរបាល ហើយប៉ុស្តិ៍នគរបាលបង្កើនកម្រិតនៃភាពតានតឹងដល់ពួកគេ។

40 GPCWD (2015) Literature Review http://www.gpcwd.org/uploads/2/6/0/9/26097656/gpcwdtask__force__child__protection__literature__review.pdf

ប៉ុន្តែការសម្ភាសនៅតាមទីតាំងសាធារណៈដូចជានៅហាងកាហ្វេ និងភោជនីយដ្ឋាន ឬនៅតាមទីតាំងផ្សេងៗនៅក្នុងសហគមន៍ពុំបានគិតគូរដល់ការរក្សាការសម្ងាត់របស់កុមារឡើយ ហើយអ្វីដែលជាផលប៉ះពាល់គឺថាតើកុមារនឹងមានអារម្មណ៍មិនស្រួលចិត្តក្នុងការរៀបរាប់រឿងលម្អិត។ ឧទាហរណ៍ កុមារម្នាក់ត្រូវបានគេសម្ភាសនៅឯការិយាល័យរបស់សាលារៀន ដែលគេកាន់តែភ័យខ្លាចថា អ្នកផ្សេងទៀតនៅសាលាអាចដឹងអំពីអ្វីដែលបានកើតឡើង។ ( សូមមើលប្រអប់ទី ២ សម្រាប់បទពិសោធន៍បន្ថែមទៀតជាមួយនគរបាលដូចដែលបានលើកឡើងដោយកុមារ ) ។

អង្គការសកម្មភាពដើម្បីកុមារ បាននិងកំពុងធ្វើការយ៉ាងជិតស្និទ្ធជាមួយនគរបាលហើយបានជួយពង្រឹងនិតិវិធីបែបកុមាមេត្រីដោយផ្តល់ការបណ្តុះបណ្តាលលើការស៊ើបអង្កេតបែបកុមារមេត្រី និងដោយបង្កើតបន្ទប់សម្ភាសន៍កុមារមេត្រីនៅក្នុងស្ថានីយ៍នគរបាលដើម្បីអនុញ្ញាតឱ្យមានកន្លែងសុវត្ថិភាព និងបែបកុមារមេត្រីសម្រាប់ធ្វើការសម្ភាស។ រហូតមកដល់ពេលនេះ មានបន្ទប់បន្ទប់សម្ភាសន៍កុមារមេត្រីចំនួន ៦ ត្រូវបានបង្កើតឡើងគឺ ២ នៅរាជធានីភ្នំពេញ មួយនៅខេត្តសៀមរាប មួយនៅខេត្តកណ្តាល មួយនៅខេត្តបាត់ដំបង និងមួយនៅខេត្តកំពត។ បន្ទប់មួយក្នុងចំណោមបន្ទប់ទាំង៦ត្រូវបានរៀបចំនៅមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទារាជធានីភ្នំពេញ ពេលដែលបន្ទប់ផ្សេងទៀតត្រូវបានរៀបចំ នៅប៉ុស្តិ៍នគរបាល។ បន្ទប់សម្ភាសន៍កុមារមេត្រីទទួលបានគាំទ្រជាវិជ្ជមានពីសំណាក់នគរបាល និងកុមារដែលត្រូវបានសម្ភាសនៅក្នុងបន្ទប់នោះ។ នគរបាលបានបញ្ជាក់ថាបរិយាកាសក្នុងបន្ទប់នោះដើរតួនាទីយ៉ាងសំខាន់លើអារម្មណ៍ដែលកុមារមាន និងឆន្ទៈរបស់កុមារក្នុងការបង្ហាញព័ត៌មានលម្អិតទាក់ទងនឹងការរំលោភបំពាន ។

បន្ទប់សម្ភាសន៍កុមារមេត្រីត្រូវបានបំពាក់ដោយការតុបតែងបែបកុមារមេត្រី ប្រដាប់ប្រដាក្មេងលេង និងសម្ភារគំនូរ និងឧបករណ៍ថតសំឡេង និងវីដេអូ ដែលអនុញ្ញាតឱ្យការសម្ភាសន៍អាចត្រូវបានមើលឃើញនៅក្នុងបន្ទប់ក្បែរនោះ។

ប៉ុន្តែគេងគេសម្គាល់ថាបច្ចុប្បន្នពុំមានឧបករណ៍ និងសម្ភារគ្រប់គ្រាន់ដែលត្រូវការជាចាំបាច់ដើម្បីលើកទឹកចិត្តកុមារឱ្យនិយាយទេ។ មន្ត្រីនគរបាលមួយចំនួនតូចបានបញ្ជាក់ថាពេលខ្លះពួកគេឱ្យកុមារយកប្រដាប់ប្រដាលេងពីបន្ទប់ទៅផ្ទះ ហើយបន្ទាប់មកពួកគេបានស្នើសុំពីអង្គការមិនមែនរដ្ឋាភិបាលឱ្យជួយបំពាក់បន្ទប់នេះឡើងវិញបានដែរឬទេ។ ទោះយ៉ាងណា ប៉ុស្តិ៍នគរបាលភាគច្រើននៅតែមិនមានបន្ទប់សម្ភាសន៍កុមារមេត្រី និងជាពិសេសនៅថ្នាក់ឃុំ និងស្រុកត្រូវបានគេកត់សម្គាល់ថានគរបាលបានគិតគូរតិចតួចលើបរិយាកាសដែលកុមារត្រូវសម្ភាស។

នៅឆ្នាំ ២០១៩ រាជរដ្ឋាភិបាលកម្ពុជាបានប្រកាសដំឡើងប្រាក់ឈ្នួលអប្បបរមាសម្រាប់នគរបាល ដែលមានសុពលភាពចាប់ពីឆ្នាំ២០២០[41] ។ ទោះបីនេះគឺជាការវិវឌ្ឍដ៏ប្រសើរ ក៏នៅតែមានការលើកឡើងពីការព្រួយបារម្ភណ៍អំពីកង្វះថវិកាដែលប៉ះពាល់ដោយផ្ទាល់ដល់នីតិវិធីនៃការស៊ើបអង្កេត។ នគរបាលមិនទទួលបានថវិការដោយឡែកសំរាប់ការធ្វើដំណើរក្នុងនីតិវិធីស៊ើបអង្កេតនៅកន្លែងកើតហេតុនោះទេ ចំណាយពាក់ព័ន្ធនឹងនីតិវិធីតុលាការជាក់លាក់ ឬអាហារ ជាឧទាហរណ៍ គឺនគរបាលប្រើប្រាស់ថវិកាពីប្រាក់ខែរបស់ពួកគេ បើទោះបីចំណាយទាំងនេះទាក់ទងនឹងចំណាយប្រតិបត្តិការក៏ដោយ។ នគរបាលមួយចំនួនបានលើកបញ្ហានេះជាការប្រឈមដែលរាំងស្ទះដល់សមត្ថភាពក្នុងការឆ្លើយតបឱ្យមានប្រសិទ្ធភាព និងបង្កើនការពឹងផ្អែករបស់ពួកគេលើការគាំទ្រពីសំណាក់អង្គការសង្គមស៊ីវិល។

កង្វះថវិកា និងប្រាក់ខែសមរម្យដើម្បីបំពេញនីតិវិធីមូលដ្ឋាន បង្កើនហានិភ័យដល់ការអនុវត្តដែលអាចពាក់ព័ន្ធនឹងអំពើពុករលួយ ឬការស្នើឱ្យមានការបង់ប្រាក់ដែលមិនតម្រូវឱ្យមាននៅក្នុងនីតិវិធី។ កុមារនិងក្រុមគ្រួសារមួយចំនួនបញ្ជាក់ថាពេលខ្លះមន្ត្រីអនុវត្តច្បាប់បានស្នើសុំឱ្យបង់ប្រាក់ក្រៅផ្លូវការដើម្បីបំពេញកិច្ចការ ឬពន្លឿននីតិវិធី [42,43,44]។

---

41 The increase in wages were from $296 to $314 for National Police officers holding ranks of staff sergeant, from $264 to $295 for military police officers holding ranks of first sergeant; and an increase to $167 for contractual officer's wages. Khy, S, Khmer Times press release "Wages Set to Increase for Civil Servants" October 28, 2019 https://www.khmertimeskh.com/654902/wages-set-to-increase-for-civil-servants/

42 Reports from APLE Beneficiaries

43 Reimer, J.K.(2015). A SYSTEM JUST FOR CHILDREN: Voices of child victims and witnesses about their experiences in the Cambodian Criminal Justice System. Hagar, Phnom Penh, Cambodia. https://hagarinternational.org/wp-content/uploads/2018/04/Hagar-Research-A-System-Just-for-Children.pdf

44 Amnesty International (2010) " Breaking the Silence - Sexual Violence in Cambodia" https://www.justice.gov/eoir/page/file/1051061/download

ការស្នើទាំងនេះ គួបផ្សំនឹងការមិនមានទំនុកចិត្តលើប្រព័ន្ធយុត្តិធម៌ គឺជាកត្តាដែលប៉ះពាល់ដល់ការជ្រើសរើសរបស់កុមារ និងក្រុមគ្រួសារមិនចូលរួមក្នុងនីតិវិធីយុត្តិធម៌ព្រហ្មទណ្ឌ និងធ្វើឱ្យពួកគេសម្រេចដោះស្រាយក្រៅប្រព័ន្ធតុលាការ។ មានការព្រួយបារម្ភណ៍លើកឡើងពាក់ព័ន្ធនឹងមន្ត្រីអនុវត្តច្បាប់ និងអាជ្ញាធរមូលដ្ឋានថាគេកត់សម្គាល់ថាពួកគាត់ជាអ្នកជម្រុញការអនុវត្តបែបនេះនៅពេលដែលករណីទាំងនោះមិនត្រូវបានចាត់ទុកជារឿងធ្ងន់ធ្ងរ ហើយជំរុញទឹកចិត្តឱ្យឪពុកម្តាយ និងអ្នកថែទាំជនរងគ្រោះសម្រេចដោះស្រាយជាមួយជនសង្ស័យតាមរយៈដំណើរការសម្រុះសម្រួលជាជាងការយកជនល្មើសទៅតុលាការ [45,46]។ ជាមួយនឹងការដោះស្រាយក្រៅប្រព័ន្ធតុលាការ កុមារត្រូវបានទុកឱ្យងាយរងគ្រោះ ខណៈដែលត្រូវបានគេគិតគូរតិចតួចលើតម្រូវការបន្ទាប់ពីរងគ្រោះរួចហើយកុមាររងគ្រោះអាចនឹងមិនត្រូវបានបញ្ជូនទៅសេវាសុខភាព ឬការគាំទ្រផ្នែកចិត្តសង្គម និងជនសង្ស័យអាចរួចផុតពីការទទួលខុសត្រូវតាមផ្លូវច្បាប់ និងអាចបន្តយាយីកុមារផ្សេងទៀត។

"យើងមានករណីមួយ...តាមពិតវាជាករណីរំលោភបំពានផ្លូវភេទ ម្តាយមានអាយុត្រឹមតែ ១៧ ឆ្នាំហើយម្តាយត្រូវបានបង្ខំរួចរងការរំលោភបំពានផ្លូវភេទដោយបុរសម្នាក់ដែលជាអ្នកជិតខាង។ នាងបានក្លាយជាម្តាយម្នាក់មានកូន តែរឿងរំលោភបំពានផ្លូវភេទត្រូវបានដោះស្រាដោយអាជ្ញាធរមូលដ្ឋានដោយ មិនឆ្លងតាមនីតិវិធីច្បាប់...នាងទទួលបានប្រាក់ពីអ្នករំលោភបំពានហើយបញ្ចប់ (បិទករណីនេះ)។ តែពេលនេះអ្វីដែលនាងត្អូញត្អែរគឺនាងមានកូន ហើយនាងនៅក្មេងណាស់ ទើបតែមានអាយុ១៧ឆ្នាំប៉ុណ្ណោះ ហើយនាងត្រូវការអ្នកណាម្នាក់ជួយទំនុកបម្រុងនាងក្នុងការចិញ្ចឹមបីបាច់កូន។ ដូច្នេះយើងគ្រាន់តែជូនដំណឹងដល់មន្ទីរសង្គមកិច្ចអតីតយុទ្ធជន និងយុវនីតិសម្បទាឱ្យជួយ ព្រោះ យើងដឹងថារឿងនេះត្រូវបានដោះស្រាយដោយអាជ្ញាធរមូលដ្ឋាន ដោយមេឃុំ និងនគរបាលក្នុងមូលដ្ឋាន ហើយមិនត្រូវបានដោះស្រាយតាមនីតិវិធីច្បាប់ទេ។ ម្តាយ និងកូនពិតជាត្រូវការជំនួយព្រោះគ្រួសាររបស់គាត់មិនមែនជាអ្នកមានជីវភាពធូរធាទេ ពួកគេក្រីក្រណាស់ ពួកគេមិនមានប្រាក់គ្រប់គ្រាន់ដើម្បីចិញ្ចឹមបីបាច់កូនទេ។ ពួកគេ (អាជ្ញាធរមូលដ្ឋាន) ត្រូវគិតអំពីបញ្ហានេះ និងមិនត្រូវព្រងើយនឹងបញ្ហានេះទេ" ។







"កុមារខ្លាចនគរបាល។ ពួកគេខ្លាចសូម្បីតែពាក្យ “នគរបាល” ។ ពួកគេអាចកំណត់ខ្លួនឯងថាជាជនរងគ្រោះប៉ុន្តែក្នុងពេលដំណាលគ្នា ពួកគេខ្លាចនគរបាលដាក់គុកពួកគេ។ លើសពីនេះទៅទៀត ពួកគេមិនទុកចិត្តនគរបាលទេ។ ដូចដែលអ្នកបានដឹងស្រាប់ហើយ នគរបាលភាគច្រើនព្យាយាមសម្របសម្រួលជាមួយឪពុកម្តាយហើយបិទរឿងក្តី"។

45 UNICEF EAPRO (2020) “Ending Violence Against Women and Children in Cambodia: Opportunities and Challenges for Collaborative and Integrative Approaches https://reliefweb.int/sites/reliefweb.int/files/resources/ending__violence__against__women__and__children__in__cambodia__-__report.pdf

46 World Vision International (2017) Protecting Cambodia’s Children? The Role of Commune Committees for Women and Children and Informal Community-based Child Protection Mechanisms in Cambodia https://www.wvi.org/sites/default/files/CCWC-Functionality-for-CP-Full-Report-EN.pdf

ការដោះស្រាយក្រៅប្រព័ន្ធតុលាការ និងក្នុងដំណើរការសម្រុះសម្រួលជាពិសេស មិនគួរត្រូវបានលើកទឹកចិត្តឡើយក្នុងករណីដែលពាក់ព័ន្ធនឹងការរំលោភបំពាន និងកេងប្រវ័ញ្ចផ្លូវភេទលើកុមារ ដោយសារការដោះស្រាយ និងដំណើរការសម្រុះសម្រួលបែបនេះកាន់តែរំលោភបំពានសិទ្ធិកុមារបន្ថែមទៀតដោយខកខានមិនបានកំណត់ និងឆ្លើយតបឱ្យបានសមស្របចំពោះផលប៉ះពាល់ជាអវិជ្ជមានចំពោះកុមាររងគ្រោះ ការអនុវត្តបែបរើសអើង ដែលបន្តឱ្យមានហានិភ័យដល់ជនរងគ្រោះ និងបន្តឱ្យជនល្មើសទទួលបាននូវវប្បធម៌និទណ្ឌភាព ដែលជនល្មើសមិនទទួលខុសត្រូវចំពោះមុខច្បាប់ចំពោះបទល្មើសដែលគេបានប្រព្រឹត្ត។

## ប្រអប់ ២. បទពិសោធន៍របស់កុមារជាមួយនគរបាល

កុមារមិនត្រូវបានជូនដំណឹងអំពីមូលហេតុនៃការកោះហៅទៅប៉ុស្តិ៍នគរបាលទេ។ ការនេះធ្វើឱ្យមានការភ័យខ្លាចថាពួកគេបានធ្វើអ្វីខុស។ កុមារខ្លះបាននិយាយថានៅពេលដែលពួកគេត្រូវបានអញ្ជើញឱ្យទៅប៉ុស្តិ៍នគរបាល នគរបាលមិនបានស្លៀកពាក់ឯកសណ្ឋានដែលបង្កឱ្យមានការបារម្ភណ៍និងភ័យខ្លាច ដោយមិនដឹងថាពួកគេពិតជានគរបាលមែនដែរឬទេ ហើយគិតថាពួកគេអាចនាំឱ្យខ្លួនមានគ្រោះថ្នាក់។ ទោះយ៉ាងណាក៏ដោយ មានកុមារខ្លះ បានបញ្ជាក់ថាខ្លួនមានការពេញចិត្តពេលនគរបាលមិនពាក់ឯកសណ្ឋាន ព្រោះវាកាត់បន្ថយការបាក់ស្បាត និងធ្វើឱ្យខ្លួនអាចនិយាយ និងបរិយាយដោយមិនមានការភិតភ័យ ។

ឥរិយាបថ និងអាកប្បកិរិយារបស់នគរបាលចំពោះកុមារមានការប្រែប្រួល ។ កុមារខ្លះយល់ថានគរបាលបានសម្តែងការគោរព និងប្រើសំនួរខ្លីៗច្បាស់ៗដែលងាយឆ្លើយ។ កុមារម្នាក់បាននិយាយថានគរបាលបានព្យាយាមធ្វើឱ្យខ្លួនមានផាសុខភាពតាមរយៈការផ្តល់ទឹកឱ្យនៅពេលគេមានអារម្មណ៍ស្រេកទឹក។ ប៉ុន្តែបទពិសោធន៍ផ្សេងទៀតរួមមាននគរបាលស្រែកដាក់កុមារឱ្យផ្តល់ចម្លើយ ការសួរសំណួរដដែលៗម្តងហើយម្តងទៀត ឬមានអារម្មណ៍ថាគំរាមកំហែងឱ្យឆ្លើយ។ ក្មេងស្រីម្នាក់បាននិយាយថាមន្ត្រីនគរបាលបានឱ្យនាងនូវក្រដាសទទេមួយបន្ទាប់ពីការសម្ភាសន៍ហើយបានសុំឱ្យនាងចុះហត្ថលេខា និងផ្តិតមេដៃដោយនិយាយថាកំណត់ហេតុដែលគាត់កត់គឺរញ៉េរញ៉ៃពេកដូច្នេះគាត់នឹងចម្លងសេចក្តីថ្លែងការណ៍របស់នាងនៅពេលក្រោយ។ នាងមិនសប្បាយចិត្តនឹងរឿងនោះព្រោះនាងខ្លាចនគរបាលអាចសរសេរអ្វីខុសពីអ្វីដែលនាងបានលើកឡើងបន្ទាប់ពីនាងបានចុះហត្ថលេខារួចហើយ។

មិនមានតុល្យភាពនៃចំនួននគរបាលភេទស្រី និងនគរបាលភេទប្រុសដែលធ្វើឱ្យការសម្ភាសភាគច្រើនត្រូវបានសម្ភាសដោយនគរបាលភេទប្រុសតែប៉ុណ្ណោះ។ កុមារភាគច្រើនចង់បាននគរបាលម្នាក់ដែលមានភេទដូចគ្នានឹងពួកគេ ប៉ុន្តែមិនសុទ្ធតែអាចមាននោះទេ។ កុមារីម្នាក់បានបញ្ជាក់ថាខ្លួនមានអារម្មណ៍ខ្មាសអៀនខ្លាំងណាស់ជាមួយនគរបាលបុរសហើយមិនអាចចែករំលែករឿងរ៉ាវរបស់នាងជាមួយគាត់បានទេ ដូច្នេះពួកគេបានហៅនគរបាលស្រីម្នាក់មកជំនួសគាត់។ ក្មេងប្រុសម្នាក់ត្រូវបានសម្ភាសដោយនគរបាលប្រុសម្នាក់ ប៉ុន្តែបាននិយាយថាបុគ្គលិកអង្គការដែលបានអមគាត់គឺជាមនុស្សស្រីដែលធ្វើឱ្យគាត់មានអារម្មណ៍ខ្មាសអៀន។

ឪពុក/ម្តាយ ឬអ្នកអាណាព្យាបាលមានវត្តមានស្ទើរគ្រប់ពេលនៅពេលនគរបាលធ្វើបទសម្ភាសន៍ ប៉ុន្តែកុមារខ្លះបាននិយាយថាពួកមិនចង់ឱ្យឪពុក/ម្តាយមានវត្តមាននោះទេ ព្រោះវាធ្វើឱ្យពួកគេខ្មាសអៀននៅពេលនិយាយអំពីអ្វីដែលបានកើតឡើងចំពោះពួកគេនៅក្បែរឪពុក/ម្តាយ ឬអ្នកមើលថែរបស់គេ។

# ការពិនិត្យកោសលវិច្ច័យវេជ្ជសាស្ត្រ និងការព្យាបាលក្រោយពីការរំលោភបំពាន

**ការឆ្លើយតបទាន់ពេលវេលាសម្រាប់ការស្វែងរកការថែទាំវេជ្ជសាស្ត្របន្ទាប់ពីការរំលោភបំពានមានសារៈសំខាន់ណាស់ មិនត្រឹមតែដើម្បីធានាសុខភាពរាងកាយរបស់កុមារ ប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងដើម្បីទទួលបានភស្តុតាងមុនពេលវាបាត់ផងដែរ ដែលត្រូវការជាចាំបាច់នៅក្នុងដំណើរការតុលាការដើម្បីជួយដល់ការផ្តន្ទាទោសជាពិសេស ករណីរំលោភសេពសន្ថវៈ។ ជាទូទៅជនរងគ្រោះ និងគ្រួសារមិនបានដឹងថាភស្តុតាងកោសល្យវិច្ច័យត្រូវ ធ្វើឡើងក្នុងរយៈពេល២៤ម៉ោងបន្ទាប់ពីមានការរំលោភបំពានកើតឡើងនោះទេ និងមិនបានដឹងថាក្នុងករណីរំលោភសេពសន្ថវៈ ការព្យាបាលបន្ទាន់ប្រឆាំងនឹងមេរោគអេដស៍ ឬថ្នាំបង្ការការមានផ្ទៃពោះអាចត្រូវបានផ្តល់ឱ្យតែត្រូវផ្តល់ក្នុងរយៈពេល ៧២ ម៉ោងប៉ុណ្ណោះបន្ទាប់ពីការរំលោភបំពាន។**

នគរបាល និងគ្រូពេទ្យភាគច្រើនបាននិយាយថាកុមារ និងសមាជិកគ្រួសាររបស់ពួកគេជាច្រើនបានរាយការណ៍អំពីការរំលោភបំពាន ក្នុងរយៈពេលយូរ ពេលខ្លះច្រើនខែ ឬសូម្បីតែច្រើនឆ្នាំក្រោយពេលមានការរំលោភបំពានកើតឡើង។ កត្តានេះនឹងបង្កការប៉ះពាល់ដល់ការពិនិត្យកោសលវិច្ច័យវេជ្ជសាស្ត្រ និងការប្រមូលភស្តុតាងពីការពិនិត្យកោសលវិច្ច័យ ។

នគរបាល និងគ្រូពេទ្យភាគច្រើនបាននិយាយថាកុមារ និងសមាជិកគ្រួសាររបស់ពួកគេជាច្រើនបានរាយការណ៍អំពីការរំលោភបំពាន ក្នុងរយៈពេលយូរ ពេលខ្លះច្រើនខែ ឬសូម្បីតែច្រើនឆ្នាំក្រោយពេលមានការរំលោភបំពានកើតឡើង។

កត្តានេះនឹងបង្កការប៉ះពាល់ដល់ការពិនិត្យកោសលវិច្ច័យវេជ្ជសាស្ត្រ និងការប្រមូលភស្តុតាងពីការពិនិត្យកោសលវិច្ច័យ។

ការពិនិត្យកោសល្យវិច្ច័យ និងវិញ្ញាបនបត្រលទ្ធផលកោសល្យវិច្ច័យសម្រាប់ជនរងគ្រោះដោយសារអំពើហិង្សាផ្លូវភេទគឺឥតគិតថ្លៃទេបន្ទាប់ពីមានសេចក្តីប្រកាសរបស់ក្រសួងមហាផ្ទៃក្នុង ឆ្នាំ ២០០៩ ប៉ុន្តែទាំងអង្គការមិនមែនរដ្ឋាភិបាល និងជនរងគ្រោះ និងក្រុមគ្រួសារក៏ដូចជាអ្នកផ្តល់សេវាខ្លួនឯងមិនបានដឹងពីសិទ្ធិទាំងនេះអស់រយៈពេលជាច្រើនឆ្នាំបន្ទាប់ពីមានការប្រកាសជាលទ្ធផលជនរងគ្រោះភាគច្រើននៅតែត្រូវបានបង្គាប់ឱ្យបង់ប្រាក់សម្រាប់ការពិនិត្យរបស់ពួកគេ។ តែប៉ុន្មានឆ្នាំចុងក្រោយនេះគេបានឃើញនូវភាពប្រសើរឡើង ដោយសិទ្ធិកាន់តែលក្ខណៈប្រសើរក្នុងការទទួលបានព័ត៌មានអំពីការទទួលបានការពិនិត្យកោសលវិច្ច័យដោយមិនគិតកម្រៃចំពោះអ្នកដែលគ្រោះដោយអំពើរំលោភបំពាន និងកេងប្រវ័ញ្ច ។ ប្រសិនបើកុមារត្រូវការការព្យាបាលបន្ថែមទៀតដោយសារការរំលោភបំពាន ការព្យាបាលនឹងមិនត្រូវបានរ៉ាប់រងទូទាត់ឡើយ លើកលែងតែពួកគេមានបណ្ណក្រីក្រ[47]។

ចំពោះលទ្ធកោសល្យវិច្ច័យវេជ្ជសាស្ត្រអាចទទួលស្គាល់នៅក្នុងតុលាការ លុះត្រាតែការពិនិត្យនោះឡើងនៅតាមមន្ទីរពេទ្យបង្អែកខេត្តដែលមកដល់បច្ចុប្បន្នមាននៅគ្រប់ខេត្តទាំងអស់។ ការពិនិត្យកោសល្យវិច្ច័យវេជ្ជសាស្ត្រជាធម្មតាផ្តោតលើតែវិធីសាស្ត្រពិនិត្យតាមបែបប្រពៃណី ដូចជាថាតើសន្ធះព្រហ្មចារីយ៍នៅដដែល ឬមានការដាច់រហែក ដែលនេះជាវិធីសាស្ត្រដែលមិនអាចទទួលបានលទ្ធផលជាក់លាក់ក្នុងការបញ្ជាក់ថាកុមារបានរងការរំលោភបំពានផ្លូវភេទ ។ ការផ្តោតលើការដាច់រហែកសន្ធះព្រហ្មចារីយ៍ជាចន្លោះខ្វះខាតចំពោះការរំលោភបំពានផ្លូវភេទដែលមិនពាក់ព័ន្ធនឹងប្រដាប់ភេទ ជាពិសេសមិនគិតគូរដល់ការរំលោភបំពានដែលកើតឡើងលើក្មេងប្រុស។ កង្វះការបណ្តុះបណ្តាល និងចំណេះដឹងខាងវេជ្ជសាស្ត្រសមស្របក៏រារាំងដល់ការវិភាគលទ្ធផលទោះបីនៅពេលលទ្ធផលត្រូវបានបញ្ជាក់ក៏ដោយះ

47 The IDPoor program, is a poverty reduction intervention, established in 2006 that identifies poor households in order to ensure assistance is provided to them. IDPoor card holders receive access to different free of charge services and assistance including health, education, financial assistance and more. For more information https://mop.idpoor.gov.kh/




"យើងមានករណីខ្លះ ដូចជាក្មេងស្រីអាយុ ២ ឆ្នាំដែលត្រូវបាននាំមកទីនេះ ដោយសារតែការហូរទឹករំអិលតាមទ្វារមាស បន្ទាប់មកយើងបានធ្វើតេស្ត ដោយប្រើចង្កឹះសំឡី បន្ទាប់មកទៀតលទ្ធផលគឺរោគប្រមេះ។ នៅពេលដែលលទ្ធផលគឺជារោគប្រមេះ ពួកគេនឹងជូនដំណឹងដល់យើង យើងនឹងសម្របសម្រួលជាមួយម្តាយអំពីការពិនិត្យសុខភាព ផ្តល់កំណត់ត្រារំលោភបំពាន ផ្លូវភេទ ហើយបន្ទាប់មកថតរូប ប៉ុន្តែបន្ទាប់មកទៀតគ្រូពេទ្យ ឪពុក/ម្តាយ ឬនគរបាលនៅតែមិនគិតថានេះជាលទ្ធផលនៃទំនាក់ទំនងផ្លូវភេទ ពួកគេគិតថាវាទាក់ទងនឹងអនាម័យ និងមិនទាក់ទងនឹងការរំលោភបំពានផ្លូវភេទ"។

មន្ទីរពេទ្យបង្អែកភាគច្រើននៅមានការខ្វះខាតផ្នែកសម្ភារៈបច្ចេកទេសសម្រាប់ការពិនិត្យឱ្យបានពេញលេញ។ លើសពីនេះកង្វះខាតធនធានមនុស្ស និងសមត្ថភាពជំនាញ ក៏ដូចជាឧបករណ៍ទំនើបក៏ត្រូវបានកត់សម្គាល់ថាជាកត្តាប្រឈមដែរ។ ក្រុមគ្រូពេទ្យបានត្អូញត្អែរថាពួកគេមិនមានឧបករណ៍ និងមន្ទីរពិសោធន៍ធ្វើកោសល្យវិច្ច័យសមស្របដើម្បីប្រមូលភស្តុតាង និងធ្វើនីតិវិធីដូចជាការធ្វើតេស្ត DNA និងការយកសំណាកឡើយ។ មន្ត្រីក្រសួងសុខាភិបាលមួយរូបដែលទទួលបន្ទុកពិនិត្យកោសល្យវិច្ច័យនៅក្នុងប្រទេសបានបង្ហាញពីបញ្ហាប្រឈមនៅតាមមន្ទីរពេទ្យ នៅតាមខេត្តដាច់ស្រយាលដែលមានការខ្វះខាតឧបករណ៍វេជ្ជសាស្ត្រខ្លាំង ដែលសូម្បីតែសម្ភារផ្គត់ផ្គង់មូលដ្ឋាន ដូចជាផលិតផលអនាម័យដែលប្រើប្រាស់មួយដងដែលត្រូវការសម្រាប់នីតិវិធីក៏ខ្វះដែរ។ គាត់បានលើកឡើងពីបញ្ហានេះថាជាក្តីបារម្ភចម្បងព្រោះវាកាត់បន្ថយគុណភាពនៃការថែទាំក្នុងទំហំធំដែលអាចផ្តល់ឱ្យអ្នកជំងឺ និងកាត់បន្ថយសមត្ថភាពរបស់ពួកគេក្នុងការឆ្លើយតបនៅផ្នែកទាំងនោះដោយអះអាងថា ការដោះស្រាយឧបសគ្គនៅក្នុងមន្ទីរពេទ្យខេត្តគួរតែត្រូវបានផ្តល់អាទិភាព។

ក្នុងការខិតខំពង្រឹងការឆ្លើយតបដល់ជនរងគ្រោះពីសំណាក់អ្នកផ្តល់សេវាសុខភាព នៅឆ្នាំ ២០១៥ ក្រសួងសុខាភិបាលបានបោះពុម្ព និងផ្សព្វផ្សាយគោលការណ៍ណែនាំថ្នាក់ជាតិសម្រាប់ការគ្រប់គ្រងអំពើហិង្សាលើស្ត្រី និងកុមារនៅក្នុងវិស័យសុខាភិបាល។ គោលការណ៍ទាំងនេះបានផ្តល់ការណែនាំដល់មណ្ឌលថែទាំសុខភាព និងមន្ទីរពេទ្យបង្អែកទាក់ទងនឹងការបង្ការ និងការឆ្លើយតបចំពោះអំពើហិង្សាលើនឹងស្ត្រីនិងកុមារ។ ក្នុងឆ្នាំ ២០១៧ បន្ថែមលើគោលការណ៍ណែនាំទាំងនេះ សៀវភៅណែនាំស្តីពីការព្យាបាល និងថែទាំស្តីពី “ការថែទាំសុខភាពសម្រាប់កុមារ ដែលទទួលរងនូវអំពើហិង្សា ឬការរំលោភបំពានផ្លូវភេទ” ត្រូវបានបង្កើតឡើង ដើម្បីជួយលើកកម្ពស់ការឆ្លើយតបឱ្យបានគ្រប់គ្រាន់ចំពោះកុមាររងគ្រោះដោយអំពើហិង្សា ឬការរំលោភបំពានផ្លូវភេទពីសំណាក់គ្រូពេទ្យថែទាំសុខភាពទាំងអស់។ សៀវភៅណែនាំនេះផ្តល់ការណែនាំដល់ការគាំទ្របឋម ការផ្តល់សេវា សុខភាព ការផ្តល់សេវាគាំទ្រចិត្តសង្គម និងការបញ្ជូនទៅទទួលសេវាគាំទ្រផ្នែកសង្គម និងច្បាប់។ វគ្គបណ្តុះបណ្តាលស្តីពីគោលការណ៍ណែនាំ និងការប្រើប្រាស់សៀវភៅណែនាំនេះត្រូវបានរៀបចំឡើងដោយក្រសួងសុខាភិបាលដោយមានការគាំទ្រពីមូលនិធិអង្គការសហប្រជាជាតិដើម្បីកុមារដល់បុគ្គលិកសុខាភិបាលទូទាំងប្រទេស។

ការសម្ភាសបង្ហាញថា ក្រៅពីការយល់ដឹងអំពីតម្រូវការក្នុងការកសាងទំនាក់ទំនងជិតស្និទ្ធិជាមួយកុមារ ដើម្បីឱ្យពួកគេមានអារម្មណ៍ស្រួលចិត្តក្នុងអំឡុងពេលពិនិត្យ គ្រូពេទ្យមិនបានបង្ហាញពីការប្រើប្រាស់វិធីសាស្ត្របែបកុមារមេត្រី និងមិនធានាឱ្យបានថាកុមារត្រូវបានយកចិត្តទុកដាក់ និងសិទ្ធិរបស់ពួកគេត្រូវបានគោរពឡើយ។ បុគ្គលិកសង្គមកិច្ចម្នាក់បានបង្ហាញថាកុមារមួយចំនួន និងអ្នកផ្តល់សេវាគាំទ្របានត្អូញត្អែរចំពោះការព្យាបាលដែលកុមារទទួលបានក្នុងពេលពិនិត្យ៖

"មានការត្អូញត្អែរជាញឹកញាប់ពីសំណាក់កុមារ និងមនុស្សពេញវ័យថាអ្នកពិនិត្យកោសល្យវិច្ច័យប្រើពាក្យសម្តីមិនផ្តល់ការគោរព។ ទាក់ទងនឹងបញ្ហានេះ ខ្ញុំធ្លាប់ចូលរួមប្រជុំជាមួយក្រុមការងាររបស់ក្រសួងសុខាភិបាលហើយក្នុងអំឡុងពេលប្រជុំ អ្នកចូលរួមជាច្រើនបានលើកឡើងពីបញ្ហានេះ។ អ្វីដែលបុគ្គលិកសង្គមអាចធ្វើបាន គឺលើកជាមតិចូលរួមរបស់យើងនៅក្នុងកិច្ចប្រជុំជាមួយក្រសួងសុខាភិបាល ឬក្រសួងពាក់ព័ន្ធ"។




កង្វះខាតឧបករណ៍សមស្របសម្រាប់ការចងក្រងឯកសារភស្តុតាង ការយល់ដឹងនៅមានកម្រិតអំពីនីតិវិធី និងការបំពានសិទ្ធិកុមារតាមរយៈការសម្រុះសម្រួលពាក់ព័ន្ធនឹងលក្ខខណ្ឌនៃការរក្សាការសំងាត់ត្រូវបានបង្ហាញនៅក្នុងការសម្ភាសន៍ជាមួយគ្រូពេទ្យម្នាក់។ ក្នុងអំឡុងពេលបទសម្ភាសន៍ គាត់បានសារភាពថា គាត់បានថតរូបប្រដាប់ភេទរបស់កុមារអំឡុងពេលពិនិត្យដោយប្រើប្រាស់ទូរសព្ទផ្ទាល់ខ្លួនរបស់គាត់ និងរក្សាទុករូបភាពនៅក្នុងទូរសព្ទ ក្នុងករណីដែលគាត់ត្រូវការប្រើវាជាភស្តុតាងនៅក្នុងតុលាការ ដោយគាត់មិនទាំងផ្ទេររូបថតទៅទម្រង់រក្សាឯកសារសម្ងាត់នៅពេលបន្ទាប់ ឬក៏លុបរូបថតទាំងនោះចោលនៅពេលក្រោយឡើយ ដោយគាត់ពោលថា "គ្មាននរណាម្នាក់នឹងឃើញរូបថតទាំងនោះទេ"៖




"បន្ទាប់ពីបំពេញទម្រង់យល់ព្រម និងចុះហត្ថលេខារួចហើយ ខ្ញុំថតរូបស្នាមរបួសដោយប្រើទូរសព្ទផ្ទាល់ខ្លួនរបស់ខ្ញុំ។ ខ្ញុំធ្វើបែបនេះព្រោះខ្ញុំអាចពង្រីកមើលរបួសបាន។ ប៉ុន្តែខ្ញុំនឹងរក្សាវាជាការសម្ងាត់។ គ្មាននរណាម្នាក់ដឹងទេ មានតែខ្ញុំម្នាក់ប៉ុណ្ណោះ... ប្រសិនបើខ្ញុំមិនថតរូបទេ ខ្ញុំមិនមានភស្តុតាងដើម្បីការពារខ្លួនខ្ញុំនៅក្នុងតុលាការទេ...ខ្ញុំសូមប្រាប់អ្នក! គ្មាននរណាម្នាក់ ឬគ្មានច្បាប់ណាការពារខ្ញុំទេ។ ពេលខ្លះឪពុកម្តាយបានឃើញស្នាមប្រឡាក់ទឹកកាមលើកុមារ ប៉ុន្តែនៅពេលដែលខ្ញុំពិនិត្យខ្ញុំរកមិនឃើញទេ។ ដូច្នេះនៅក្នុងតុលាការ ខ្ញុំអាចបង្ហាញភស្តុតាង។ រាប់រយករណី... កុមារនឹងប្រាប់តុលាការថាពួកគេត្រូវបានគេចាប់រំលោភបែបនេះ បែបនោះ ប៉ុន្តែ (លទ្ធផល)នៃការធ្វើកោសល្យវិច្ច័យរបស់ខ្ញុំមិនបានបង្ហាញបែបនោះទេ ពុំមានការរំលោភទេ ដូច្នេះរូបថតដែលខ្ញុំបានថតនឹងបង្ហាញ"។

មណ្ឌលវេជ្ជសាស្ត្រឯកជន ឬអង្គការក្រៅរដ្ឋាភិបាលដែលផ្តល់ការថែទាំវេជ្ជសាស្ត្របន្ទាន់ជាធម្មតាមានកន្លែង និងឧបករណ៍ល្អប្រសើរជាងមន្ទីរពេទ្យបង្អែកខេត្ត ហើយបុគ្គលិកមានការបណ្តុះបណ្តាលល្អជាងអំពីនីតិវិធីបែបកុមារមេត្រី។ តែមជ្ឈមណ្ឌលវេជ្ជសាស្ត្រឯកជនមានតម្លៃថ្លៃ និងអ្នកក្រមិនអាចប្រើប្រាស់សេវានៅទីនោះបាន និងសូម្បីតែអង្គការក្រៅរដ្ឋាភិបាលដូចជាមន្ទីរពេទ្យកុមារអង្គរដែលផ្តល់ការថែទាំផ្នែកវេជ្ជសាស្ត្រដោយឥតគិតថ្លៃដល់កុមារ លទ្ធផលកោសល្យវិច្ច័យដែលពួកគេបានផ្តល់មិនត្រូវបានទទួលស្គាល់ជាផ្លូវការនៅក្នុងតុលាការទេ លទ្ធផលនឹងត្រូវបានចាត់ទុកជាភស្តុតាងគាំទ្រនៅក្នុងនីតិវិធីយុត្តិធម៌ព្រហ្មទណ្ឌតែប៉ុណ្ណោះ ប៉ុន្តែនឹងមិនអាចការពារកុមារពីការតម្រូវឱ្យធ្វើការពិនិត្យនៅមន្ទីរពេទ្យបង្អែកខេត្តឡើយ។

យោងទៅតាមបទញ្ញត្តិ សំណៅចម្លងលទ្ធផលពិនិត្យកោសល្យវិច្ច័យត្រូវបញ្ជូនទៅតុលាការដោយផ្ទាល់ ខណៈដែលឯកសារច្បាប់ដើមត្រូវបានរក្សាទុកនៅមន្ទីរពេទ្យ។ តែបទសម្ភាសន៍ជាមួយតួអង្គយុត្តិធម៌បានបង្ហាញថាការទទួលបានលទ្ធផលកោសល្យវិច្ច័យគឺជាបញ្ហាប្រឈមដ៏ធំបំផុតមួយរបស់ពួកគេដែលរំខានដល់នីតិវិធីរបស់តុលាការដោយសារតែលទ្ធផលជារឿយៗត្រូវបានទទួលយឺតយ៉ាវ ហើយទាមទារឱ្យមានការតាមដានជាច្រើនជាមួយមន្ទីរពេទ្យ។ អ្នកខ្លះបាននិយាយថាពេលខ្លះការជំនុំជម្រះបានចាប់ផ្តើមរួចទៅហើយ ពួកគេបានទទួលព័ត៌មានតែបន្ទាប់ពីចៅក្រមធ្វើការស្នើសុំជាផ្លូវការដោយផ្ទាល់ទៅមន្ទីរពេទ្យប៉ុណ្ណោះ។ ចៅក្រមម្នាក់បានរំលឹកពីករណីមួយចំនួននៅក្នុងតុលាការខេត្តដែលការជំនុំជម្រះបានចាប់ផ្តើម ដោយគ្មានលទ្ធផលកោសលវិច្ច័យវេជ្ជសាស្ត្រក្នុងករណីជនល្មើសបានសារភាពទទួលកំហុសរួចហើយ។

ការទទួលបានលទ្ធផលនៃការធ្វើកោសល្យវិច្ច័យវេជ្ជសាស្ត្រយឺតយ៉ាវ ត្រូវបានលើកឡើងថាជាហេតុផលចម្បងមួយដែលដំណើរការយុត្តិធម៌ព្រហ្មទណ្ឌមានរយៈពេលវែង និងដែលនីតិវិធីក្នុងតុលាការត្រូវបានពន្យារពេល។ នៅពេលមានកិច្ចសម្របសម្រួលលទ្ធផលកោសលវិច្ច័យអាចទទួលបានត្រឹមតែ២ ទៅ៣ថ្ងៃប៉ុណ្ណោះ ផ្ទុយទៅវិញបើសិនកិច្ចសម្របសម្រួលមានកំរិត នោះការទទួលបានលទ្ធផលកោសលវិច្ច័យអាចចំណាយពេលរហូតដល់ ៦ ទៅ៨ខែ។ បញ្ហាប្រឈមទាំងនេះត្រូវបានដាក់បន្ទុកលើកង្វះនីតិវិធីច្បាស់លាស់ កង្វះគោលការណ៍ណែនាំត្រឹមត្រូវទាក់ទងនឹងពេលវេលាដែលលទ្ធផលវេជ្ជសាស្ត្រត្រូវផ្តល់ជូន កង្វះភាពច្បាស់លាស់លើទំនួលខុសត្រូវរបស់ភាគីពាក់ព័ន្ធ កង្វះការប្តេជ្ញាចិត្តរបស់អ្នកដែលពាក់ព័ន្ធ ក៏ដូចជាបន្ទុកការងារច្រើនរបស់បុគ្គលិកពេទ្យ។ លើសពីនេះទៅទៀត មន្ទីរពេទ្យមិនប្រើវិធីទំនើបនិងបែបឌីជីថលក្នុងការថែរក្សាទិន្នន័យ និងព័ត៌មានរបស់អ្នកជំងឺទេដែលបង្កើនបញ្ហាប្រឈម និងធ្វើឱ្យដំណើរការនៃការទទួលបានព័ត៌មានកាន់តែវែង។

## ប្រអប់ទី ៣. បទពិសោធន៍របស់កុមារក្នុងអំឡុងពេលពិនិត្យកោសល្យវិច្ច័យវេជ្ជសាស្ត្រ

ជាធម្មតាកុមារត្រូវបានអមដំណើរទៅមន្ទីរពេទ្យដោយសមាជិកគ្រួសារម្នាក់ ឬមន្ត្រីនគរបាលម្នាក់ ។ កុមារបាននិយាយថាពួកគេត្រូវបានគេជូនដំណឹងមុនពេលពិនិត្យ ថាលទ្ធផលនឹងត្រូវប្រើសម្រាប់គោលបំណងអ្វី និងអ្នកណាអាចអមដំណើរពួកគេក្នុងពេលពិនិត្យ។ ពួកគេក៏ត្រូវបានជូនដំណឹងផងដែរថាលទ្ធផលរបស់ពួកគេនឹងរក្សាការសម្ងាត់។

បទពិសោធន៍ទាក់ទងនឹងឥរិយាបថ និងអាកប្បកិរិយារបស់បុគ្គលិកពេទ្យមានលក្ខណៈខុសៗគ្នា។ កុមារខ្លះបាននិយាយថាគ្រូពេទ្យរួសរាយរាក់ទាក់ និងកំប្លែង និយាយដោយការគោរព ហាក់ដូចជាមានវិជ្ជាជីវៈ ហើយគួរសមនឹងពួកគេ។ បទពិសោធន៍ផ្សេងទៀតរួមមាន គ្រូពេទ្យស្រែក និងនិយាយដោយគ្មានការគួរសម ហើយពួកគេបានបញ្ជាក់ថាពួកគេចង់ឱ្យបុគ្គលិកពេទ្យមានភាពរួសរាយរាក់ទាក់ និងមិនមានភាពលំអៀង ឬរើសអើងពួកគេដោយសារតែពួកគេជាជនរងគ្រោះដោយសារការរំលោភបំពាន។

កុមារខ្លះបានបង្ហាញពីការលំបាកក្នុងការទៅមន្ទីរពេទ្យព្រោះវានៅឆ្ងាយពីផ្ទះរបស់ពួកគេ។ មនុស្សមួយចំនួនតូចបាននិយាយថាបន្ទប់ពិនិត្យមិនស្អាត និងគ្មានអនាម័យ។ ខណៈពេលដែលការពិនិត្យមួយចំនួនត្រូវបានធ្វើឡើងដោយឯកជនដោយគ្មាននរណាម្នាក់ចូលបាន  ការពិនិត្យខ្លះមានការរំខានដោយសារបុគ្គលិកផ្សេងទៀតដែលដើរចូលចេញបន្ទប់។ ដោយគ្មានកន្លែងរង់ចាំឯកជន ក្មេងស្រីម្នាក់បានបញ្ជាក់ថានាងមានអារម្មណ៍មិនស្រួលចិត្តក្នុងការរង់ចាំនៅខាងក្រៅមុនពេលធ្វើការពិនិត្យនៅក្នុងបរិយាកាសដែលមានមនុស្សច្រើនដោយសារមនុស្សជាច្រើនអាចមើលឃើញនាង។

ភាគច្រើនបានពោលថាការពិនិត្យគឺរហ័ស និងគ្មានការឈឺចាប់ប៉ុន្តែបានលើកឡើងពីការលំបាកដោយត្រូវបានសួរសំណួរជាច្រើនមុនពេលធ្វើការពិនិត្យអំពីព័ត៌មានលម្អិតនៃការរំលោភបំពានរបស់ពួកគេ ដែលពិបាកសម្រាប់ពួកគេ។ កុមារម្នាក់មានការព្រួយបារម្ភដោយថាគ្រូពេទ្យ គឺជាមនុស្សប្រុសហើយខ្លាចគ្រូពេទ្យរំលោភបំពានពួកគេ។ កុមារភាគច្រើនចង់បានគ្រូពេទ្យភេទដូចគ្នានឹងពួកគេធ្វើការពិនិត្យពួកគេ តែពួកគេមិនត្រូវបានគេផ្តល់ជម្រើសឱ្យទេ ហើយត្រូវបានពិនិត្យដោយគ្រូពេទ្យភេទប្រុសប៉ុណ្ណោះ។

# ការគាំទ្រផ្នែកចិត្តសាស្ត្រសង្គម និងសេវាកម្មនានា

**ភស្តុតាងនៃការស្រាវជ្រាវបង្ហាញថាការផ្តល់ជម្រើស និងឱកាសសំរាប់កុមារក្នុងការទទួលបានការគាំទ្រផ្លូវចិត្តភ្លាមៗ រួមបញ្ចូលទាំងការវាយតម្លៃផ្នែកចិត្តសាស្ត្រសង្គមសមស្រប និងការបញ្ជូនទៅកាន់កន្លែងស្នាក់នៅបណ្តោះអាសន្ន នៅពេលមានតម្រូវការគឺជាតម្រូវការមួយដ៏ចាំបាច់ និងបន្ទាន់បំផុតសំរាប់កុមារបន្ទាប់ពីរងការរំលោភបំពាន[48] ។ ទោះជាយ៉ាងណា ភស្តុតាងនៅក្នុងការស្រាវជ្រាវនេះក៏បង្ហាញដែរថា នៅពេលករណីមួយត្រូវបានកសាងឡើង មន្ត្រីអនុវត្តច្បាប់ និងព្រះរាជអាជ្ញាជារឿយៗផ្តោតលើការប្រមូលភស្តុតាង និងការកត់ត្រាព័ត៌មានដែលអាចត្រូវបានប្រើប្រាស់បន្ថែមទៀតនៅក្នុងតុលាការ ដើម្បីផ្តន្ទាទោសជនល្មើស ខណៈសេចក្តីត្រូវការខាងចិត្តសាស្ត្រសង្គមត្រូវបានចាត់ទុកថាជាអាទិភាពទី២ បើទោះបីមានការណែនាំយ៉ាងណាក៏ដោយ [49]។**

វិធានដែលផ្តោតលើភាពជោគជ័យនៃប្រតិបត្តិការនេះ មិនផ្តល់អាទិភាពដល់អ្វីដែលជាឧត្តមប្រយោជន៍របស់កុមារឡើយ ហើយតម្រូវការសុខភាពរាងកាយ និងផ្លូវចិត្តរបស់ពួកគេអាចត្រូវបានមើលរំលងដែលអាចបង្កើនហានិភ័យ និងប៉ះពាល់អវិជ្ជមានក្នុងរយៈពេលវែង។

មានការខ្វះខាតខាងធនធានមនុស្ស ហើយជាពិសេសបុគ្គលិកសង្គមកិច្ច[50] នៅក្នុងប្រទេសដែលជះឥទ្ធិពលដល់កម្រិតនៃការថែទាំឯកទេស និងការបញ្ជូនទៅរកសេវាចិត្តសាស្ត្រដែលផ្តល់ដល់កុមារ។ ការព្យាបាល និងការគាំទ្រសុខភាពផ្លូវចិត្តផ្តល់ដោយរាជរដ្ឋាភិបាលនៅមិនទាន់ពេញលេញ ដែលភាគច្រើនផ្តោតដោយផ្ទាល់ទៅលើអន្តរាគមន៍វិបត្តិ និងការផ្តល់ប្រឹក្សាជាមូលដ្ឋាន ដោយមិនបានផ្តោតលើតម្រូវការរយៈពេលវែង។ លើសពីនេះទៅទៀត សេវាកម្មមានលក្ខខណៈទូទៅ និងកង្វះជំនាញជាក់លាក់ក្នុងករណីរំលោភបំពាន និងកេងប្រវ័ញ្ចផ្លូវភេទ។ លើសពីនេះទៅទៀត វាមានការលំបាកក្នុងការទទួលបានសេវាសុខភាពផ្លូវចិត្តពីព្រោះវាត្រូវបានផ្តល់ជូនតែនៅក្នុងមន្ទីរពេទ្យរដ្ឋ ដែលនឹងបង្កើនថ្លៃធ្វើដំណើរ និងពេលវេលា ហើយត្រូវមានឯកសារពិសេសដោយបញ្ជាក់ថាកុមារត្រូវការសេវាកម្មទាំងនេះ មុនពេលទទួលបានការព្យាបាល ។ បច្ចុប្បន្ននេះ អង្គការមិនមែនរដ្ឋាភិបាលគឺជាអ្នកផ្តល់សេវាព្យាបាលដ៏សំខាន់ ដែលនឹងទទួលទូទាត់ថ្លៃព្យាបាល ប៉ុន្តែភាគច្រើនមិនមានឯកទេសលើបញ្ហាទាក់ទងនឹងការរំលោភបំពាន និងការកេងប្រវ័ញ្ចផ្លូវភេទលើកុមារឡើយ និងចំនួនអ្នកជំងឺដែលពួកគេអាចជួយបាននៅមានកម្រិតនៅឡើយ។

មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងមន្ទីរកិច្ចការនារីគឺជាស្ថាប័នរដ្ឋាភិបាលសំខាន់ពីរដែលស្ថិតនៅក្រោម ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងក្រសួងកិច្ចការនារី ដែលផ្តល់បុគ្គលិកសង្គម និងបង្កើតជាយុទ្ធសាស្ត្រក្នុងការដោះស្រាយតម្រូវការចិត្តសាស្ត្រសង្គមរបស់កុមារដែលរងគ្រោះដោយអំពើរំលោភបំពាន និងការកេងប្រវ័ញ្ចផ្លូវភេទ។

---

48 WHO (2017) "Responding to Children and Adolescents Who Have Been Sexually Abused: WHO Clinical Guidelines https://apps.who.int/iris/bitstream/handle/10665/259270/9789241550147-eng.pdf?sequence=1

49 RGC (2009)"Policy and Minimum Standards for Protection of the Rights of Victims of Human Trafficking" http://un-act.org/publication/view/cambodias-policy-and-minimum-standards-for-protection-of-the-rights-of-victims-of-human-trafficking-2009/

50 OHCHR (2019) "Combined Fourth to Sixth Report Submitted by Cambodia under Article 44 of the Convention due in 2018 http://docstore.ohchr.org/SelfServices/FilesHandler

ឥលូវនេះ មន្ត្រីតុលាការស្នើសុំឱ្យការសម្ភាសកុមារទាំងអស់ដោយនគរបាលត្រូវមានតំណាងម្នាក់មកពីខាងសង្គមកិច្ច បន្ទាប់ពីមានការព្រួយបារម្ភថានគរបាលបង្ខំឱ្យកុមារ ផ្តល់សក្ខីកម្ម និងអាចប៉ះពាល់ដល់សក្ខីកម្មរបស់ពួកគេបន្ទាប់ពីកុមារផ្លាស់ប្តូរសក្ខីកម្មរបស់ពួកគេនៅក្នុងនីតិវិធីតុលាការ។ បុគ្គលិកសង្គមនៃមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងមន្ទីរកិច្ចការនារី មានអាណត្តិ និងសិទ្ធិអំណាចស្របច្បាប់ដើម្បីអមជាមួយកុមារក្នុងដំណាក់កាលនេះ។ ជួនកាលបុគ្គលិកសង្គមកិច្ចមកពីអង្គការមិនមែនរដ្ឋាភិបាលត្រូវបានអនុញ្ញាតឱ្យចូលរួម ប៉ុន្តែពួកគេអាចជួយក្នុងការសំរួលផ្លូវអារម្មណ៍កុមារ តែគ្មានអំណាចស្របច្បាប់ផ្សេងទៀតទេ។ បុគ្គលិកសង្គមកិច្ចម្នាក់មកពីអង្គការមិនមែនរដ្ឋាភិបាលមួយបានអះអាងថា បញ្ហានេះបង្កើតជាបញ្ហាប្រឈមជាច្រើនដោយសារខាងសង្គមកិច្ចមិនសូវទទួលបានការបណ្តុះបណ្តាល ដើម្បីធានាអំពីឧត្តមប្រយោជន៍របស់កុមារ ដែលវាហាក់ជារឿងធម្មតាដែលថាខាងសង្គមកិច្ចច្រើនតែផ្តោតលើការជួយនគរបាលដែលពេលខ្លះពួកគេហាក់ដាក់សម្ពាធឱ្យកុមារឆ្លើយសំណួររបស់នគរបាលជាជាងធានាការគោរព សិទ្ធិកុមារនៅក្នុងដំណើរការនីតិវិធី។

លើសពីនេះទៀត របាយការណ៍របស់អ្នកអនុវត្តផ្សេងៗគ្នា បង្ហាញថាជារឿយៗបុគ្គលិកសង្គមកិច្ចពីខាងសង្គមកិច្ចមានការស្ទាក់ស្ទើរក្នុងការចូលរួមក្នុងការសម្ភាសកុមារនៅដំណាក់កាលនគរបាល ទោះបីជាមានការស្នើសុំជាផ្លូវការ និងមានការសហការរបស់នគរបាលតាមរយៈការអញ្ជើញខាងសង្គមកិច្ចមុនពេលការសម្ភាសកុមារក៏ដោយ។ កង្វះកិច្ចសហការរបស់ភ្នាក់ងារ ឬតំណាងសង្គមកិច្ច ពាក់ព័ន្ធជាចម្បងនឹងភាពស្ទាក់ស្ទើរ និងការភ័យខ្លាចនៃការកោះហៅចូលរួមក្នុងនីតិវិធីតុលាការ និងកង្វះការទុកចិត្តលើប្រព័ន្ធយុត្តិធម៌។ នៅពេលដែលពួកគេចូលរួមការសម្ភាសកុមារ វាច្រើននៅចុងបញ្ចប់នៃការសម្ភាសដើម្បីចូលរួមក្នុងការចុះហត្ថលេខាលើឯកសារផ្លូវការជាជាងការធានាការគោរពសិទ្ធិរបស់កុមារក្នុងពេលសម្ភាស។

នៅពេលកុមាររងគ្រោះដោយការរំលោភបំពាន និងការកេងប្រវ័ញ្ចផ្លូវភេទត្រូវការការគាំទ្រពីខាងសង្គមកិច្ចក្នុងដំណើរការនីតិវិធីយុត្តិធម៌ព្រហ្មទណ្ឌ កុមារីទូទៅទទួលបានការគាំទ្រពីបុគ្គលិកសង្គមកិច្ចម្នាក់ពីមន្ទីរកិច្ចការនារី ខណៈដែលកុមារាទទួលបានការគាំទ្រពីបុគ្គលិកសង្គមម្នាក់ពីមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។ បុគ្គលិកពីមន្ទីរកិច្ចការនារីទទួលបានការបណ្តុះបណ្តាលច្រើនជាង ពាក់ព័ន្ធនឹងអំពើរំលោភបំពាន និងកេងប្រវ័ញ្ចផ្លូវភេទ។ ប៉ុន្តែយោងតាមអ្នកផ្តល់ព័ត៌មាន កង្វះខាតខាងចំណេះដឹងស្តីពីតម្រូវការសំរាប់ការគាំទ្រ ជាពិសេសពាក់ព័ន្ធជនរងគ្រោះជាកុមារា គឺហាក់មានចំនួនច្រើនក្នុងមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ដោយកង្វះខាតជំនាញក្នុងកិច្ចការនេះ។ កត្តានេះធ្វើឱ្យមានការព្រួយបារម្ភជាខ្លាំងដោយក្មេងប្រុស ៦ ភាគរយនិយាយថាពួកគេមានបទពិសោធន៍យ៉ាងហោចណាស់មួយដងពាក់ព័ន្ធនឹងការរំលោភបំពាន និងការកេងប្រវ័ញ្ចផ្លូវភេទមុនពេលពួកគេមានអាយុ ១៨ ឆ្នាំច្រើនជាងក្មេងស្រីទៅទៀត [51]។

"អ្វីដែលយើងអាចធ្វើបានគឺពង្រឹងសមត្ថភាពរបស់ មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា - ចាប់ពីថ្នាក់ក្រសួងរហូតដល់ថ្នាក់មូលដ្ឋានទាក់ទងនឹងការបណ្តុះបណ្តាល ការគាំទ្របច្ចេកទេស និងការបង្វឹកបង្វឹន។ មិនត្រឹមតែ មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ប៉ុណ្ណោះទេ ថែមទាំង ក្រសួងមហាផ្ទៃផងដែរ ពីព្រោះពួកគេមានទំនាក់ទំនងនឹងគ្នា។ យើងអាចឥស៊ូមតិនៅក្នុងគ្រប់ដំណើរការទាំងអស់-អង្គការមិនមែនរដ្ឋាភិបាល ដែលមានជំនាញខាងសុខភាពផ្លូវចិត្ត ហើយអ្នកផ្សេងទៀតអាចចូលរួមនិងតាមដានករណីទាំងនោះបាន - ថាតើកុមារដែលរងគ្រោះត្រូវបានផ្តល់សិទ្ធិពេញលេញដែរឬទេ"។




51 The IDPoor program, is a poverty reduction intervention, established in 2006 that identifies poor households in order to ensure assistance is provided to them. IDPoor card holders receive access to different free of charge services and assistance including health, education, financial assistance and more. For more information https://mop.idpoor.gov.kh/

កង្វះខាតកន្លែងស្នាក់នៅបណ្តោះអាសន្នជាបញ្ហាប្រឈមចម្បងមួយក្នុងការផ្តល់ជំនួយដល់កុមាររងគ្រោះដោយអំពើរំលោភបំពាន និងកេងប្រវ័ញ្ចផ្លូវភេទដែលត្រូវបានលើកឡើងដោយអ្នកផ្តល់បទសម្ភាសន៍ទាំងអស់ដែលធ្វើការក្នុងវិស័យសង្គមកិច្ច និងអ្នកខ្លះដែលធ្វើការក្នុងវិស័យផ្សេងទៀត ។ ជម្រកបណ្តោះអាសន្ននេះចាំបាច់ក្នុងករណីពាក់ព័ន្ធនឹងកុមារតាមចិញ្ចើមផ្លូវ កុមារចំណាកស្រុក និងជនរងគ្រោះពីការជួញដូរកុមារដែលពាក់ព័ន្ធនឹងករណីអំពើហិង្សាក្នុងគ្រួសារ។ ជម្រកបណ្តោះ អាសន្ននេះអាចធានាសុវត្ថិភាព និងការការពារសំរាប់កុមារដែលស្ថិតក្នុងស្ថានភាពគ្រោះថ្នាក់ ហើយការផ្តល់ជម្រកនេះពិតជាចាំបាច់ និងសំខាន់ នៅពេល ដែលត្រូវការ។ ជម្រកបណ្តោះអាស្នបែបនេះគឺមានតិចតួចណាស់ជាពិសេសនៅតាមបណ្តាខេត្ត និងក្រៅពីកន្លែងស្នាក់នៅបណ្តោះអាសន្ននៅប៉ោយប៉ែតស្ទើរតែទាំងអស់ដឹកនាំនិងគ្រប់គ្រងដោយអង្គការមិនមែនរដ្ឋាភិបាល។  ខណៈជំនួយអង្គការមិនមែនរដ្ឋាភិបាលបានសារៈប្រយោជន៍ ពួកគេក៏ប្រឈមច្រើនដែលរួមមានការមិនអាចឆ្លើយតបប្រកបដោយនិរន្តរភាព ដោយសារម្ចាស់ជំនួយមានទិសដៅផ្សេង ឬតម្រូវឱ្យជនរងគ្រោះមានលក្ខខណ្ឌជាក់លាក់មុននឹងអាចទទួលយកបញ្ចូលក្នុងសេវារបស់ខ្លួន។

នៅក្នុងបទសម្ភាសន៍ជាមួយមន្ត្រីមកពីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បានបញ្ជាក់ថាកង្វះខាតកន្លែងស្នាក់នៅបណ្តោះអាសន្នត្រូវបានលើកឡើងជាបញ្ហាប្រឈមចម្បងមួយ ហើយត្រូវបានដោះស្រាយជាអាទិភាពខ្ពស់របស់ក្រសួងសង្គមកិច្ចអតីតយុទ្ធជន និងយុវនីតិសម្បទា ដើម្បីបង្កើតលំនៅដ្ឋានបណ្តោះអាសន្ន និងកន្លែងស្នាក់នៅបណ្តោះអាសន្នបន្ថែមទៀតសម្រាប់អ្នកដែលត្រូវការ ទោះបីត្រូវបានទទួលស្គាល់ថា ពួកគេបច្ចុប្បន្នខ្វះធនធានហិរញ្ញវត្ថុគ្រប់គ្រាន់សម្រាប់គោលបំណងបែបនេះ។ អ្នកតំណាងមកពីមន្ទីរកិច្ចការនារីបានលើកឡើងពីការលំបាកពេលមានការរំលោភបំពានកើតឡើងនៅពេលយប់ និងលើកឡើងថា ទោះបីមានជំនួយពីអង្គការមិនមែនរដ្ឋាភិបាល វានៅតែលំបាករកជម្រកបណ្តោះអាសន្នប្រកបដោយសុវត្ថិភាព ដោយតម្រូវឱ្យពួកគេចំណាយប្រាក់ផ្ទាល់ខ្លួន សម្រាប់ការជួលកន្លែងដែលពេលខ្លះក៏អាចបង្កគ្រោះថ្នាក់ដល់សុវត្ថិភាពរបស់ជនរងគ្រោះផងដែរ។ មន្ត្រីនគរបាលម្នាក់មកពីខេត្តកណ្តាលបានបញ្ជាក់ថា ដោយខ្វះកន្លែងស្នាក់នៅបណ្តោះអាសន្ន ជាច្រើនដងពួកគេត្រូវអនុញ្ញាតឱ្យកុមារស្នាក់នៅក្នុងប៉ុស្តិ៍នគរបាលមួយយប់ ដោយមានមន្ត្រីយាមការពាររហូតដល់ពួកគេអាចរកកន្លែងសមរម្យសម្រាប់ឱ្យកុមារស្នាក់នៅ។ កង្វះកន្លែងស្នាក់នៅបណ្តោះអាសន្នសម្រាប់ក្មេងប្រុសត្រូវបានលើកឡើងជាបញ្ហាពិសេសមួយខណៈដែលកន្លែងស្នាក់នៅភាគច្រើនផ្តោតតែលើស្ត្រី និងក្មេងស្រី។




"ជម្រកបណ្តោះអាសន្នអាចផ្តល់ជាកន្លែងសុវត្ថិភាពនៅពេលដែលការកំណត់រកគ្រួសារមិនអាចធ្វើបានភ្លាមៗ និងទាន់ពេលវេលា។ កន្លែងនេះអាចការពារកុមារបណ្តោះអាសន្នពីហានិភ័យនានា។ វាពិតជាល្អណាស់ ជាពិសេសសម្រាប់កុមារ។ ដោយឡែកសំរាប់កុមារី មានជម្រកបណ្តោះអាសន្នមួយចំនួនដូចជា អង្គការ ARM ឬអង្គការកម្ពុជាដើម្បីជួយស្ត្រីមានវិបត្តិ ឬខ្លះទៀតខាងសង្គមកិច្ចអាចជួយ។ ប៉ុន្តែសំរាប់ក្មេងប្រុស វាហាក់មិនសូវមាននោះទេ"។

ខណៈដែលមណ្ឌលបណ្តោះអាសន្នមានសារៈសំខាន់ វាគួរត្រូវបានគូសបញ្ជាក់ឱ្យច្បាស់ថាក្រៅពីមណ្ឌលថែទាំ ក៏មានទម្រង់នៃការថែទាំផ្សេងទៀតដែលការសិក្សាចង្អុលបង្ហាញថាអាចល្អជាងសម្រាស់សុខុមាលភាពកុមារ បើទោះកុមារអាចស្នាក់នៅក្នុងរយៈពេលខ្លី និងបណ្តោះអាសន្នក៏ដោយ។ ឧទាហរណ៍ខ្លះរួមមានការមើលថែតាមសហគមន៍ និងគ្រួសារដែលកុមារត្រូវបានគេដាក់ជាមួយសមាជិកគ្រួសាររបស់គេ ឬនៅក្រោមការមើលថែរបស់គ្រួសារចិញ្ចឹម ជាពិសេសនៅក្នុងសហគមន៍ ឬការមើលថែតាមផ្ទះជាក្រុមដែលកុមារត្រូវបានគេដាក់ឱ្យរស់នៅក្នុងបរិយាកាសគ្រួសារក្រោមការត្រួតពិនិត្យរបស់ក្រុមអ្នកថែទាំមួយក្រុមតូច និងផ្ទះក្រុមនឹងត្រូវបានដាក់បញ្ចូលនៅក្នុងសហគមន៍[52]។

52 MoSVY (2017) “Study on Alternative Care Community Practices for Children in Cambodia”. https://www.unicef.org/cambodia/media/666/file/Alternative_Care_Community_Practices-EN.pdf%20.pdf

# សិទ្ធទទួលបានសេវាផ្លូវច្បាប់ និងសេវាយុត្តិធម៌

**នៅពេលដែលកុមាររងគ្រោះ និងអ្នកអាណាព្យាបាលស្រប ច្បាប់ សម្រេចដាក់បណ្តឹងអំពីបទល្មើស និងបន្តនីតិវិធីទៅ តុលាការ សក្ខីកម្មដែលកុមារផ្តល់ដល់នគរបាលជាទូទៅប្រើ សម្រាប់តែជាឯកសារគាំទ្រ និងតម្រូវឱ្យកុមារចូលរួមជាច្រើន ដងក្នុងការផ្តល់ការសម្ភាសដល់ភាគីពាក់ព័ន្ធក្នុងនីតិវិធីយុត្តិធម៌ ព្រហ្មទណ្ឌ។ ការចូលរួមម្តងហើយម្តងទៀត កើតឡើងនៅក្នុង ការកោះហៅរបស់ព្រះរាជអាជ្ញា ចៅក្រមស៊ើបសួរ មេធាវី និងក្នុងពេលជំនុំជម្រះ ហើយក្នុងករណីខ្លះ ពួកគេនឹងត្រូវបាន អញ្ជើញឱ្យផ្តល់ការសម្ភាសន៍ជាមួយមនុស្សដដែល ដើម្បី បញ្ជាក់ព័ត៌មានលម្អិតដែលពួកគេមិនបានទទួលក្នុងពេលបទ សម្ភាសន៍ពីមុន។ នៅអំឡុងពេលជំនំជម្រះ កុមារត្រូវតម្រូវ ឱ្យឆ្លងកាត់ការសម្ភាសបន្ថែមលើអង្គហេតុនៃការរំលោភ បំពាន។ ដំណាក់កាលនេះជាការលំបាកខ្លាំងសម្រាប់កុមារ ព្រោះថារវាងពេលធ្វើបទសម្ភាសន៍លើកដំបូងជាមួយប៉ូលីស រហូតដល់ការជំនុំជម្រះជាធម្មតានឹងត្រូវចំណាយពេលពី ៦ខែ ទៅមួយឆ្នាំ និងច្រើនជាងនេះទៅទៀតប្រសិនបើជនល្មើស មិនមានខ្លួន (ការឃុំខ្លួនបណ្តោះអាសន្ន)។**

ភេទរបស់អ្នកសម្ភាសន៍ជារឿយៗមិនត្រូវបានគេគិតគូរទេដែល ជាហេតុបន្ថែមភាពតានតឹង ជាពិសេសលើក្មេងស្រីព្រោះភាគ ច្រើននៃតួអង្គយុត្តិធម៌គឺជាបុរស។ សំណើសុំចៅក្រមភេទស្រី អាចធ្វើឡើងជាមុន ប៉ុន្តែជាធម្មតានឹងត្រូវការពេលវេលាច្រើន ហើយជារឿយៗជនរងគ្រោះមិនចង់ពន្យារពេលដំណើរការនេះ ទេ។ លើសពីនេះទៀត នៅពេលដែលកុមារត្រូវបានសម្ភាស ដោយចៅក្រមស៊ើបសួរ វាជារឿងធម្មតាដែលចៅក្រមតែងតាំង ក្រឡាបញ្ជីម្នាក់ដើម្បីសាកសួរជំនួន ដែលក្រឡាបញ្ជីទំនងជា មិនសូវទទួលបានការបណ្តុះបណ្តាលពិសេសនៅក្នុងនីតិវិធី បែបកុមារមេត្រីឡើយ។ បញ្ហានេះកើតមានមួយផ្នែកដោយ សារកង្វះតួអង្គយុត្តិធម៌ដែលមានសមត្ថភាពនៅក្នុងប្រទេស។ គិតត្រឹមឆ្នាំ ២០១៦ មានតែចៅក្រម ២៧៨ នាក់ ព្រះរាជអាជ្ញា ១៨៤ នាក់ និងក្រឡាបញ្ជី ២១៨ នាក់ប៉ុណ្ណោះនៅទូទាំង ប្រទេស ហើយមានមេធាវីសរុប ១.២០៣ នាក់ [53]។

ទោះជនរងគ្រោះ និងជនល្មើសមិនត្រូវបានគេកោះហៅទៅ តុលាការដើម្បីផ្តល់សក្ខីកម្មដល់ព្រះរាជអាជ្ញា ឬចៅក្រមស៊ើប សួរក្នុងពេលតែមួយក៏ដោយ ក៏ការធ្វើបែបនេះមិនត្រូវបាន អនុវត្តតាមជានិច្ចនោះទេ។ មានករណីខ្លះដែលជនសង្ស័យ នៅបន្ទប់ជាប់នឹងបន្ទប់ដែលកុមារកំពុងត្រូវគេសាកសួរក៏មាន ការនេះអាចបន្ទុចបង្អាក់កុមារពីការនិយាយដោយសេរី។ ប៉ុន្តែ អ្នកផ្តល់សេវាច្បាប់បានលើកឡើងថាបញ្ហានេះត្រូវបានកែតម្រូវរួចហើយនៅក្នុងទីក្រុងធំៗ ប៉ុន្តែមិនទូទាំងប្រទេសនោះទេ។ លើសពីនេះទៀត បច្ចុប្បន្ននេះ តុលាការមិនមានបន្ទប់រង់ចាំ ពិសេសដាច់ដោយឡែកពីគ្នារវាងជនសង្ស័យនៃ និងភ្ញៀវផ្សេង ទៀតនោះទេ ដែលជាញឹកញាប់កុមារ និងភ្ញៀវដទៃទៀតនឹងត្រូវ រង់ចាំក្បែរជនសង្ស័យដែលជាប់ខ្នោះដៃក្នុងឯកសណ្ឋាន ពន្ធនាគារ។ កុមារបានលើកឡើងពីអារម្មណ៍ភ័យខ្លាច និងការ បាក់ស្បាត នៅពេលឃើញជនសង្ស័យដែលធ្វើឱ្យពួកគេកាន់ តែមានបញ្ហាប៉ះទង្គិចផ្លូវចិត្តបន្ថែមទៀត។

[53] OHCHR (2019) "Combined Fourth to Sixth Report Submitted by Cambodia under Article 44 of the Convention due in 2018 http://docstore.ohchr.org/SelfServices/FilesHandler.ashx?enc=6QkG1d%2FPPRiCAqhKb7yhsq9DYm2EJ8kB20jPtQOn4nxl%2BFxIxumJ1eAFLgxgGiOWUgPnvmpkshhKDQO6YVxF9nuPhl4oF16yYK2bglK3%2BPPhj0U5NFPSIsgFPwGPi05s

បច្ចុប្បន្ននៅក្នុងប្រទេសកម្ពុជា ពុំមានតុលាការជំនាញសម្រាប់កុមារដែលរងគ្រោះដោយអំពើហិង្សានៅក្នុងនីតិវិធីរបស់តុលាការទេ ហើយតម្រូវការជាក់លាក់របស់កុមារមិនត្រូវបានដោះស្រាយ ដែលធ្វើឱ្យកុមារងាយរងគ្រោះនៅក្នុងប្រព័ន្ធយុត្តិធម៌បែបនេះ។ ទោះយ៉ាងណាក៏ដោយ ក៏មានការពិចារណាបង្កើតអង្គភាពជំនាញនៅក្នុងសាលាដំបូងតាមការចាំបាច់ដូចជាអង្គជំនុំជម្រះសម្រាប់កុមារ ឬអង្គជំនុំជម្រះគ្រួសារដែលឃ្លាំមើល និងធានាការគោរពសិទ្ធិរបស់កុមារដែលអនុទ្បោមតាមនីតិវិធីរបស់តុលាការ។ [54]

ក្នុងឆ្នាំ ២០១៦ ច្បាប់ទាក់ទងនឹងយុត្តិធម៌អនីតិជនត្រូវបានអនុម័ត តែច្បាប់នេះផ្តោតលើអនីតិជនទំនាស់នឹងច្បាប់ ហើយមានចែងតិចតួចទាក់ទងនឹងការការពារសិទ្ធិរបស់កុមារដែលជាជនរងគ្រោះ ឬជាសាក្សី។ ទោះបីការតំណាងផ្នែកច្បាប់នៅក្នុងតុលាការត្រូវបានគេចាត់ទុកថាជាសិទ្ធិសម្រាប់កុមារទាំងអស់ស្របតាមអនុសញ្ញាស្តីពីសិទ្ធិកុមារក៏ដោយ ក៏តម្រូវការសម្រាប់ការតំណាងស្របច្បាប់យោងតាមក្រមនីតិវិធីព្រហ្មទណ្ឌ ត្រូវបានកំណត់តែសម្រាប់តែអនីតិជនដែលមានទំនាស់នឹងច្បាប់ប៉ុណ្ណោះ ដោយទុកឱ្យសិទ្ធិរបស់កុមាររងគ្រោះ និងសាក្សីសម្រាប់ការតំណាងផ្នែកច្បាប់មិនត្រូវបានលើកឡើងនៅក្នុងច្បាប់នៃប្រទេសកម្ពុជា (ក្រមនីតិព្រហ្មទណ្ឌ មាត្រា ៣០១)។

ពុំមានច្បាប់គ្របដណ្តប់គ្រប់ជ្រុងជ្រោយសម្រាប់ដាក់បញ្ញត្តិក្នុងការផ្តល់ជំនួយផ្នែកច្បាប់ឡើយ ហើយគោលនយោបាយស្តីពីសេវាជំនួយផ្នែកច្បាប់ក៏មិនទាន់ពេញលេញ ដែលធ្វើឱ្យសិទ្ធិក្នុងការទទួលបានជំនួយផ្នែកច្បាប់សម្រាប់កុមារ និងគ្រួសាររបស់កុមារនៅមានកម្រិត។ ជាផ្លូវការ នាយកដ្ឋានជំនួយផ្នែកច្បាប់នៃគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជាទទួលបានថវិកាពីក្រសួងយុត្តិធម៌ដើម្បីផ្តល់ជំនួយផ្នែកច្បាប់ដល់ជនក្រីក្រ[55] ហើយនាយករដ្ឋមន្ត្រីក៏បានប្រកាសផងដែរនៅខែកុម្ភៈឆ្នាំ ២០១៩ ថានឹងវិនិយោគថវិកាចំនួន ៥០០.០០០ ដុល្លារអាមេរិកពីថវិកាផ្ទាល់ខ្លួនរបស់គាត់ក្នុងការបង្កើតក្រុម



គិតត្រឹមឆ្នាំ ២០១៦

**២៧៨** ចៅក្រម | **១៨៤** ព្រះរាជអាជ្ញា

**២១៨** ក្រឡាបញ្ជី | **១.២០៣** មេធាវី

មេធាវីស្ម័គ្រចិត្តដើម្បីជួយជនក្រីក្រ។ ប៉ុន្តែការពិត ដើម្បីទទួលបានជំនួយផ្លូវច្បាប់ពីអង្គភាពរដ្ឋាភិបាល កុមារ និងគ្រួសារត្រូវមានប័ណ្ណក្រីក្រ ហើយជំនួយផ្នែកច្បាប់ទំនងជាផ្តោតលើជនជាប់ចោទជាជាងជនរងគ្រោះដោយសារបញ្ញត្តិនានាដែលមានចែងក្នុងច្បាប់។ ការធ្វើបែបនេះមិនអើពើដល់ជនរងគ្រោះ និងគ្រួសាររបស់ជនរងគ្រោះជាច្រើន ដែលមិនមានធនធានហិរញ្ញវត្ថុគ្រប់គ្រាន់ដើម្បីបង់ថ្លៃសេវាមេធាវី ហើយមិនត្រូវនឹងលក្ខណៈវិនិច្ឆ័យដើម្បីកាន់ប័ណ្ណក្រីក្រ។ មេធាវីដែលត្រូវបានតែងតាំងពីគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជាទូទៅមានលំនៅដ្ឋាននៅក្នុងរាជធានីភ្នំពេញទៅទៀតដោយដាក់កំហិតដល់គ្រួសាររបស់កុមារដែលរស់នៅក្រៅរាជធានីភ្នំពេញក្នុងការទៅរកមេធាវីដែលបានតែងតាំងនោះ ដែលពួកគេមិនអាចមានលទ្ធភាពចំណាយលើការធ្វើដំណើរបន្ថែមនោះទេ។

បច្ចុប្បន្ននេះ អង្គការមិនមែនរដ្ឋាភិបាលបាននិងកំពុងបំពេញចន្លោះខ្វះខាតទាំងនេះ ប៉ុន្តែការចំណាយរបស់ម្ចាស់ជំនួយលើកម្មវិធីជំនួយផ្នែកច្បាប់មានការថយចុះក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ដោយសារតែការបង្កើននូវការបែងចែកថវិកាទៅលើកម្មវិធីស្តីពីសិទ្ធិទទួលបានយុត្តិធម៌ដោយរដ្ឋាភិបាលថ្វីបើការផ្តល់មូលនិធិមិនបានទៅដល់អ្នកទាំងអស់ដែលត្រូវការក៏ដោយ។ លើសពីនេះទៅទៀត វាកាន់តែពិបាកក្នុងការស្វែងរកមេធាវីអាជីពដែលចង់ជួយក្នុងករណីរំលោភបំពាន និងកេងប្រវ័ញ្ចផ្លូវភេទកុមារ ជាពិសេសសម្រាប់អង្គការមិនមែនរដ្ឋាភិបាលដោយ សារមេធាវីភាគច្រើនមិនមានឯកទេសក្នុងវិស័យនេះ ហើយក៏មានការលំបាកនានាក្នុងការតស៊ូមតិនៅ

54 ibid

55 AICHR (2019) "Thematic Study on Legal Aid" https://aichr.org/wp-content/uploads/2019/09/AICHR-Thematic-Study-on-Legal-Aid-for-web.pdf

> “នៅពេលដែលកុមារ និងក្រុមគ្រួសារមិនមានមេធាវី ពួកគេទំនងជានឹង **ដោះស្រាយករណីក្រៅប្រព័ន្ធតុលាការ។**”

ចំពោះមុខចៅក្រមក្នុងនាមឱ្យកុមារ។ លើសពីនេះទៀត ដោយសារករណីជាច្រើននៃការរំលោភបំពាន និងកេងប្រវ័ញ្ចផ្លូវភេទកុមារបញ្ចប់ដោយការដោះស្រាយក្រៅប្រព័ន្ធតុលាការ អត្ថប្រយោជន៍ហិរញ្ញវត្ថុសម្រាប់មេធាវីមានកម្រិតទាបដែលប៉ះពាល់ដល់ទឹកចិត្តរបស់ពួកគេក្នុងការធ្វើការលើករណីបែបនេះ។ ដូច្នេះបើគ្មានការកែទម្រង់ត្រឹមត្រូវដែលឆ្លើយតបទៅនឹងតម្រូវការ និងសិទ្ធិស្របច្បាប់របស់កុមារក្នុងការបន្តរឿងក្តីទៅតុលាការនោះទេ សិទ្ធិក្នុងការទទួលបានយុត្តិធម៌សម្រាប់កុមាររងគ្រោះដោយអំពើរំលោភបំពាន និងកេងប្រវ័ញ្ចផ្លូវភេទនៅតែមានលក្ខណៈទន់ខ្សោយ។

នៅពេលដែលកុមារ និងក្រុមគ្រួសារមិនមានមេធាវី ពួកគេទំនងជានឹងដោះស្រាយករណីក្រៅប្រព័ន្ធតុលាការ។ រឿងបែបនេះកើតឡើងប្រាកដណាស់ជាពិសេសក្នុងចំណោមគ្រួសារក្រីក្រដែលមានការយល់ដឹងអំពីសិទ្ធិតិចតួច ឬផលប៉ះពាល់យូរអង្វែងនៃអំពើរំលោភបំពាន និងកេងប្រវ័ញ្ចផ្លូវភេទលើកុមារជាធម្មតាពួកគេនឹងព្យាយាមដោះស្រាយរឿងក្តីឱ្យបានឆាប់បំផុតដើម្បីទទួលបានសំណងពីជនល្មើស ក្រៅនីតិវិធីច្បាប់។ ពួកគេភាគច្រើនមិនដឹងថាពួកគេមានសិទ្ធិទទួលបានសំណងតាមរយៈនីតិវិធីយុត្តិធម៌នោះទេ។

កុមារនៅកម្ពុជាមិនអាចធ្វើជាតំណាងរបស់ខ្លួនឯងនៅក្នុងតុលាការបានទេ ហើយមានតែមនុស្សពេញវ័យប៉ុណ្ណោះដែលអាចធ្វើជាដើមបណ្តឹងឱ្យពួកគេដែលធម្មតាជាឪពុក/ម្តាយ ឬអ្នកអាណាព្យាបាល។ ទោះបីជាដើមបណ្តឹង និងមេធាវីរបស់ជនរងគ្រោះត្រូវបានគេសន្មត់ថានឹងទទួលបានព័ត៌មានអំពីកាលបរិច្ឆេទនៃការជំនុំជម្រះជាមុនក្តី ក៏មេធាវី និងដើមបណ្តឹងជារឿយៗលើកឡើងថាពួកគេទទួលបានព័ត៌មាននេះយឺតយ៉ាវតែប៉ុន្មានថ្ងៃមុនការជំនុំជម្រះក្តីប៉ុណ្ណោះ ដោយទុកពេលតិចតួចដើម្បីរៀបចំ។ នេះរារាំងកុមារពីការបំពេញសិទ្ធិរបស់ពួកគេសម្រាប់ការជំនុំជម្រះដោយយុត្តិធម៌។ ឧទាហរណ៍មួយ ក្នុងរឿងក្តីដែលជនរងគ្រោះទទួលបានតំណាងស្របច្បាប់ដោយមេធាវីរបស់អង្គការសកម្មភាពដើម្បីកុមារ ( APLE Cambodia ) ព័ត៌មានស្តីពីការជំនុំជម្រះក្តីត្រូវបានទទួលដោយមានការជូនដំណឹងក្នុងរយៈពេលខ្លី ដែលមេធាវីមិនអាចចូលរួម និងស្នើសុំពន្យារពេលជំនុំជម្រះ។ ទោះយ៉ាងណាក៏ដោយក៏ចៅក្រមមិនពន្យារពេលដែរ ហើយការជំនុំជម្រះត្រូវធ្វើឡើងដោយគ្មានវត្តមានរបស់កុមាររងគ្រោះ ឬដើមបណ្តឹងដោយមិនគិតពីសិទ្ធិរបស់ពួកគេក្នុងការបញ្ចេញមតិ និងសិទ្ធិចូលរួម។

មេធាវីមួយចំនួនលើកឡើងថាមានការរីកចម្រើនក្នុងរយៈពេលប៉ុន្មានឆ្នាំថ្មីៗនេះ ដោយមានចៅក្រមកាន់តែច្រើនយល់ដឹងអំពីតម្រូវការ និងរបៀបធ្វើការបែបកុមារមេត្រី ដូចជាការបង្កើតទំនាក់ទំនងជិតស្និទ្ធ និងការនិយាយដោយមិនបំភ័យដើម្បីជួយកុមារឱ្យនិយាយ និងទទួលបានព័ត៌មានត្រឹមត្រូវជាមុន។ ទោះយ៉ាងណាក៏ដោយ ក៏ត្រូវបានគេកត់សម្គាល់ផងដែរថា ការប្រើប្រាស់វិធីសាស្ត្រសម្ភាសបែបកុមារមេត្រីបានប្រើប្រាស់តែម្តងម្កាលប៉ុណ្ណោះ អាស្រ័យលើកម្រិតនៃការបណ្តុះបណ្តាល និងការយល់ដឹងដែលពួកគាត់មានលើបញ្ហាទាំងនេះ។ មេធាវីម្នាក់បានរលើកពីករណីក្មេងស្រីម្នាក់ដែលជាជនរងគ្រោះដោយការចាប់រំលោភ ហើយអំឡុងពេលជំនុំជម្រះនៅក្នុងតុលាការដែលពេញទៅដោយមនុស្សជាច្រើន ចៅក្រម និងព្រះរាជអាជ្ញាបានសួរសំណួរដដែលៗម្តងហើយម្តងទៀត ធ្វើឱ្យក្មេងមានអារម្មណ៍មិនស្រួលចិត្តយ៉ាងខ្លាំងរហូតដល់នាងស្រែកឱ្យចៅក្រមឱ្យបញ្ឈប់។ ក្រៅពីសួរសំណួរដដែលៗ តួអង្គយុត្តិធម៌មួយចំនួនក៏ត្រូវបានគេរាយការណ៍ផងដែរថា និយាយមិនសមរម្យទៅកាន់កុមារដោយប្រើពាក្យមិនសមរម្យសម្រាប់អាយុ និងការយល់ដឹងរបស់ពួកគេ៖

"នៅក្នុងដំណាក់កាលជំនុំជម្រះ កុមារបាននិយាយពេលខ្លះថាពួកគេត្រូវបានគេសួរសំណួរដដែលៗ ពេលខ្លះក្នុងលក្ខណៈដែលត្រូវបានមើលងាយ។ ប៉ុន្តែខ្ញុំគិតថានេះគ្រាន់តែជាបច្ចេកទេសក្នុងការសួរសំណួរប៉ុណ្ណោះ។ ពេលខ្លះកុមារយល់ពីពាក្យ "ការរួមភេទ" ប៉ុន្តែនៅពេលដែលកុមារប្រើពាក្យផ្សេងគ្នា ពួកគេត្រូវបានសួរម្តងហើយម្តងទៀតឱ្យឆ្លើយជាមួយនឹងពាក្យដែលតុលាការចង់បាន។ សំណួរខ្លះធ្វើឱ្យកុមារយំ ឬភ័យខ្លាច។ ខ្ញុំមិនដឹងថាវាត្រូវ ឬខុសទេពីព្រោះនេះអាចជាបច្ចេកទេសសម្ភាសន៍របស់ពួកគេ។ ប៉ុន្តែកុមារប្រាប់យើងថាពួកគេមានអារម្មណ៍អាម៉ាស់។ ខ្ញុំចាំបាននូវករណីមួយនៅពេលដែលមេធាវីរបស់ជនជាប់ចោទបានចោទប្រកាន់/បំបាក់មុខកុមារនោះដោយអចេតនាថាជាមនុស្សឆ្កួត ឬមានជំងឺផ្លូវចិត្តហើយចៅក្រមបានសើចចំពោះសំណួរនោះ។"







"ចៅក្រមត្រូវតែមានអព្យាក្រឹត ប៉ុន្តែពេលខ្លះចៅក្រមសួរសំណួរដែលហាក់ដូចជាចោទប្រកាន់កុមារហើយធ្វើឱ្យកុមារមានការលំបាក។ ឧទាហរណ៍ ពួកគេបានសួរកុមារអំពីការរំលោភបំពានផ្លូវភេទរបស់ពួកគេ ហើយបានចោទប្រកាន់កុមារនោះថាជាមនុស្សលោភលន់ ឬងាយផ្តល់ការយល់ព្រមដល់ជនល្មើស"

តួអង្គយុត្តិធម៌បានបង្ហាញពីសារៈសំខាន់នៃការជូនដំណឹងដល់កុមារអំពីសិទ្ធិស្របច្បាប់របស់ពួកគេ ប៉ុន្តែនៅក្នុងការអនុវត្តជាក់ស្តែង ការធានាសិទ្ធិ និងឧត្តមប្រយោជនរបស់ពួកគេដែលជាក់ស្តែងត្រូវបានបំពេញនៅក្នុងតុលាការ មិនត្រូវធ្វើឱ្យលេចជារូបរាងឡើយនៅក្នុងករណីជាច្រើន។ ឧទាហរណ៍ យោងតាមប្រកាសរបស់ក្រសួងយុត្តិធម៌ "របាំងតុលាការគួរតែត្រូវបានប្រើជាវិធានការការពារចម្បងក្នុងរឿងក្តីទាំងអស់ដែលពាក់ព័ន្ធនឹងកុមារ/ជនរងគ្រោះឬសាក្សីដែលងាយរងគ្រោះ" [56] ប៉ុន្តែភស្តុតាងបង្ហាញថារបាំងតុលាការមិនត្រូវបានប្រើប្រាស់ជាទូទៅទេ ហើយជារឿយៗត្រូវបានប្រើប្រាស់ ប្រសិនបើមានការស្នើសុំជាផ្លូវការពីមេធាវីរបស់កុមារ ឬបុគ្គលិកសង្គមកិច្ចដែលអមកុមារប៉ុណ្ណោះ។ កុមារ និងអាណាព្យាបាលច្រើនតែមិនដឹងអំពីសិទ្ធិរបស់ពួកគេក្នុងការស្នើសុំប្រើប្រាស់របាំងក្នុងពេលជំនុំជម្រះ។ លើសពីនេះទៀត តុលាការខ្លះនៅតែមិនមានរបាំង ឬពេលខ្លះពួកគេប្រើរបាំងដែលមានលក្ខណៈមិនគ្រប់គ្រាន់ ដូចជាវាំងននថ្លាដែលកុមារនៅតែអាចមើលឃើញជនល្មើសតាមវាំងនននោះដែលប៉ះពាល់ដល់អារម្មណ៍ សុវត្ថិភាព និងសមត្ថភាពរបស់កុមារក្នុងការនិយាយ។

មានតែតុលាការមួយចំនួនទេ ដែលមានជម្រើសក្នុងការប្រើបន្ទប់ដែលមានទូរទស្សន៍ដែលកុមារអាចផ្តល់សក្ខីកម្មរបស់ពួកគេនៅក្នុងបន្ទប់ដាច់ដោយឡែក ប៉ុន្តែទាំងតួអង្គយុត្តិធម៌ និងតួអង្គសង្គមបាននិយាយថាបន្ទប់ទាំងនេះកម្រនឹងប្រើណាស់។ បញ្ហានេះភាគច្រើនត្រូវបានស្តីបន្ទោសទៅលើការថែរក្សាបរិក្ខារមិនបានល្អ និងកង្វះជំនាញបច្ចេកទេសក្នុងការប្រើបរិក្ខារ ឬតួអង្គយុត្តិធម៌ចូលចិត្តធ្វើការជំនុំជម្រះតាមរបៀបប្រពៃណីដែលមិនយកចិត្តទុកដាក់លើឧត្តមប្រយោជន៍របស់កុមារ។

---

56 MoJ, (2008) Prakas on the Use of Court Screen and Courtroom TV-Linked Testimony from Child/Vulnerable Victims or Witnesses - item2.1

## ប្រអប់ទី៤. បទពិសោធន៍របស់កុមារជាមួយនឹងតួអង្គយុត្តិធម៌

កុមារភាគច្រើនបាននិយាយថា ពួកគេត្រូវបានគេជូនដំណឹងអំពីសិទ្ធិរបស់ពួកគេ និងហេតុផលដែលពួកគេត្រូវបានគេកោះហៅឱ្យផ្ដល់ការសម្ភាសន៍នៅតុលាការ។

កុមារបានពិពណ៌នាថាមានអារម្មណ៍សន្ទប់ នៅពេលដែលមន្ត្រីតុលាការដូចជាក្រឡាបញ្ជី ឬចៅក្រមបាននិយាយជាមួយពួកគេដោយគ្មានការគួរសម ហើយបាននិយាយថាវាមានផលប៉ះពាល់លើសមត្ថភាពរបស់ពួកគេ ក្នុងការពិពណ៌នាលម្អិតអំពីរឿងរំលោភបំពានមកលើពួកគេ។ មន្ត្រីខ្លះត្រូវបានកុមារបញ្ជាក់ថាបានប្រើពាក្យ "មិនល្អ" ហើយនិយាយខ្លាំងៗដែលធ្វើឱ្យពួកគេភ័យខ្លាច ឬដែលមិនផ្ដល់ការគោរព។ ពួកគេបានសម្ដែងនូវការចង់បានការគោរពទោះបីជាមានអ្វីកើតឡើងចំពោះពួកគេក៏ដោយ។ ប៉ុន្តែក៏មានចៅក្រមមួយចំនួនត្រូវបានគេកត់សម្គាល់ថាមានការគួរសម និងប្រើពាក្យសម្ដីល្អៗដែលអនុញ្ញាតឱ្យសម្រាកនៅពេលកុមារមានអារម្មណ៍រំជួលចិត្ត។ ចៅក្រមស៊ើបសួរភាគច្រើនក៏បានអនុញ្ញាតឱ្យឪពុក ម្ដាយ ឬអ្នកអាណាព្យាបាលចូលរួមក្នុងពេលធ្វើការសាកសួរដែលជួយពួកគេឱ្យមានអារម្មណ៍ស្រួលចិត្ត និងបាត់តក់ស្លុតខ្លះ។

ភាគច្រើនកុមារីបានបង្ហាញពីការលំបាកនៅពេលដែលតួអង្គយុត្តិធម៌ជាមនុស្សប្រុស និងបង្ហាញពីផលប៉ះពាល់ដែលមានទៅលើការចែករំលែករឿងរ៉ាវរបស់ពួកគេ។ ពួកគេបានបង្ហាញថាមានអារម្មណ៍អៀនខ្មាស និងមិនស្រណុកចិត្ត និងអាម៉ាស់ ហើយបង្ហាញថាវាប៉ះពាល់ដល់សមត្ថភាពរបស់ពួកគេ ក្នុងការពិពណ៌នាអំពីអ្វីដែលបានកើតឡើងចំពោះពួកគេឱ្យបានលម្អិត។

ការមើលឃើញមន្ត្រីតុលាការនៅក្នុងឯកសណ្ឋានពណ៌ខ្មៅរបស់ពួកគេ គួរឱ្យភ័យខ្លាចចំពោះកុមារជាច្រើនពេលដំបូងៗ។ កុមារម្នាក់បាននិយាយថាវាធ្វើឱ្យនាងភ័យខ្លាំងណាស់ដោយនាងមានអារម្មណ៍ច្របូកច្របល់នៅពេលនាងត្រូវរៀបរាប់ពីលំដាប់ព្រឹត្តិការណ៍នៃអ្វីដែលបានកើតឡើងចំពោះនាង។ តែការស្លៀកពាក់ឯកសណ្ឋានក៏ត្រូវបានគេយល់ឃើញថាមានអត្ថប្រយោជន៍ចំពោះកុមារខ្លះផងដែរ ព្រោះវាបានជួយពង្រឹងស្មារតីរបស់ពួកគេនៅពេលពួកគេទម្លាប់នឹងវាដែលជួយពួកគេប្រាប់រឿងរបស់ពួកគេ។

ភាពឯកជន និងការសម្ងាត់របស់កុមារមិនត្រូវបានគេគិតគូរជានិច្ចជាកាលនោះទេ។ ជារឿយៗ មានយ៉ាងហោចណាស់ក្រឡាបញ្ជីពីរនាក់បន្ថែមទៀតក្នុងអំឡុងពេលសម្ភាសជាមួយចៅក្រមស៊ើបសួរ ហើយការសម្ភាសន៍មិនតែងតែត្រូវបានធ្វើក្នុងបន្ទប់ដែលបិទទ្វារនោះទេ ដោយមនុស្សផ្សេងទៀតចូល និងចេញបន្ទប់បាន។ នេះត្រូវបានបង្ហាញជាហេតុផលចម្បងមួយដែលធ្វើឱ្យពួកគេមានអារម្មណ៍អៀនខ្មាស និងមិនចង់ប្រាប់ព័ត៌មានលម្អិត។ កង្វះបន្ទប់រង់ចាំនៅក្នុងតុលាការក៏ត្រូវបានគេទទួលស្គាល់ថាជាការរំខានផងដែរ ដោយកុមារមានអារម្មណ៍មិនស្រួលចិត្តដែលមនុស្សបានឃើញមុខនាងខណៈពេលដែលនាងរង់ចាំមួយម៉ោងមុនពេលសាកសួរ។

កុមារភាគច្រើននិយាយថាវាចំណាយពេលច្រើនខែ បន្ទាប់ពីការសម្ភាសន៍លើកដំបូងជាមួយនគរបាល រហូតដល់ពេលពួកគេត្រូវបានកោះហៅទៅផ្ដល់សក្ខីកម្មជាមួយចៅក្រមស៊ើបសួរ។ កុមារភាគច្រើនបានបង្ហាញពីភាពស្រងាកចិត្តចំពោះរយៈពេលនៃដំណើរការនេះ ដោយនិយាយថាវាជះឥទ្ធិពលយ៉ាងខ្លាំងទៅលើអារម្មណ៍ និងកម្រិតនៃភាពតានតឹងរបស់ពួកគេ នៅពេលរំលឹកពីរឿងរ៉ាវរំលោភបំពានដែលពួកគេចង់បំភ្លេចវា។ កុមារខ្លះពោលថានេះជាកត្តាមួយធ្វើឱ្យពួកគេពិចារណាថាតើពួកគេគួរតែបន្ត ឬពួកគេគួរតែបញ្ចប់នីតិវិធី។

# របកគំហើញ

## ផ្នែកទី ២៖ ផលប៉ះពាល់របស់ទីភ្នាក់ងារដែលប្រតិបត្តិដាច់ដោយឡែកពីគ្នា



ការប្រយុទ្ធប្រឆាំងនឹងអំពើរំលោភបំពាន និងកេងប្រវ័ញ្ចផ្លូវភេទលើកុមារ និងការលើកកម្ពស់សិទ្ធិក្នុងការទទួលបានយុត្តិធម៌តម្រូវឱ្យមានតួអង្គជាច្រើនសហការគ្នាឱ្យបានពេញលេញ ស្របតាមយន្តការសម្របសម្រួលប្រកបដោយប្រសិទ្ធភាព។ ទីភ្នាក់ងារដែលធ្វើប្រតិបត្តិការដាច់ដោយឡែក ហើយមានបណ្ដាញទំនាក់ទំនងខ្សោយក្នុងចំណោមបណ្ដាទីភ្នាក់ងារផ្សេងៗ បង្កើតជាបញ្ហាប្រឈមនានាដែលប៉ះពាល់ដល់គុណភាពសេវាកម្មដែលផ្ដល់ដល់កុមារក៏ដូចជាផលប៉ះពាល់ដល់លទ្ធផលយុត្តិធម៌ព្រហ្មទណ្ឌផងដែរ។ ដូចដែលបានបញ្ជាក់តាមរយៈទិដ្ឋភាពទូទៅលើស្ថានភាពបច្ចុប្បន្ននៃនីតិវិធីយុត្តិធម៌ព្រហ្មទណ្ឌនៅកម្ពុជា មានប្រធានបទសំខាន់ចំនួន ៣ លេចឡើងពីកង្វះខាតក្នុងការឆ្លើយតបរបស់ពហុទីភ្នាក់ងារដែលប៉ះពាល់ទាំងកុមារក៏ដូចជាប្រសិទ្ធភាពនៃនីតិវិធីផងដែរ៖

## ការកើនឡើងនូវហានិភ័យនៃការធ្វើឱ្យរងគ្រោះឡើងវិញ ដោយសារការរំលឹកដដែលៗអំពីរឿងរំលោភបំពាន

**ផលប៉ះពាល់មួយក្នុងចំណោមផលប៉ះពាល់សំខាន់ៗ នៃការមានភ្នាក់ងារដែលធ្វើប្រតិបត្តិការដាច់ដោយឡែកពីគ្នាក្រោមនីតិវិធីយុត្តិធម៌ព្រហ្មទណ្ឌគឺ កុមារត្រូវបានតម្រូវឱ្យនិយាយរឿងរ៉ាវរបស់ពួកគេម្ដងហើយម្ដងទៀតទៅកាន់បុគ្គលិកផ្សេងៗគ្នាជាច្រើនតាមដំណាក់កាលនីមួយៗ។**

ការរំលឹកដដែលៗនូវរឿងរំលោភបំពានកើតឡើងលើពួកគេទៅកាន់អ្នកផ្ដល់សេវាផ្សេងៗ មានផលប៉ះពាល់អវិជ្ជមានជាច្រើនចំពោះសុខុមាលភាពរបស់កុមារនិងសមត្ថភាពក្នុងការជាសះស្បើយឡើងវិញ ហើយឈានទៅដល់ការប៉ះទង្គិចផ្លូវចិត្តឡើងវិញ និងរងគ្រោះឡើងវិញនៅតាមដំណើរការនីតិវិធីបែបនេះ។ ដូចដែលបានពិពណ៌នាដោយកុមារអារម្មណ៍ទាំងនេះរួមមានដូចជា៖ មានអារម្មណ៍អាម៉ាស់ក្នុងការចែករំលែករឿងរ៉ាវរបស់ពួកគេជាមួយមនុស្សចម្លែកជាច្រើន មានអារម្មណ៍ឈឺ និងនឿយហត់ក្នុងការផ្ដល់ចម្លើយដដែល ភ័យខ្លាច មិនសប្បាយចិត្ត មិនចង់ឱ្យនរណាម្នាក់ដឹងអំពីវា ធ្វើឱ្យពិបាកក្នុងការបំភ្លេច និងកាត់ចិត្ត  មានអារម្មណ៍ខកចិត្ត ច្របូកច្របល់ ធុញទ្រាន់ និងរំខាន។

សមាសភាគចាំបាច់មួយ ដែលត្រូវការសម្រាប់កុមារដើម្បីឱ្យពួកគេអាចផ្ដល់សក្ខីកម្មលម្អិត និងត្រឹមត្រូវអំពីរឿងរំលោភបំពានរបស់ពួកគេគឺអារម្មណ៍សុវត្ថិភាពរបស់ពួកគេ ក៏ដូចជាការទទួលដឹងថាពួកគេកំពុងត្រូវបានគេស្ដាប់ និងត្រូវបានគេអើពើដោយគ្មានការវិនិច្ឆ័យ។ ពួកគេចាំបាច់ត្រូវជឿទុកចិត្តលើប្រព័ន្ធយុត្តិធម៌ហើយជឿជាក់ថាសុវត្ថិភាព និងតម្រូវការរបស់ពួកគេត្រូវបានគេចាត់ទុកថាជាអាទិភាព។ បុគ្គលិកសង្គមកិច្ចម្នាក់បានពិពណ៌នាថា៖




"ពួកគេចាំបាច់ត្រូវប្រាប់រឿងរ៉ាវរបស់ពួកគេទៅកាន់នគរបាល បុគ្គលិកសង្គមកិច្ចគ្រូពេទ្យកោសល្យវិច្ច័យ ចៅក្រមស៊ើបសួរ និងចៅក្រមនៅក្នុងតុលាការ។ វាប៉ះពាល់ដល់( ពួកគេ )ពីព្រោះរាល់ពេលដែលពួកគេប្រាប់ ពួកគេមិនបានឃើញលទ្ធផលភ្លាមៗទេ ហើយពួកគេមានអារម្មណ៍ថារឿងនេះត្រូវបានចែករំលែកពីគ្នាទៅវិញទៅមកដោយគ្មានលទ្ធផល។ ក្រោយមកទៀតកុមារនឹងចាត់ទុកវាជាការអាម៉ាស់ ហើយនឹងបញ្ឈប់ការចូលរួមរបស់ពួកគេ។ លើសពីនេះទៀត ទាក់ទងនឹងសុខភាពផ្លូវចិត្តរបស់ពួកគេ នៅពេលដែលពួកគេចែករំលែករឿងរ៉ាវរបស់ពួកគេជាមួយនគរបាល ហើយប្រសិនបើគ្មានអ្នកជំនាញខាងសុខភាពផ្លូវចិត្តមកជួយទេនោះ ( សុខភាព ) ផ្លូវចិត្តរបស់កុមារនឹងកាន់តែធ្ងន់ធ្ងរហើយពួកគេនឹងកាន់តែមានការប៉ះទង្គិចផ្លូវចិត្តបន្ថែមទៀត ... ពេលខ្លះដោយសារតែចម្លើយដំបូងមិនអាចនាំមកនូវលទ្ធផល ពួកគេផ្លាស់ប្តូរ ឬប្រឌិត( សេចក្តីថ្លែងការណ៍របស់ពួកគេ )"

ទោះបីជាមានការទទួលស្គាល់ថា ការរំលឹកដដែលៗនូវរឿងរ៉ាវរបស់ពួកគេអាចជះឥទ្ធិពលអវិជ្ជមានដល់សុខភាពផ្លូវចិត្ត និងដំណើរការជាសះស្បើយឡើងវិញរបស់កុមារក៏ដោយក៏នគរបាលតួអង្គយុត្តិធម៌ភាគច្រើន និងសូម្បីតែអ្នកជំនាញមួយចំនួនមកពីខាងសង្គមកិច្ចបានអះអាងថាវាចាំបាច់ និងសមហេតុផលចំពោះការកោះហៅច្រើនដង និងការសួរសំណួរដដែលៗក្នុងពេលសម្ភាសន៍ដូចដែល "ត្រូវការ"  ដោយសារតែមានការផ្លាស់ប្តូរជាញឹកញាប់នៅក្នុងពត៌មានលម្អិត និងសក្ខីកម្មរបស់កុមារ និងការលំបាករបស់ពួកគេក្នុងការចងចាំព័ត៌មានអំពីព្រឹត្តិការណ៍នៃការរំលោភបំពានរបស់ពួកគេ។ វាមិនមែនជារឿងចម្លែកទេសម្រាប់ព្រឹត្តិការណ៍ដ៏តក់ស្លុតដូចជាការរំលោភបំពាន និងការកេងប្រវ័ញ្ចផ្លូវភេទរំខានដល់ការចងចាំព្រឹត្តិការណ៍ និងសមត្ថភាពក្នុងការរៀបរាប់ឡើងវិញនូវព័ត៌មានលម្អិតត្រឹមត្រូវ ហើយវាកាន់តែធម្មតាក្នុងករណីជាកុមារ [57]។ ទោះយ៉ាងណាក៏មានជម្រើសផ្សេងទៀតដែលអាចធានាបាននូវសក្ខីកម្មត្រឹមត្រូវដែលគិតគូរពីឧត្តមប្រយោជន៍របស់កុមារ និងកាត់បន្ថយការធ្វើឱ្យមានការប៉ះទង្គិចផ្លូវចិត្តឡើងវិញ។ វិធីសាស្រ្តបែបនេះឱ្យមានអ្នកឯកទេសដែលត្រូវបានបណ្តុះបណ្តាលយ៉ាងស្ទាត់ជំនាញធ្វើជាអ្នកសម្ភាសន៍ស្របពេលប្រើប្រាស់វិធីសាស្រ្តបែបកុមារមេត្រី និងកត់ត្រាបទសម្ភាសន៍តាមបែបឌីជីថលដើម្បីប្រើក្នុងជំហានផ្សេងទៀតក្នុងនីតិវិធីយុត្តិធម៌ព្រហ្មទណ្ឌ។ អ្នកឯកទេសដែលត្រូវបានបណ្តុះបណ្តាលអំពីការសម្ភាសន៍បែបកុមារមេត្រីអាចបង្កើនគុណភាពព័ត៌មានដែលបានទាញយក និងលើកទឹកចិត្តកុមារឱ្យផ្តល់ព័ត៌មានលម្អិត ត្រឹមត្រូវបន្ថែមទៀតដែលអាចមានប្រយោជន៍សម្រាប់រឿងក្តីរបស់ពួកគេ។ ការថតសំឡេងអាចត្រូវបានប្រើនៅពេលក្រោយទៀតជំនួសឱ្យការកោះហៅកុមារម្តងហើយម្តងទៀតដើម្បីធ្វើការសាកសួរ ។

បន្ទប់សម្ភាសន៍កុមារមេត្រីបានបង្កើតឡើងដោយអង្គការសកម្មភាពដើម្បីកុមារ ( APLE Cambodia ) រួមមានឧបករណ៍ថតសំឡេង ហើយមន្ត្រីនគរបាលដែលសម្ភាសកុមារនៅក្នុងបន្ទប់ទាំងនេះ ត្រូវបានបណ្តុះបណ្តាលឱ្យប្រើការថតសំឡេងក្នុងអំឡុងពេលធ្វើបទសម្ភាសន៍ ប៉ុន្តែការថតសំឡេងនៃការសម្ភាសន៍បែបកោសល្យវិច្ច័យរបស់កុមារមិនត្រូវបានធ្វើជាទម្លាប់នោះទេ។ នគរបាល និងតួអង្គយុត្តិធម៌មួយចំនួនបានគាំទ្រគំនិតនៃការថតសំឡេងក្នុងកម្រិតមួយ ប៉ុន្តែជារឿយៗពួកគេមានការបម្រុងទុកជាច្រើនផងដែរ ។ ការព្រួយបារម្ភនានាត្រូវបានលើកឡើងគឺទាក់ទងនឹងសក្តានុពលនៃការថតសំឡេងដែលត្រូវបានប្រើខុសចំពោះកុមារ និងអ្នកសម្ភាសន៍ដោយខាងចុងចោទ ឬតាមរបៀបមួយដែលធ្វើឱ្យប៉ះពាល់ដល់ការសម្ងាត់របស់កុមារ។ ប៉ុន្តែមន្ត្រីមួយចំនួនបានឃើញនូវសក្តានុពលក្នុងការការពារនគរបាលដោយនិយាយថាពេលខ្លះកុមារនឹងផ្លាស់ប្តូរសក្ខីកម្មរបស់ពួកគេ ហើយខាងចុងចោទនឹងអះអាងថាកុមារនោះត្រូវបានបញ្ចុះបញ្ចូលដោយនគរបាល ប៉ុន្តែពួកគេអាចបង្ហាញការថតសំឡេង ដើម្បីបង្ហាញពីអ្វីដែលបានកើតឡើងក្នុងពេលធ្វើការសម្ភាសន៍។

57 Howe, M.L, & Knott, L.M (2015) “The Fallibility of Memory in Judicial Processes: Lessons from the Past and their Modern Consequences” https://www.tandfonline.com/doi/full/10.1080/09658211.2015.1010709

លើសពីនេះទៀត ការលំបាកត្រូវបានលើកឡើងទាក់ទងនឹងការថតសំឡេង ខណៈដែលការសម្ភាសន៍មួយចំនួនត្រូវបានធ្វើឡើងនៅក្រៅប៉ុស្តិ៍នគរបាល ឬនៅតាមតំបន់ជនបទដែលត្រូវការប្រើប្រាស់ឧបករណ៍ថតចល័តដែលពួកគេមិនមាន។ ពួកគេភាគច្រើនបានសារភាពថាទោះបីជាមានឧបករណ៍ក៏ដោយ គេកម្រប្រើណាស់ហើយសូម្បីតែនៅពេលដែលពួកគេធ្វើការថតសំឡេង ពួកគេភាគច្រើនយល់ថាវាមិនចាំបាច់ និងប្រើប្រាស់ធនធានច្រើន នៅពេលដែលបច្ចុប្បន្នការថតសំឡេងមិនត្រូវបានគេទទួលស្គាល់ថាជាភស្តុតាងផ្លូវច្បាប់នៅក្នុងតុលាការ ឬត្រូវបានប្រើប្រាស់ដោយតួអង្គយុត្តិធម៌ឡើយ។



ស្នងការរងនៃស្នងការដ្ឋាននគរបាលខេត្តសៀមរាប - P៣

"ក្នុងអំឡុងពេលបណ្តុះបណ្តាល ពួកគេបានប្រាប់យើងឱ្យរក្សាខ្សែអាត់ថតសំឡេង។ យើងរក្សាទុកការថតសំឡេងប៉ុន្តែយើងមិនប្រគល់ទៅតុលាការទេ។ ខ្សែអាត់ថតសំឡេងទាំងនោះត្រូវបានរក្សាទុកនៅក្នុងឧបករណ៍ផ្ទុកយូអេសប៊ី ( USB flash drives )។ ប៉ុន្តែតុលាការមិនមានបច្ចេកវិទ្យាដើម្បីប្រើប្រាស់ខ្សែអាត់ថតសំឡេងទេ។ យើងមិនចង់ស្នើឱ្យកុមារ ( និយាយរឿងរបស់ពួកគេឡើងវិញ ) ច្រើនដងទេប៉ុន្តែតុលាការមិនទាន់មកដល់ដំណាក់កាលនេះនៅឡើយទេ។ ពួកគេនៅតែសម្ភាសកុមារម្តងទៀត។"

ដោយសារខ្សែអាត់ថតសំឡេងអាចមានរយៈពេលច្រើនម៉ោង ចៅក្រមលើកឡើងថាគេចូលចិត្តសួរសំណួរកុមារដោយផ្ទាល់ពេលដែលព័ត៌មានជាក់លាក់មួយចំនួនត្រូវបានយល់ច្រឡំជាជាងទៅស្តាប់ខ្សែអាត់ថតសំឡេងម្តងទៀតនៅពេលមានរឿងមិនច្បាស់។ ខ្សែអាត់សំឡេងអាចត្រូវបានកត់ត្រាជាលាយលក្ខណ៍អក្សរដើម្បីឱ្យបុគ្គលដែលវិភាគភស្តុតាងធ្វើការពិនិត្យកាន់តែលឿន។ ទោះបីជាខ្សែអាត់សំឡេងមិនទាន់ត្រូវបានអនុម័តជាភស្តុតាងនៅក្នុងតុលាការក៏ដោយ ក៏ខ្សែអាត់សំឡេងអាចត្រូវបានប្រើប្រាស់ក្នុងដំណាក់កាលផ្សេងទៀតនៃនីតិវិធីយុត្តិធម៌ព្រហ្មទណ្ឌជំនួសឱ្យការសួរសំណួរកុមារឡើងវិញ ដើម្បីធានាថាឧត្តមប្រយោជន៍របស់ពួកគេត្រូវបានផ្តល់អាទិភាព។

# ផលប៉ះពាល់លើប្រសិទ្ធភាពនៃ ការប្រាស្រ័យទាក់ទងគ្នា និងការសម្របសម្រួលសេវាកម្ម

**មានការខិតខំប្រឹងប្រែងដោយរាជរដ្ឋាភិបាលចំពោះការអភិវឌ្ឍយន្តការសម្របសម្រួលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ រវាងអន្តរភាគីធ្វើការពាក់ព័ន្ធនឹងកុមារ ឬផ្តល់ការគាំទ្រដល់ជនរងគ្រោះនៃអំពើហិង្សា។**

ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ ( ក.ជ.ក ) ជាឧទាហរណ៍ត្រូវបានបង្កើតឡើងក្នុងឆ្នាំ១៩៩៥ និងត្រូវបានទទួលស្គាល់ជាផ្លូវការដោយរាជរដ្ឋាភិបាលកម្ពុជានៅឆ្នាំ២០០៩ ដើម្បីដើរតួជាយន្តការសម្របសម្រួលសំរាប់ការអនុវត្ត តាមដាន និងវាយតម្លៃលើគ្រប់គោលនយោបាយ និងកម្មវិធីដែលពាក់ព័ន្ធនឹងកុមារនៅក្នុងប្រទេសកម្ពុជា ដោយរួមបញ្ចូលទាំងកិច្ចការពារកុមារ។ គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ ( គ.ក.ស.ក )និងគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ/សង្កាត់ ( គ.ក.ន.ក ) ត្រូវបានបង្កើតឡើងជាយន្តការសម្របសម្រួលថ្នាក់ក្រោមជាតិ ដែលមានទំនួលខុសត្រូវពាក់ព័ន្ធនឹងកិច្ចការពារកុមារក្នុងកម្រិតក្រោមជាតិ។

លើសពីនេះទៀត យន្តការសម្របសម្រួលផ្សេងទៀតត្រូវបានបង្កើតឡើងដើម្បីការពារជនរងគ្រោះដោយសារអំពើហិង្សាជាពិសេសអំពើហិង្សាផ្អែកលើយេនឌ័រ។ ឧទាហរណ៍ ក្រសួងកិច្ចការនារីដឹកនាំ ក្រុមការងារបច្ចេកទេសស្តីពីយេនឌ័រ អំពើហិង្សាផ្អែកលើយេនឌ័រ ( TWGG–GBV ) ជាដៃគូអន្តរក្រសួង / ដៃគូអភិវឌ្ឍន៍ និងយន្តការសម្របសម្រួលរបស់អង្គការក្រៅរដ្ឋាភិបាល ដើម្បីជម្រុញការសម្របសម្រួលថ្នាក់ជាតិសម្រាប់ការអនុវត្តផែនការសកម្មភាពជាតិដើម្បីទប់ស្កាត់អំពើហិង្សាលើស្ត្រី ( NAPVAW ) ។ ក្រុមការងារបច្ចេកទេស - អំពើហិង្សាផ្អែកលើយេនឌ័រ ( TWG–GBV ) រៀបចំការប្រជុំសម្របសម្រួលទៀងទាត់ និងផ្តួចផ្តើមផែនការប្រតិបត្តិការប្រចាំឆ្នាំរួមគ្នារវាងក្រសួងសំខាន់ៗចំនួន៥ (ក្រសួងកិច្ចការនារី ក្រសួងសុខាភិបាល ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងមហាផ្ទៃ និងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា [58] )។ នៅថ្នាក់ក្រោមជាតិ អនុក្រុមការងារស្តីពីអំពើហិង្សាផ្អែកលើយេនឌ័រត្រូវបានផ្តួចផ្តើមឡើងនៅតាមខេត្តចំនួន ៨ ដោយក្នុងខេត្តនីមួយៗមានសមាជិក ២០-៣០ នាក់ តំណាងដោយនគរបាលកងរាជអាវុធហត្ថ យុត្តិធម៌ ក្រសួងមហាផ្ទៃ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា មន្ទីរកិច្ចការនារីខេត្ត ក្រសួងសុខាភិបាល ក្រសួងអប់រំយុវជននិងកីឡា និងអង្គការមិនមែនរដ្ឋាភិបាលមួយចំនួនដែលប្រតិបត្តិដើម្បីធ្វើឱ្យយន្តការបញ្ជូនបន្ត និងការផ្តល់សេវាដល់ជនរងគ្រោះដោយសារអំពើហិង្សាផ្អែកលើយេនឌ័រ[59] មានលក្ខណៈកាន់តែប្រសើរឡើង។

យន្តការសម្របសម្រួលទាំងនេះគឺជាជំហានដែលនឹងផ្តល់ផ្លែផ្កា ដើម្បីពង្រឹងការសម្របសម្រួលពហុភាគី។ ទោះបីយន្តការសម្របសម្រួលភាគច្រើន ជាពិសេសនៅថ្នាក់ក្រោមជាតិមិនបានផ្តោតជាពិសេសលើកុមារ និងមានលក្ខណៈទូទៅធម្មតារួមនឹងឯកទេសការពារកុមារនៅមានកម្រិត ជាពិសេសការរំលោភបំពាន និងការកេងប្រវ័ញ្ចផ្លូវភេទលើកុមារ ឬលើបញ្ហាដែលទាក់ទងនឹងយុត្តិធម៌បែបកុមារមេត្រីនៅក្នុងការឆ្លើយតបទៅនឹងតម្រូវការពិសេសរបស់កុមារ។ លើសពីនេះទៀត វាត្រូវបានកត់សម្គាល់ថាដែនវិសាលភាពនៅទូទាំងប្រទេសនៅមានកម្រិតហើយពួកគេខ្វះលក្ខខណ្ឌយោង ដើម្បីបញ្ជាក់ពីទំនួលខុសត្រូវ និងតួនាទីជាក់លាក់របស់សមាជិកនៃយន្តការទាំងនេះ [60] ដែលការនេះបន្តការរំខានដល់ប្រសិទ្ធភាពនៃការឆ្លើយតប។

នៅពេលដែលភ្នាក់ងារ និងអ្នកផ្តល់សេវាប្រតិបត្តិដាច់ដោយឡែកពីគ្នា បញ្ហាប្រឈមមួយទៀតគឺការប៉ះពាល់ដល់ប្រសិទ្ធភាពពាក់ព័ន្ធនឹងការសម្របសម្រួលរវាងសេវាកម្ម និងការផ្ទេរព័ត៌មានមិនគ្រប់គ្រាន់។ នៅពេលព័ត៌មានរវាងភ្នាក់ងារមិនត្រូវបានផ្ទេរប្រកបដោយប្រសិទ្ធភាព វាជះឥទ្ធិពលដល់ដំណើរការស៊ើបអង្កេតក៏ដូចជាសមត្ថភាពក្នុងការកំណត់អត្តសញ្ញាណជនរងគ្រោះឱ្យបានទាន់ពេលវេលា ដែលអាចបង្កើនហានិភ័យដល់ការជួយសង្គ្រោះកុមារអាចយឺត និងការរំលោភបំពានអាចនៅបន្ត ។ លើសពីនេះទៀត វាអាចនាំឱ្យមានការវាយតម្លៃយឺត ឬធ្វេសប្រហែសចំពោះតម្រូវការរបស់កុមារបន្ទាប់ពីរងការរំលោភបំពាន។ ការនេះបង្ករឱ្យមានការយឺតយ៉ាវ ឬអាក់ខានក្នុងការប៉ាន់ប្រមាណតម្រូវការរបស់កុមារបន្ទាប់ពីរងគ្រោះ ដែលអាចឈានដល់ការបញ្ជូនយឺតយ៉ាវទៅអ្នកផ្តល់សេវាចិត្តសង្គមភ្លាម។ លើសពីនេះ ដោយយន្តការបញ្ជូនបន្តត្រូវបានសម្រួល និងមានលក្ខណៈទន់ខ្សោយ ការទទួលខុសត្រូវក្នុងការស្វែងរកសេវាកម្មដែលសមស្របនឹងត្រូវធ្លាក់ទៅលើជនរងគ្រោះ។ មានករណីជាច្រើន ដែលមិនមានព័ត៌មានអំពីសេវាដែលមានសម្រាប់កុមាររងគ្រោះ និងពេលខ្លះនៅតំបន់ដាច់ស្រយាលមិនមានសេវាសម្រាប់ជនរងគ្រោះនោះទេ។

ផលប៉ះពាល់មួយទៀតនៃការសម្របសម្រួលដែលមានកម្រិត គឺភាពត្រួតស៊ីគ្នានៃនីតិវិធីដែលអាចត្រូវបានបញ្ចៀសប្រសិនមានការឆ្លើយតបរបស់ពហុភាគីប្រកបដោយលក្ខណៈសហការ។ វាដាក់បន្ទុកបន្ថែមទៀតលើប្រព័ន្ធដោយយកពេលវេលា និងធនធានសម្រាប់ការបំពេញបញ្ចប់នីតិវិធី។ កង្វះគោលការណ៍ណែនាំច្បាស់លាស់ស្តីពីពេលវេលា និងវិធីដែលព័ត៌មានគួរតែត្រូវបានផ្ទេររវាងពហុភាគី ឬការមានបុគ្គលម្នាក់ដែលត្រូវបានចាត់តាំងសម្រាប់គោលបំណងនេះ ក៏ធ្វើឱ្យទីភ្នាក់ងារនីមួយៗធ្វើប្រតិបត្តិការក្នុងល្បឿនខុសៗគ្នា និងយោងតាមវិធានរបស់ពួកគេដែលអូសបន្លាយនីតិវិធីផងដែរ។ នេះត្រូវបានគេកត់សម្គាល់ជាពិសេសថាជាបញ្ហាប្រឈមមួយរួមជាមួយនឹងការសម្របសម្រួលរវាងសេវាសុខភាព និងតួអង្គយុត្តិធម៌ ជាពិសេសទាក់ទងនឹងការផ្ទេរលទ្ធផលវេជ្ជសាស្ត្រកោសល្យវិច្ច័យដែលជះឥទ្ធិពលយ៉ាងខ្លាំងដល់រយៈពេលនៃដំណើរការយុត្តិធម៌ព្រហ្មទណ្ឌ។

---

58 The World Bank (2019) Cambodia: Gender Based Violence Institutional Mapping Report http://documents1.worldbank.org/curated/en/644691594091820996/pdf/Cambodia-Gender-Based-Violence-Institutional-Mapping-Report.pdf

59 ibid

60 ibid

# ផលប៉ះពាល់លើភាពជោគជ័យ នៃលទ្ធផលផ្នែកយុត្តិធម៌ព្រហ្មទណ្ឌ

**ដូចដែលបានបញ្ជាក់ខាងលើ ដោយសារទីភ្នាក់ងារប្រតិបត្តិដាច់ដោយឡែកពីគ្នា និងយន្តការសម្របសម្រួលមានលក្ខណៈទន់ខ្សោយ នោះតម្រូវការរបស់កុមារមិនត្រូវបានយចិត្តទុកគ្រប់គ្រាន់ក្នុងដំណើរការយុត្តិធម៌ព្រហ្មទណ្ឌទេ។ នេះមិនត្រឹមតែជះឥទ្ធិពលដល់សុខភាពផ្លូវចិត្ត និងសមត្ថភាពក្នុងការជាសះស្បើយឡើងវិញរបស់កុមារប៉ុណ្ណោះទេ វាថែមទាំងជះឥទ្ធិពលដោយផ្ទាល់ទៅលើការសម្រេចបាននូវលទ្ធផលខ្ពស់ពីដំណើរការយុត្តិធម៌ព្រហ្មទណ្ឌផងដែរ។**

នៅពេលដែលកុមារ និងគ្រួសារជឿថាប្រព័ន្ធនេះមិនត្រូវបានតម្រង់ទៅរកឧត្តមប្រយោជន៍របស់កុមារដូចនៅក្នុងចិត្តរបស់ពួកគេនោះទេ ពួកគេកាន់តែបាត់បង់ជំនឿថាពួកគេនឹងទទួលបានជំនួយក្នុងដំណើរការនេះ។ កង្វះជំនឿលើប្រព័ន្ធយុត្តិធម៌ធ្វើឱ្យកុមារ និងក្រុមគ្រួសាររបស់កុមារមានជំនឿថា ពួកគេនឹងប្រសើរជាងបើដោះស្រាយក្រៅប្រព័ន្ធតុលាការ។ ការសិក្សាមួយដែលរៀបចំដោយអង្គការទស្សនៈពិភពលោកអន្តរជាតិ ជាឧទាហរណ៍ បានបង្ហាញថាក្រុមគ្រួសារ សមាជិកគណៈកម្មការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ/សង្កាត់ និងដៃគូអង្គការមិនមែនរដ្ឋាភិបាលទាំងអស់បានបញ្ជាក់ថា ទោះបីដឹងថាការឆ្លើយតបសមស្របទៅនឹងការរំលោភបំពាន និងការកេងប្រវ័ញ្ចផ្លូវភេទកុមារគឺត្រូវរាយការណ៍ទៅអាជ្ញាធរមូលដ្ឋាន និងធ្វើការចោទប្រកាន់ដើម្បីឈានដល់ការកាត់ទោសករណីនោះក៏ដោយ ក៏ភាគច្រើនមិនបានធ្វើចំណាត់ការស្របទៅតាមនោះទេ ទាក់ទងនឹងករណីនៅក្នុងសហគមន៍របស់ពួកគេ [61]។ ហេតុផលមួយចំនួនដែលផ្តល់ដោយអ្នកចូលរួមក្នុងការសិក្សារួមមានការជឿថាការប្រព្រឹត្តអំពើពុករលួយនឹងនាំឱ្យជនល្មើសរួចផុតពីការកាត់ទោសទោះបីមានភស្តុតាងក៏ដោយ ការជឿថានគរបាលនឹងមិនជួយដល់គ្រួសារក្រីក្រឡើយ ឬត្រូវធ្វើដំណើរឆ្ងាយប្រសិនបើពួកគេរស់នៅឆ្ងាយ ការចំណាយទាក់ទងនឹងការកាត់ទោស នគរបាលខ្វះជំនាញក្នុងការប្រមូលភស្តុតាង និងការរងប៉ះពាល់លើការសម្ងាត់របស់ជនរងគ្រោះ និងការចំណាយទាក់ទងនឹងការកាត់ទោស [62]។

ភាពលំបាកក្នុងការទទួលបានសេវាកម្មផ្សេងៗក៏រារាំងកុមារ និងក្រុមគ្រួសារពីការស្វែងរកយុត្តិធម៌ និងកាន់តែជម្រុញឱ្យមានការដោះស្រាយក្រៅប្រព័ន្ធតុលាការផងដែរ។ ការចំណាយលើការធ្វើដំណើរពីទីភ្នាក់ងារមួយទៅទីភ្នាក់ងារមួយទៀតត្រូវបានគេកត់សម្គាល់ឃើញថាជាឧបសគ្គដែលរារាំងកុមារពីការស្វែងរកសេវាកម្មបន្ថែម ជាពិសេសកុមារដែលមានគ្រួសារនៅជនបទ និងក្រីក្រ។ រយៈពេលនៃដំណើរការនេះជាកត្តាដែលជម្រុញឱ្យកុមារ និងអាណាព្យាបាលរបស់ពួកគេដោះស្រាយនីតិវិធីក្រៅប្រព័ន្ធច្បាប់ ហើយព្យាយាមបញ្ចប់ដំណើរការនេះឱ្យបានកាន់តែឆាប់តាមដែលអាចធ្វើទៅបាន។

លើសពីនេះទៀត វិធីសាស្ត្រនៃការសម្ភាសន៍ដែលគ្មានជំនាញ និងមិនផ្តល់ការយកចិត្តទុកដាក់ ជាពិសេសនៅពេលដែលធ្វើម្តងហើយម្តងទៀតដោយអ្នកផ្តល់សេវាកម្មផ្សេងៗ ទំនងជាទទួលបានព័ត៌មានមិនត្រឹមត្រូវពីកុមារដែលជះឥទ្ធិពលដល់ភាពខ្លាំងនៃករណីរបស់ពួកគេ។ វាធ្វើឱ្យប៉ះពាល់ដល់ដំណើរការស៊ើបអង្កេត និងអត្រាជោគជ័យនៃការផ្តន្ទាទោសជនល្មើស និងការធ្វើឱ្យជនល្មើសទទួលខុសត្រូវចំពោះបទល្មើសរបស់ពួកគេមានកំរិតទាប។

---

[61] World Vision International (2017) Protecting Cambodia's Children? The Role of Commune Committees for Women and Children and Informal Community-based Child Protection Mechanisms in Cambodia
https://www.wvi.org/sites/default/files/CCWC-Functionality-for-CP-Full-Report-EN.pdf

[62] ibid

# របកគំហើញ

## ផ្នែកទី ៣៖ មជ្ឈមណ្ឌលច្រកចេញចូល តែមួយ - ដំណោះស្រាយរបស់ពហុភាគី

### មជ្ឈមណ្ឌល ច្រកចេញចូលតែមួយ

**មជ្ឈមណ្ឌលច្រកចេញចូលតែមួយ គឺជាការឆ្លើយតបរបស់ពហុភាគីដែលប្រតិបត្តិក្នុងទីតាំងតែមួយ ( ក្រោមដំបូលតែមួយ ) ដើម្បីឆ្លើយតបនឹងបញ្ហារបស់ជងរងគ្រោះដោយអំពើហិង្សា។ មជ្ឈមណ្ឌលនេះ ត្រូវបានបង្កើតឡើងដើម្បីបម្រើដល់គោលបំណងមួយចំនួន៖ ពង្រឹងកិច្ចសម្របសម្រួលនិងការចែករំលែកព័ត៌មានរវាងពហុភាគី រួមទាំងការបញ្ជូនទៅសេវាគាំទ្រនានា កាត់បន្ថយការប៉ះទង្គិចផ្លូវចិត្ត និងផលប៉ះពាល់អវិជ្ជមានដែលនីតិវិធីយុត្តិធម៌ព្រហ្មទណ្ឌមានលើជនរងគ្រោះ និងបង្កើនលទ្ធផលផ្នែកយុត្តិធម៌ព្រហ្មទណ្ឌ[63] កាន់តែមានលក្ខណៈប្រសើរ។**

គំរូមជ្ឈមណ្ឌលច្រកចេញចូលតែមួយកើតចេញពីដំណោះស្រាយរួមដែលអ្នកជំនាញប្រតិបត្តិក្នុងទីតាំងតែមួយដើម្បីបំរើប្រយោជន៍ជនរងគ្រោះ ជាជាងតម្រូវឱ្យជនរងគ្រោះធ្វើដំណើរពីទីតាំងមួយទីតាំងមួយ ដើម្បីទទួលបានសេវាគាំទ្រដែលពួកគេត្រូវការ។ ប្រសិនភាគីធ្វើការពាក់ព័ន្ធទាំងអស់ដែលពាក់ព័ន្ធនឹងករណីនោះសហការគ្នាឱ្យកាន់តែមានប្រសិទ្ធភាព និងទាន់ពេលវេលា ជនរងគ្រោះកាន់តែអាចទទួលបានការគាំទ្រ និងជំនួយចាំបាច់នានា។ មានភស្តុតាងបញ្ជាក់ថាជនរងគ្រោះដែលត្រូវបានគេប្រាប់អំពីសិទ្ធិរបស់ពួកគេកាន់តែមានអារម្មណ៍ថាតម្រូវការរបស់ពួកគេត្រូវបានគេយកទៅពិចារណា និងលើកកម្ពស់សិទ្ធិទទួលបានយុត្តិធម៌ ព្រមទាំងលើកទឹកចិត្តពួកគេឱ្យបន្តចូលរួមក្នុងនីតិវិធីច្បាប់។

ខណៈមជ្ឈមណ្ឌលច្រកចេញចូលតែមួយទាំងអស់អនុវត្តតាមយន្តការប្រហាក់ប្រហែលរួមគ្នាមួយ បម្រែបម្រួលនៅតែមានដែលធ្វើឱ្យសមស្របទៅតាមបរិបទ និងតម្រូវការក្នុងស្រុក។ គំរូស្រដៀងគ្នានៃមជ្ឈមណ្ឌលច្រកចេញចូលតែមួយសម្រាប់ការគាំទ្រដល់មនុស្សពេញវ័យ ដែលជាជនរងគ្រោះដោយអំពើហិង្សាបានលេខរូបរាងចាប់តាំងពីទសវត្សរ៍ឆ្នាំ១៩៧០នៅសហរដ្ឋអាមេរិក ប៉ុន្តែគំរូត្រូវបានកែសម្រួលលើកដំបូង ដើម្បីផ្តោតលើតម្រូវការជាក់លាក់របស់កុមារ និងបង្កើតជាមជ្ឈមណ្ឌលតស៊ូមតិសម្រាប់កុមារ ( CAC ) នៅក្នុងឆ្នាំ ១៩៨៥ នៅក្នុងរដ្ឋ

[63] Herbert & Bromfield (2017), Better Together? A Review of Evidence for Multi-Disciplinary Teams Responding to Physical and Sexual Child Abuse. Accessed December 2020 https://ncjtc-static.fvtc.edu/Resources/RS00004131.pdf

អាឡាបាម៉ា ( Alabama ) សហរដ្ឋអាមេរិក។ គិតត្រឹមបច្ចុប្បន្នមានប្រមាណជាង១000មជ្ឈមណ្ឌលដែលកំពុងដំណើរការនៅក្នុងសហរដ្ឋអាមេរិក និងប្រទេស៣៨ផ្សេងទៀតទូទាំងសាកលលោក[64]។ គោលដៅចម្បងរបស់មជ្ឈមណ្ឌលតស៊ូមតិសម្រាប់កុមារគឺដើម្បីធានាថាកុមារនឹងមិនបន្តរងគ្រោះនៅពេលចូលរួមក្នុងកិច្ចអន្តរាគមន៍នានាដែលសំដៅការពារពួកគេទៀត[65]។ វាផ្តល់នូវកន្លែងមានសុវត្ថិភាពមួយសម្រាប់កុមារ ដែលមន្ត្រីអនុវត្តច្បាប់ តួអង្គយុត្តិធម៌ អ្នកផ្តល់សេវាសុខភាពរាងកាយ និងផ្លូវចិត្ត ផ្តល់សេវានៅកន្លែងតែមួយ ដើម្បីផ្តល់ការថែទាំរួម និងការថែទាំបែបកុមារមេត្រីសម្រាប់តម្រូវការបន្ទាន់របស់កុមារ។

ការសិក្សាអំពីមជ្ឈមណ្ឌលតស៊ូមតិសម្រាប់កុមារនៅសហរដ្ឋអាមេរិក បានបង្ហាញថាមជ្ឈមណ្ឌលតស៊ូមតិសម្រាប់កុមារមានប្រសិទ្ធិភាពតាមរូបភាពផ្សេងៗគ្នា៖ ធ្វើឱ្យប្រសើរឡើងនូវការទទួលបានការគាំទ្រសុខភាពផ្លូវចិត្តនិ ងប្រព័ន្ធបញ្ជូនបន្តកាន់តែរឹងមា[66] ការចូលរួមពេញលេញរបស់មន្ត្រីអនុវត្តច្បាប់មានការពេញចិត្តខ្ពស់ពីសំណាក់របស់អ្នកថែទាំដែលមិនពាក់ព័ន្ធនឹងបទល្មើស ព្រមទាំងពេញចិត្តនឹងដំណើរការស៊ើបអង្កេត និងការទុកចិត្តលើបុគ្គលិក[67] ដែលអាចរួមចំណែកដល់ការឃាត់ខ្លួន និងការផ្តន្ទាទោសកាន់តែខ្ពស់[68] ។

ដោយសារភាពជោគជ័យរបស់មជ្ឈមណ្ឌលតស៊ូមតិសម្រាប់កុមារនៅសហរដ្ឋអាមេរិក និងការផ្តើមចេញពីគោលគំនិតដូចគ្នា Baranhus ឬផ្ទះកុមារត្រូវបានបង្កើត ឡើងក្នុងចុងទសវត្សទី៩0 នៅស្កង់ឌីណាវី ( ស្កង់ឌីណាវី ជាក្រុមប្រទេសមួយនៅតំបន់ទ្វីបអឺរ៉ុបភាគខាងជើង ) តែត្រូវបានកែសម្រួលដើម្បីសម្របទៅនឹងប្រព័ន្ធសុខុមាលភាពរបស់បណ្តុំប្រទេសខាងលើ និងប្រព័ន្ធយុត្តិធម៌។ ផ្ទះគំរូ Barnahus ដំបូងត្រូវបានបង្កើតឡើងនៅ ប្រទេសអៀកឡង់ដ៏ ដែលប្រព័ន្ធសុខុមាលភាពមានភាពរឹងមាំ និងបានផ្តល់អាទិភាពយ៉ាងខ្លាំងរួចហើយទៅលើការថែទាំកុមារ និងសិទ្ធិកុមារ ការអប់រំ សន្តិសុខសង្គម និងការថែទាំសុខភាពដែលនាំឱ្យមានភាពងាយស្រួលក្នុងការអនុវត្តគំរូនៅក្នុងបរិបទនោះ[69]។ អត្ថប្រយោជន៍នៃគំរូត្រូវបានបង្ហាញឱ្យឃើញនៅក្នុងប្រទេសទាំងនេះ ហើយបានបង្ហាញអារម្មណ៍សុវត្ថិភាពកាន់តែច្រើនអំពីបរិយាកាសបែបកុមារមេត្រីដោយកុមារកាន់តែអាចបង្ហាញព័ត៌មានលម្អិត បានទទួលការថែទាំសុខភាពផ្លូវចិត្តកាន់តែប្រសើរ និងការស៊ើបអង្កេតកាន់តែរឹងមាំដែលនាំឱ្យមានលទ្ធផលផ្នែកយុត្តិធម៌ព្រហ្មទណ្ឌប្រសើរជាងមុន។[70]

ការឆ្លើយតបរបស់ពហុភាគីចំពោះជនរងគ្រោះដែលជាមនុស្សពេញវ័យ និងជាកុមារដោយអំពើហិង្សាបានកើនប្រជាប្រិយភាពជាអន្តរជាតិ ខណៈពេលដែលទទួលបានការផ្តោតនិងយកចិត្តទុកដាក់ពីសំណាក់ម្ចាស់ជំនួយ និងរដ្ឋាភិបាលទាំងនៅក្នុងប្រទេសដែលមានប្រាក់ចំណូលខ្ពស់ និងប្រទេសដែលមានចំណូលមធ្យមកម្រិតទាប។

---

64 National Children's Alliance (2016) "Putting Standards into Practice: A Guide to Implementing the 2017 Standards for Accredited Members" https:// www.nationalchildrensalliance.org/wp-content/uploads/2015/06/NCA2017-StandardsIntoPractice-web.pdf

65 National Children's Alliance (2016) "Putting Standards into Practice: A Guide to Implementing the 2017 Standards for Accredited Members" https://www.nationalchildrensalliance.org/wp-content/uploads/2015/06/NCA2017-StandardsIntoPractice-web.pdf

66 Connor-Burrows, N.A et al (2012) "The Development of a Systematic Approach to Mental Health Screening in Child Advocacy Centers" https://www.sciencedirect.com/science/article/abs/pii/S0190740912001788

67 Jones, L.M et al (2009)"Nonoffending Caregiver and Youth Experiences with Child Sexual Abuse Investigations" https://journals.sagepub.com/doi/10.1177/0886260509334394

68 Miller, A. & Rubin, D. (2009), "The Contribution of Children's Advocacy Center's to Felony Prosecutions of Child Sexual Abuse" https://www.sciencedirect.com/science/article/abs/pii/S014521340800241X

69 Stefansen et al.,(2017) Epilogue: The Barnahus Model: Potentials and Challenges in the Nordic Context and Beyond. In "Collaborating Against Child Abuse; exploring the Nordic Barnahaus model", edited by Johansson et.al. https://www.palgrave.com/gp/book/9783319583877

70 Johansson et. al (2017) Collaborating Against Child Abuse; exploring the Nordic Barnahaus model https://www.palgrave.com/gp/book/9783319583877

ទាំងមជ្ឈមណ្ឌលតស៊ូមតិសម្រាប់កុមារ និងមជ្ឈមណ្ឌលច្រកចេញចូលតែមួយ ត្រូវបានគេចាត់ទុកថាជាការអនុវត្តល្អបំផុតមួយដែលត្រូវបានជម្រុញ និងគាំទ្រដោយបរិធានអន្តរជាតិនិងទីភ្នាក់ងារផ្សេងៗ។ ឧទាហរណ៍ អង្គការUNODC បានបង្កើតឧបករណ៍មួយរួមផ្សំជាមួយយុទ្ធសាស្ត្រនានា និងវិធានអនុវត្តស្តីពីការលុបបំបាត់អំពើហិង្សាលើកុមារក្នុងផ្នែកបង្ការបទល្មើស និងយុត្តិធម៌ព្រហ្មទណ្ឌដើម្បីជួយដល់អ្នកធ្វើគោលនយោបាយ មន្ត្រីយុត្តិធម៌ព្រហ្មទណ្ឌ និងអ្នកអនុវត្តនានា។ នៅក្នុងនោះ វាបញ្ជាក់ថាអង្គភាពឯកទេសពហុភាគីដែលរួមបញ្ចូលគ្នាអាចឆ្លើយតបបានយ៉ាងឆាប់រហ័ស និងដោយប្រសិទ្ធភាពចំពោះតម្រូវការខាងវេជ្ជសាស្ត្រ ផ្លូវចិត្ត សង្គម និងផ្លូវច្បាប់របស់កុមារ ក៏ដូចជាតម្រូវការការពាររបស់ពួកគេ ជាធម្មតាគឺជាការឆ្លើយតបប្រកបដោយប្រសិទ្ធភាពបំផុតចំពោះបទល្មើសនៃអំពើហិង្សាលើកុមារ [71]។

មានបម្រែបម្រួលជាច្រើននៅក្នុងវិធីសាស្ត្ររបស់បណ្តាប្រទេសផ្សេងៗ ដែលប្រទេសខ្លះផ្តោតលើតម្រូវការរបស់កុមារ ខណៈពេលប្រទេសខ្លះទៀតផ្តល់អត្ថិភាពជាមជ្ឈមណ្ឌលច្រកចេញចូលតែមួយដែលជួយទាំងស្ត្រី និងកុមាររងគ្រោះដោយអំពើហិង្សា( សូមមើលប្រអប់ ៥ ) ។ ជាធម្មតា មជ្ឈមណ្ឌលច្រកចេញចូលតែមួយមាន ៣ ប្រភេទគឺ មជ្ឈមណ្ឌលច្រកចេញចូលតែមួយដែលមានមូលដ្ឋានជាមន្ទីរពេទ្យ មជ្ឈមណ្ឌលច្រកចេញចូលតែមួយដែលឈរតែឯង និងមជ្ឈមណ្ឌលច្រកចេញចូលតែមួយដែលដឹកនាំដោយអង្គការក្រៅរដ្ឋាភិបាល។

មជ្ឈមណ្ឌលច្រកចេញចូលតែមួយនីមួយៗមានគុណសម្បត្តិ និងគុណវិបត្តិដាច់ដោយឡែកពីគ្នា ដែលជះឥទ្ធិពលដល់ការថែទាំដែលជនរងគ្រោះទទួលបាន។ មជ្ឈមណ្ឌលច្រកចេញចូលតែមួយ ដែលមានមូលដ្ឋានជាមន្ទីរពេទ្យមានបំពាក់គ្រឿងបរិក្ខារបានល្អប្រសើរ និងអាចទទួលចំនួនអ្នកជំងឺបានច្រើន មានកិច្ចសហការពហុវិស័យកាន់តែប្រសើរ និងមានអត្ថប្រយោជន៍យ៉ាងច្រើន និងបង្កការប៉ះទង្គិចតិចទៅលើជនរងគ្រោះដែលមកទទួលសេវាគាំទ្រ។ មជ្ឈមណ្ឌលច្រកចេញចូលតែមួយដែលមានមូលដ្ឋាននៅក្នុងមន្ទីរពេទ្យអាចមានតម្លៃថ្លៃជាង ហើយជាធម្មតាមិនមានលក្ខណៈងាយស្រួលក្នុងការទៅរកសេវា ឬលទ្ធភាពតិចតួចក្នុងការបង្កើតនៅក្នុងតំបន់ដែលមានការខ្វះខាតអ្នកឯកទេស ឬនៅតំបន់ជនបទ និងតំបន់ដែលមិនសក្តិសមផ្តល់សេវា ( non–tertiary )[72]។ មជ្ឈមណ្ឌលច្រកចេញចូលតែមួយដែលឈរតែឯងមានហានិភ័យខ្ពស់ក្នុងការបង្កឱ្យមានស្លាកស្នាមទុរយសដល់ជនរងគ្រោះ ព្រោះវាត្រូវបានគេស្គាល់ថាជាកន្លែងសំរាប់ជនរងគ្រោះដោយអំពើរំលោភបំពាន និងកេងប្រវ័ញ្ចផ្លូវភេទ ហើយមិនអាចបំពេញតាមតម្រូវការផ្នែកវេជ្ជសាស្ត្រ និងតម្រូវការបន្ទាន់របស់អ្នកជនរងគ្រោះបានឡើយ ខណៈដែលមជ្ឈមណ្ឌលច្រកចេញចូលតែមួយ ដែលដឹកនាំដោយអង្គការក្រៅរដ្ឋាភិបាលមានសេវាកម្មគាំទ្រផ្នែកចិត្តសាស្ត្រល្អជាងប៉ុន្តែអាចខ្វះលទ្ធភាពក្នុងការបន្តការថែទាំដោយហេតុផលនិន្នាការម្ចាស់ជំនួយ និងធនធាន [73]។

---

71 UNODC (2015) " Introducing the United Nations Model Strategies and Practical Measures on the Elimination of Violence against Children in the Field of Crime Prevention and Criminal Justice: A New Tool for Policymakers, Criminal Justice Officials and Practitioners" https://www.unodc.org/documents/justice-and-prison-reform/14-08451_Strategy_eBook.pdf book/9783319583877

72 Olson, R, Garcia-Moreno,. C, Columbini, M. (2020) The implementation and effectiveness of the one stop centre model for intimate partner and sexual violence in low- and middle- income countries: a systematic review of barriers and enablers https://gh.bmj.com/content/5/3/e001883

73 ibid

## ប្រអប់ ៥. តើការឆ្លើយតបសម្រាប់អំពើហិង្សាលើកុមារ និងអំពើហិង្សាលើស្ត្រីគួរត្រូវបានបញ្ចូលគ្នា ឬធ្វើឱ្យដាច់ដោយឡែកពីគ្នា?

មានយន្តការផ្សេងៗចំពោះអត្ថប្រយោជន៍ និងគុណវិបត្តិនៃការរួមបញ្ចូលប្រព័ន្ធឆ្លើយតបសម្រាប់កុមាររងគ្រោះដោយអំពើហិង្សា និងប្រព័ន្ធឆ្លើយតបសម្រាប់ស្ត្រី ឬដើម្បីដោះស្រាយបញ្ហានីមួយៗក្នុងទម្រង់ដាច់ដោយឡែកពីគ្នា។ អំណះអំណាងដែលគាំទ្រដល់ការដាក់បញ្ចូលទាំងពីរអះអាងថាប្រព័ន្ធការពារសម្រាប់ទាំងស្ត្រី និងកុមារមានទំនាក់ទំនងគ្នាដោយប្រព័ន្ធគាំទ្រនេះនៅមានកម្រិតចំពោះតម្រូវការរបស់កុមារ និងស្ត្រី ហើយចំណាត់ការផ្លូវច្បាប់ប្រឆាំងនឹងជនល្មើសមានភាពទន់ខ្សោយ [74]។ លើសពីនេះទៀត ក៏មានពាក់ព័ន្ធផងដែរនឹងទម្លាប់សង្គមដែលលើកទឹកចិត្តឱ្យរក្សាភាពស្ងៀមស្ងាត់ជុំវិញអាកប្បកិរិយាហិង្សាលើស្ត្រីនិងកុមារ[75]។ អាទិភាពត្រួតគ្នាអាចផ្តល់ឱកាសដើម្បីចែករំលែកធនធានសម្រាប់គោលបំណងស្រដៀងគ្នា។

ប៉ុន្តែ គុណវិបត្តិមានដូចជា ហានិភ័យនៃការមើលរំលងតម្រូវការជាក់លាក់របស់កុមារដែលខុសពីមនុស្សពេញវ័យ ជាពិសេសដោយសារសិទ្ធិរបស់ពួកគេត្រូវបានគេព្រងើយកន្តើយ និងមិនគិតគូរនៅក្នុងនីតិវិធីយុត្តិធម៌ព្រហ្មទណ្ឌ។ ការព្រួយបារម្ភមួយទៀតគឺនៅពេលការឆ្លើយតបទៅនឹងអំពើហិង្សាលើស្ត្រីត្រូវបានរួមផ្សំជាមួយអំពើហិង្សាលើកុមារ មានទំនោរផ្តោតច្រើនជាងលើជនរងគ្រោះជាស្ត្រីក្រោមអំពើហិង្សាផ្អែកលើយេនឌ័រដែលអាចមិនអើពើដោះស្រាយតម្រូវការរបស់ក្មេងប្រុសជាជនរងគ្រោះ។

ខណៈពេលអំពើហិង្សាលើកុមារ និងអំពើហិង្សាលើស្ត្រី ត្រូវការការយកចិត្តទុកដាក់ផ្ទាល់ និងការបង្វែរធនធានជាពិសេសនៅក្នុងប្រទេសកម្ពុជា និងក្នុងបរិបទអាស៊ីអាគ្នេយ៍ដែលសិទ្ធិរបស់កុមារមិនត្រូវបានគេយល់ និងពិចារណាតិចជាងសិទ្ធិរបស់មនុស្សពេញវ័យ ការមានប្រព័ន្ធឆ្លើយតបដាច់ដោយឡែកដែលផ្តោតលើតម្រូវការរបស់កុមារអាចមានសារៈសំខាន់ និងមានប្រយោជន៍ក្នុងការជួយធានាថាតម្រូវការពិសេសរបស់ពួកគេត្រូវបានដោះស្រាយយ៉ាងពេញលេញ ខណៈពេលដែលពង្រឹងសមត្ថភាពរបស់ពួកគេក្នុងការជាសះស្បើយ និងស្តារឡើងវិញពីការរំលោភបំពាន។

របាយការណ៍នេះមានចេតនាពិចារណាលើប្រព័ន្ធពិសេសមួយសម្រាប់កុមារ ដើម្បីបង្ហាញពីភាពខ្វះចន្លោះនៃការឆ្លើយតបដែលមានលក្ខណៈពិសេសចំពោះតម្រូវការរបស់កុមារ និងជម្រុញការពិភាក្សាទាក់ទងនឹងការលើកកម្ពស់ដំណោះស្រាយផ្តោតលើកុមារនៅក្នុងនីតិវិធីយុត្តិធម៌ព្រហ្មទណ្ឌ និងធានាថាភាពខ្វះចន្លោះទាំងនេះត្រូវបានបំពេញ ។

---

74 UNICEF EAPRO (2020) "Ending Violence Against Women and Children in Cambodia: Opportunities and Challenges for Collaborative and Integrative Approaches https://reliefweb.int/sites/reliefweb.int/files/resources/ending_violence_against_women_and_children_in_cambodia_-_report.pdf

75 ibid

# ឧបសគ្គ និងការរឹតត្បិត ចំពោះប្រសិទ្ធភាពនៃការអនុវត្តគំរូ

**ថ្វីបើមានអត្ថប្រយោជន៍យ៉ាងច្រើនពាក់ព័ន្ធនឹងមជ្ឈមណ្ឌលច្រកចេញចូលតែមួយក្នុងការផ្តល់ការសេវាថែទាំ និងគាំទ្រដល់ជនរងគ្រោះ និងសិទ្ធិទទួលបានយុត្តិធម៌មានលក្ខណៈកាន់តែប្រសើរក៏ដោយ ក៏នៅតែមានឧបសគ្គសម្រាប់ការអនុវត្ត និងការរឹតត្បិតចំពោះភាពជោគជ័យនៃគំរូនេះដែរ។**

ដូចមានចែងក្រោមយុទ្ធសាស្ត្រ INSPIRE – ការអនុវត្តកម្មវិធីបង្ការដោយផ្អែកលើភស្តុតាង អាស្រ័យលើភាពខ្លាំងនៃប្រព័ន្ធដែលនៅក្រោមវិស័យនីមួយៗទាំងនេះ( និងការត្រៀមខ្លួនរបស់ពួកគេក្នុងការដោះស្រាយបញ្ហានៃអំពើហិង្សាលើកុមារ ) ដែលរួមជាមួយយន្តការដ៏មានប្រសិទ្ធិភាពក្នុងការធានាឲ្យបាននូវការសម្របសម្រួលរវាងពួកគេ[76]។ ការឆ្លើយតប និងកិច្ចប្រឹងប្រែងផ្តល់ការគាំទ្រអាចនឹងមានលទ្ធផលដូចការព្រាងទុកប្រសិនបើកិច្ចប្រឹងប្រែងនោះមានលក្ខណៈបែបកុមារមេត្រី និងគិតគូរពីយេនឌ័រ ប្រកាន់ខ្ជាប់នូវគោលការណ៍ណែនាំស្តីពីសីលធម៌ និងសិទ្ធិមនុស្សដើម្បីធានាឱ្យបាននូវការរក្សាការសំងាត់ និងអនុទ្បោមតាមបទដ្ឋាន និងស្តង់ដារច្បាស់លាស់។ ស្តង់ដារគួរត្រូវបានតាក់តែងឡើងក្រោមច្បាប់ និងគោលនយោបាយដែលចែងអំពីអណត្តិ និងតួនាទីច្បាសលាស់សំរាប់អ្នកផ្តល់សេវាដើម្បីធានាឱ្យបាននូវការប្រមូល និងតាមដានទិន្នន័យនៃវិស័យនានាសំដៅការធានារឱ្យបានធនធានគ្រប់គ្រាន់ក្នុងការគាំទ្រដល់ដំណើរការ [77]។ បើគ្មានការបង្កើតគោលការណ៍ណែនាំមូលដ្ឋានថ្នាក់ជាតិ និងការបង្កើនសមត្ថភាពចំពោះការអនុវត្តប្រកបដោយប្រសិទ្ធភាពនោះទេ សមត្ថភាពរបស់ក្រុមការងារពហុភាគីនៅតែមានកម្រិតក្នុងការ ឆ្លើយតបឲ្យបានប្រសើរ។

នៅក្នុងការពិនិត្យលើភស្តុតាម លោក Herbert and Bromfield [78] បានបង្ហាញថាក្រុមពហុភាគី( multi-disciplinary teams ) អាចមានប្រសិទ្ធិភាពក្នុងការកែលម្អលើការឆ្លើយតបផ្អែកយុត្តិធម៌ព្រហ្មទណ្ឌ និងសុខភាពផ្លូវចិត្តបើប្រៀបធៀបទៅនឹងការអនុវត្តជាស្តង់ដារធម្មតាមួយ ប៉ុន្តែលោកបានសង្កត់ធ្ងន់ថាប្រសិនបើមិនមានការអនុវត្តល្អ ឬក្រុមពហុភាគីមិនមានដំណើរការល្អនោះទេ វានឹងមិនទទួលបានលទ្ធផលជាវិជ្ជមាន ហើយអាចនឹងមានកម្រិតទាបជាងការអនុវត្តតាមស្តង់ដារធម្មតាទៅទៀត។ ចំណោទគឺនៅត្រង់ការបង្កើតក្រុមដ៏ប្រសើរបំផុត និងអ្វីដែលត្រូវត្រៀមឲ្យបានសមស្របដើម្បីបង្កើតក្រុមការងារដែលមានមានប្រសិទ្ធិភាព។[79]

[76] WHO (2016) "INSPIRE: Seven Strategies for Ending Violence Against Children" https://www.end-violence.org/sites/default/files/paragraphs/download/9789241565356-eng.pdf

[77] WHO (2018) INSPIRE Handbook: Action for Implementing the Seven Strategies for Ending Violence Against Children" https://www.who.int/publications/i/item/inspire-handbook-action-for-implementing-the-seven-strategies-for-ending-violence-against-children p.193

[78] Herbert & Bromfield (2017), Better Together? A Review of Evidence for Multi-Disciplinary Teams Responding to Physical and Sexual Child Abuse. Accessed December 2020 https://ncjtc-static.fvtc.edu/Resources/RS00004131.pdf

[79] ibid

បន្ថែមពីនេះ គួរតែមានការប្រុងប្រយ័ត្ននិងការគិតគូរឲ្យបានច្រើន នៅពេលព្យាយាមសម្របតាមគំរូដែលទទួលបានជោគជ័យក្នុងប្រទេសដែលមានប្រាក់ចំណូលខ្ពស់ ទៅជាគំរូរបស់ប្រទេសដែលមានប្រាក់ចំណូលមធ្យមកម្រិតទាប ចំពោះហេដ្ឋារចនាសម្ព័ន្ធ និងសមត្ថភាពស្ថាប័នខុសគ្នាក្នុងគោលបំណងដើម្បីធានានូវប្រសិទ្ធភាពរបស់គំរូ។ បច្ចុប្បន្ន ភាពជោគជ័យនៃមជ្ឈមណ្ឌលច្រកចេញចូលតែមួយ ភាគច្រើនត្រូវបានចងក្រងជាឯកសារនៅក្នុងប្រទេសដែលមានប្រាក់ចំណូលខ្ពស់ ដែលសុខុមាលភាពសង្គម សេវាសុខភាព និងប្រព័ន្ធយុត្តិធម៌ត្រូវបានគេប្រតិបត្តិយ៉ាងប្រសើរ និងរយៈពេលយូរកន្លងមកហើយ។ ដោយឡែក មានការវាយតម្លៃតិចទៅលើផលប៉ះពាល់ និងប្រសិទ្ធភាពនៃមជ្ឈមណ្ឌលច្រកចេញចូលតែមួយនៅក្នុងប្រទេសដែលមានប្រាក់ចំណូលមធ្យមកម្រិតទាប។ ការសិក្សារបស់ Olson et al [80] បានពិនិត្យលើប្រសិទ្ធភាពនៃការអនុវត្តនៅក្នុងប្រទេសដែលមានប្រាក់ចំណូលមធ្យមកម្រិតទាប ដែលជាការសិក្សាដំបូងបង្អស់ដើម្បីប្រមូលភស្តុតាងពីប្រទេសដែលមានប្រាក់ចំណូលមធ្យមកម្រិតទាប។ ការសិក្សានេះបានបង្ហាញថាមានឧបសគ្គចំនួន ១៥ ដែលរំខានដល់ការអនុវត្តឱ្យមានប្រសិទ្ធភាព  និងបានបង្ហាញថាប្រសិនបើឧបសគ្គទាំងនោះមិនត្រូវបានដោះស្រាយទេ នោះមានភស្តុតាងរឹងមាំដែលបង្ហាញថាមជ្ឈមណ្ឌលច្រកចេញចូលតែមួយនឹងមិនទទួលបានលទ្ធផលខ្ពស់នោះទេ។ កង្វះខាតបុគ្គលិក ឧបករណ៍មូលដ្ឋានមិនគ្រប់គ្រាន់ និងកង្វះថវិកាដែលមាននិរន្តរភាព ជាឧទាហរណ៍ បង្កការលំបាកក្នុងសម្រេចបាននូវការផ្លាស់ប្តូរសូម្បីតែក្នុងកម្រិតទាបក៏ដោយ ដែលរំខានដោយផ្ទាល់ដល់សមត្ថភាពក្នុងការសម្របសម្រួលប្រកបដោយប្រសិទ្ធភាព និងលទ្ធភាពក្នុងការទទួលបានសេវា និងដែលរារាំងដល់ការសម្រេចបានការផ្លាស់ប្តូរកម្រិតខ្ពស់ដូចដែលគំរូមជ្ឈមណ្ឌលច្រកចេញចូលតែមួយចង់បាន។ កត្តារាំងស្ទះផ្សេងទៀតរួមមានចំណេះដឹង អកប្បកិរិយា និងការប្រព្រឹត្តរបស់បុគ្គលិកដែលអាចប៉ះពាល់ផងដែរដល់ដំណើរការអនុវត្ត ព្រមទាំងកង្វះឆន្ទៈនយោបាយ និងការវិនិយោគរបស់រដ្ឋាភិបាលគឺជាឧបសគ្គចំបងបន្ថែមទៀត។

ខណៈឧបសគ្គទាំងនេះបង្អាក់ដល់ប្រសិទ្ធភាពនៃការឆ្លើយតបគ្រប់រូបភាព ឧបសគ្គដ៏ទៃទៀតជាច្រើនដែលអាចប៉ះពាល់ដល់ប្រសិទ្ធភាពនៃការឆ្លើយតប ដូចជាគំរូមជ្ឈមណ្ឌលច្រកចេញចូលតែមួយត្រូវចំណាយធនធានច្រើន ត្រូវការជំនាញឯកទេសខ្ពស់ក៏ដូចជាសេវាកម្មសម្របសម្រួលប្រកបដោយប្រសិទ្ធភាពផងដែរ ធានាឲ្យបាននូវសមត្ថភាពរឹងមាំសម្រាប់ការបង្កើតរបស់ខ្លួនគឺជាការចាំបាច់ដើម្បីធានាបានជោគជ័យ។ កិច្ចសហការរវាងក្រុមពហុជំនាញក៏ចាំបាច់ត្រូវកំណត់ឱ្យមានការតាំងចិត្តរួមក្នុងការផ្តល់សេវាដល់ជនរងគ្រោះជាការគិតគូរតែលើការសម្រេចប្រតិបត្តិការ។ បើតម្រូវការរបស់ជនរងគ្រោះមិនមែនជាចំណុចស្នូលរបស់ក្រុមពហុភាគីនោះទេ នោះមជ្ឈមណ្ឌលច្រកចេញចូលតែមួយនឹងមិនប្រសើរសំរាប់ការផ្តល់ការសេវាគាំទ្រដល់ជនរងគ្រោះឡើយ ។

80 Olson, R, Garcia-Moreno,. C, Columbini, M. (2020) The implementation and effectiveness of the one stop centre model for intimate partner and sexual violence in low- and middle- income countries: a systematic review of barriers and enablers https://gh.bmj.com/content/5/3/e001883



# មជ្ឈមណ្ឌលច្រកចេញចូលតែមួយនៅក្នុងបរិបទប្រចាំតំបន់ ឧទាហរណ៍ដែលបានជ្រើសរើសចេញពីតំបន់អាស៊ីអាគ្នេយ៍

**វិធានក្នុងការគោរពសិទ្ធិកុមារ និងការឆ្លើយតបបែបកុមារមេត្រីចំពោះជនរងគ្រោះដោយអំពើហិង្សានៅបណ្តាប្រទេសក្នុងតំបន់អាស៊ីភាគអាគ្នេយ៍ គឺស្រដៀងនឹងដំណោះស្រាយ និងការឆ្លើយតបនៅក្នុងប្រទេសកម្ពុជា ដែលហាក់មានការខុសគ្នាខ្លាំងពីសហរដ្ឋអាមេរិក ឬបណ្តាប្រទេស Nordic ដែលមជ្ឈមណ្ឌលច្រកចេញចូលតែមួយទីមួយដែលផ្តោតលើកុមារដំបូងគេត្រូវបានបង្កើតឡើង។**



ការពិនិត្យលើមជ្ឈមណ្ឌលច្រកចេញចូលតែមួយនៅក្នុងបរិបទប្រចាំតំបន់ ផ្តល់នូវការយល់ដឹងកាន់តែប្រសើរ ចំពោះការប្រៀបធៀបលើការអនុវត្ត និងលទ្ធភាពនៃការកែសម្រួលឲ្យសមស្របខណៈពេលពិនិត្យមើលបញ្ហាប្រឈមពាក់ព័ន្ធនានា។

ប្រទេសអាស៊ីអាគ្នេយ៍មួយចំនួនដូចជាប្រទេសថៃ ហ្វីលីពីន និងម៉ាឡេស៊ីបានអនុវត្តតាមអនុសាសន៍ស្តីពីការបង្កើតការឆ្លើយតបពហុភាគីចំពោះជនរងគ្រោះដោយអំពើហិង្សា ដែលភាគច្រើនជាទម្រង់មជ្ឈមណ្ឌលផ្តល់សេវាមួយដែលមានមូលដ្ឋាននៅតាមមន្ទីរពេទ្យដែលផ្តោតលើការឆ្លើយតបចំពោះស្រ្តី និងកុមារ ឬស្រ្តី និងកុមារី រួមជាមួយនឹងមជ្ឈមណ្ឌលតិចតួចដែលដឹកនាំដោយអង្គការក្រៅរដ្ឋាភិបាល ដែលត្រូវបានអភិវឌ្ឍជាពិសេសសម្រាប់កុមារ។ មជ្ឈមណ្ឌលរក្សាទំនាក់ទំនងរវាងពហុភាគី ជាមួយវិស័យផ្សេងៗដូចជា ផ្នែកអនុវត្តច្បាប់ ការប្រឹក្សានិងការគាំទ្រផ្នែកចិត្តសាស្រ្ត សេវាយុត្តិធម៌ និងសេវាផ្លូវច្បាប់នានា។ ភាពជោគជ័យនិងបញ្ហាប្រឈមនានាត្រូវបានកត់សម្គាល់ជាមួយនឹងការបញ្ជាក់ច្បាស់ចំពោះបរិបទក្នុងតំបន់អាស៊ីអាគ្នេយ៍៖

# ប្រទេសហ្វីលីពីន



**១០៦**

**អង្គភាពការពារស្ត្រី និងកុមារ**

**ក្នុងខេត្តចំនួន ៥៥**
**និងទីក្រុងចំនួន ១០**

មជ្ឈមណ្ឌលច្រកចេញចូលតែមួយដំបូងមួយ រួមជាមួយនឹងក្រុមពហុជំនាញ ដែលត្រូវបានបង្កើតឡើងនៅប្រទេសហ្វីលីពីន គឺនៅក្នុងអាគារនៃមន្ទីរពេទ្យ ដែលអាគារច្រកចេញចូលតែមួយនោះត្រូវបានគេហៅថា “The Pink House” ដែលត្រូវបានបង្កើតឡើងក្នុងឆ្នាំ១៩៩៦។ វាមានទីតាំងស្ថិតនៅក្នុងមជ្ឈមណ្ឌលវេជ្ជសាស្ត្រ Vicente Sotto ទីក្រុងសេប៊ូ ដោយក្រុមការងារអន្តរទីភ្នាក់ងារធ្វើការរួមគ្នាដើម្បីឆ្លើយតបនឹងសេចក្តីត្រូវការរបស់ស្ត្រី និងក្មេងស្រីដែលរងគ្រោះដោយអំពើហិង្សា។ ក្នុងអំឡុងពេលដំណើរទស្សនកិច្ចទៅកាន់មជ្ឈមណ្ឌលនេះ ដោយ បុគ្គលិកអង្គការសកម្មភាពដើម្បីកុមារ និងប្រតិភូរបស់ការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន បញ្ហាប្រឈមជាមួយនឹងការបង្កើតនៅឆ្នាំដំបូងៗត្រូវបានពិភាក្សា ហើយបញ្ហាទាំងអស់នោះត្រូវបានដោះស្រាយអស់រយៈពេលជាច្រើនឆ្នាំ។ កង្វះចំណេះដឹង និងការយល់ដឹងអំពីការអនុវត្តល្អបំផុតក្នុងការព្យាបាលជនរងគ្រោះពីសំណាក់ភាគីពាក់ព័ន្ធដែលបានចូលរួមក៏ជាបញ្ហាប្រឈមមួយ ដែលទាមទារឲ្យមានការបណ្តុះបណ្តាលរយៈពេលយូរ ដើម្បីឱ្យមានបុគ្គលិកដែលមានចំណេះដឹងគ្រប់គ្រាន់អំពីនីតិវិធី។ កិច្ចសហប្រតិបត្តិការ និងការសម្របសម្រួលរវាងអ្នកអនុវត្តមកពីវិស័យផ្សេងៗគ្នាក៏ត្រូវបានលើកឡើងថាជាបញ្ហាប្រឈមផងដែរ រួមជាមួយកិច្ចខិតខំប្រឹងប្រែងជាច្រើនដែលត្រូវការដើម្បីពង្រឹងទំនាក់ទំនងរវាងទីភ្នាក់ងារទាំងឡាយ។ យ៉ាងណាក្តី ការវិនិយោគអស់ជាច្រើនឆ្នាំលើការពង្រឹងសមត្ថភាព និងការតស៊ូមតិដើម្បីធ្វើវិសោធនកម្មច្បាប់ក្នុងការលើកកម្ពស់ការឆ្លើយតបបែបកុមារមេត្រីបានបង្ហាញថាមានប្រសិទ្ធភាព។ ឥឡូវនេះវាត្រូវបានគេចាត់ទុកថាជាឧទាហរណ៍ឈានមុខគេមួយនៅក្នុងប្រទេសដែលផ្តល់ការថែទាំឯកទេស ដោយជនរងគ្រោះកាន់តែច្រើនទទួលបានការគាំទ្រ និងការឆ្លើយតបដែលមានលក្ខណៈប្រសើរឡើង រួមជាមួយនឹងលទ្ធផលខ្ពស់។

បច្ចុប្បន្ននៅក្នុងប្រទេសហ្វីលីពីន មានអង្គភាពការពារស្ត្រី និងកុមារចំនួន ១០៦  នៅក្នុងខេត្តចំនួន ៥៥ និងទីក្រុងចំនួន ១០ ហើយភាគច្រើនត្រូវបានរៀបចំនៅក្នុងមន្ទីរពេទ្យរដ្ឋ មានជាច្រើនដែលរួមបញ្ចូលទាំងមជ្ឈមណ្ឌលច្រកចេញចូលតែមួយ។ អង្គភាពទាំងនោះផ្តល់ការឆ្លើយតបបែបពហុភាគីដើម្បីជួយកុមារ និងស្ត្រីដែលរងគ្រោះដោយអំពើហិង្សាហើយជាធម្មតាមានក្រុមកាងារដូចជា វេជ្ជបណ្ឌិត បុគ្គលិកសង្គម ចិត្តវិទូ និងមន្ត្រីនគរបាល និងពេលខ្លះមានមេធាវីដែលធ្វើការជារៀងរាល់ថ្ងៃ ២៤ម៉ោង លើ២៤ម៉ោង ហើយសេវាកម្មដែលផ្តល់ដោយអង្គភាពការពារស្ត្រី និងកុមារ ដល់ជនរងគ្រោះគឺមិនគិតថ្លៃទេ។ ខណៈពេលអង្គភាពការពារស្ត្រីនិងកុមារ ឆ្លើយតបទាំងករណីអំពើហិង្សាលើកុមារ និងអំពើហិង្សាលើស្ត្រី នោះពុំមានការធ្វើសមាហរណកម្មផ្លូវការ ឬបែបពិធីការរវាងសេវាកម្មទាំងនេះទេក្រៅពីបុគ្គលិកដដែលធ្វើការពិនិត្យតាមដាន ករណីទាំងពីរប្រភេទនេះ។ [81]

សមាជិក WSPU ចូលរួមការប្រជុំជាមួយក្រុមពហុជំនាញ និងបម្រើការជាអ្នកទំនាក់ទំនងរវាងអ្នកផ្តល់សេវាថែទាំសុខភាព និងសេវាការពារកុមារ នាយកដ្ឋាននគរបាល មេធាវីថ្នាក់ស្រុក និងទីភ្នាក់ងារសហគមន៍ផ្សេងទៀត។ សមាជិក WSPU ក៏នឹងបង្ហាញខ្លួននៅក្នុងនីតិវិធីរបស់តុលាការ ឬជួយរៀបចំអ្នកជំនាញថែទាំសុខភាពផ្សេងទៀតសម្រាប់សក្ខីកម្មរបស់តុលាការ ហើយអត្រានៃការកាត់ទោសធ្ងន់ធ្ងរត្រូវបានគេកត់សម្គាល់ចាប់តាំងពីការបង្កើតអង្គភាពមក។

81 UNICEF EAPRO (2020) “Ending Violence Against Women and Children in the Philippines: Opportunities and Challenges for Collaborative and Integrative Approaches https://reliefweb.int/sites/reliefweb.int/files/resources/ending__violence__against__women__and__children__in__philippines__-__report.pdf

# ប្រទេសថៃ




មជ្ឈមណ្ឌលវិបត្តិច្រកចេញចូលតែមួយ( OSCCs ) ដែលមានមូលដ្ឋាននៅក្នុងមន្ទីរពេទ្យទីមួយត្រូវបានដំណើរការសាកល្បងនៅក្នុងប្រទេសក្នុងឆ្នាំ ១៩៩៩ ដើម្បីផ្តល់ការគាំទ្រដល់ស្ត្រី និងក្មេងស្រី ហើយចាប់តាំងពីពេលនោះមក ត្រូវបានពង្រីក និងគ្រប់ដណ្តប់យ៉ាងទូលំទូលាយក្នុងប្រទេស ដោយមានការគាំទ្រពីក្រសួងសុខាភិបាលសាធារណៈ ដែលមានចំនួនរហូតដល់២០មជ្ឈមណ្ឌលគិតត្រឹមឆ្នាំ២០០២។ ការប៉ាន់ប្រមាណក្នុងឆ្នាំ២០០៤ បង្ហាញថាមានតែ៥មជ្ឈមណ្ឌលប៉ុណ្ណោះដែលប្រតិបត្តិប្រកបដោយប្រសិទ្ធភាព ខណៈដែលមជ្ឈមណ្ឌលចំនួន ៧ ត្រូវការការបណ្តុះបណ្តាល និងការពង្រីកបណ្តាញបន្ថែម ហើយមជ្ឈមណ្ឌលចំនួន ៨ ទៀតត្រូវបានចាត់ទុកថានៅក្នុងដំណាក់កាលដំបូង[82]។ ចំណុចសំខាន់ដែលត្រូវបានកត់សម្គាល់ គឺការបណ្តុះបណ្តាលដែលផ្តោតលើបញ្ហាបច្ចេកទេស ប៉ុន្តែត្រូវមានការផ្លាស់ប្តូរអាកប្បកិរិយារបស់បុគ្គលិកចំពោះការព្យាបាលជនរងគ្រោះឲ្យយកចិត្តទុកដាក់បន្ថែមចំពោះយេនឌ័រ និងឲ្យមានលក្ខណៈកុមារមេត្រី ហើយត្រូវបានគេកត់សម្គាល់ឃើញថាការផ្លាស់ប្តូរអាកប្បកិរិយាជាធម្មតា ជាអ្វីដែលបានចំណាយពេលច្រើនបំផុត ទម្រាំឃើញមានភាពប្រសើរឡើង[83]។ កង្វះការសហការរឹងមាំ ទាំងនៅក្នុងមន្ទីរពេទ្យ និងក្រៅមន្ទីរពេទ្យ គឺជាកត្តាចម្បងដែលនាំឱ្យមានការបរាជ័យនៅក្នុងការបង្កើតមជ្ឈមណ្ឌលច្រកចេញចូលតែមួយ ដែលភាគច្រើនទាក់ទងទៅនឹងការបណ្តុះបណ្តាល និងលើកកម្ពស់មិនគ្រប់គ្រាន់លើការយល់ដឹងរបស់បុគ្គលិកសុខាភិបាលដែលពាក់ព័ន្ធ [84]។ សេវាកម្មត្រូវបានគេចាត់ទុកថាមានប្រសិទ្ធភាពជាងមុនប្រសិនបើត្រូវបានបញ្ចូលទៅក្នុងសេវាកម្មមន្ទីរពេទ្យធម្មតា ជាជាងត្រូវបានផ្តល់ជាសេវាដាច់ដោយឡែក "ដាច់តែឯង" នៅក្នុងមន្ទីរពេទ្យ [85]។

ក្រោយមក មជ្ឈមណ្ឌលវិបត្តិច្រកចេញចូលតែមួយដែលបំពាក់ដោយបច្ចេកវិទ្យាព័ត៌មានវិទ្យាត្រូវបានដំណើរការនៅឆ្នាំ ២០១៣ ក្រោមគំនិតផ្តួចផ្តើមរបស់ COMMIT ដោយមានកិច្ចសហការរវាងរាជរដ្ឋាភិបាលប្រទេសថៃ និងអង្គការ UN Women ។ មជ្ឈមណ្ឌលច្រកចេញចូលតែមួយមានគោលបំណងផ្តល់សេវាកម្មដល់កុមារ ស្ត្រី មនុស្សចាស់ជរា និងជនមានពិការភាពដែលប្រឈមនឹងការជួញដូរមនុស្ស អំពើហិង្សាផ្អែកលើយេនឌ័រ ពលកម្មកុមារ និងការមានផ្ទៃពោះវ័យជំទង់។ គំនិតផ្តួចផ្តើមនេះមានបណ្តាញទូរស័ព្ទទាន់ហេតុការណ៍មួយដែលគ្រប់គ្រងដោយបុគ្គលិកដែលបានទទួលការបណ្តុះបណ្តាល និងមានអ្នកបកប្រែភាសារបស់

---

82 Grisurapong, S. (2004) “Health Sector Responses to Violence Against Women in Thailand”
https://www.researchgate.net/publication/49735759_Health_sector_responses_to_violence_against_women_in_Thailand

83 ibid

84 ibid

85 ibid

ប្រទេសជិតខាង មានបណ្តាញមួយដែលមានមជ្ឈមណ្ឌលចំនួន ២២.០០០ កន្លែងនៅទូទាំងប្រទេស និងមានអង្គភាពចល័តចំនួន ១៣០០ ទូទាំងសហគមន៍ [86]។

មុខងារសំខាន់ៗរបស់មជ្ឈមណ្ឌលច្រកចេញចូលតែមួយ រួមមាន ប្រព័ន្ធទិន្នន័យដោយប្រព័ន្ធកុំព្យូទ័រមួយដែលអនុញ្ញាតឱ្យមានការប្រមូលព័ត៌មានសម្រាប់បំរើឱ្យមជ្ឈមណ្ឌលច្រកចេញចូលតែមួយប្រើប្រាស់ និងដើម្បីធានាឲ្យបាននូវភាពប្រសើរឡើងនៃការឆ្លើយតប និងប្រសិទ្ធភាពនៃមជ្ឈមណ្ឌល[87]។ ការពង្រឹងសេវាកម្ម និងកិច្ចសហការផ្តល់នូវសមិទ្ធិផល និងប្រសិទ្ធភាព ពាក់ព័ន្ធនឹងការថែទាំពេញលេញដែលជនរងគ្រោះទទួលបាននាពេលបច្ចុប្បន្ន។

អង្គការក្រៅរដ្ឋាភិបាលមួយចំនួនក៏បានបង្កើតនូវគំរូច្រកចេញចូលតែមួយ ដែលផ្តោតលើការឆ្លើយតបជាពិសេសចំពោះកុមារ ដូចជា  មជ្ឈមណ្ឌលតស៊ូមតិសម្រាប់កុមារដែលបង្កើតឡើងដោយមូនិធិ A២១ នៅប៉ាតាយ៉ា។ ក្រុមពហុជំនាញរួមមានចិត្តវិទូ បុគ្គលិកសង្គម ព្រះរាជអាជ្ញា គ្រូពេទ្យខាងកោសល្យវិច្ច័យ និងនគរបាលស៊ើបអង្កេត ដែលពិភាក្សារឿងក្តីជាមួយគ្នា និងចែករំលែកព័ត៌មានពាក់ព័ន្ធទាក់ទងនឹងរឿងក្តី ដើម្បីធានាថាកុមារទទួលបានការគាំទ្រដែលពួកគេត្រូវការ ហើយភស្តុតាងនោះត្រូវបានធានាសុវត្ថិភាព ដើម្បីជួយក្នុងអំឡុងពេលផ្តន្ទាទោសជនល្មើស។

ក្នុងអំឡុងពេលដំណើរទស្សនកិច្ចសិក្សារបស់អង្គការសកម្មភាពដើម្បីកុមារ ( APLE Cambodia ) និង ប្រតិភូរបស់នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន ក្នុងគោលបំណងសិក្សារៀនសូត្រពីការអនុវត្តល្អៗ ខ្សែអាត់ថតសំឡេងត្រូវបានលើកឡើងថាត្រូវបានប្រើជាភស្តុតាងក្នុងអំឡុងពេលជំនុំជម្រះភាគច្រើនក្នុងរឿងក្តី ដែលពាក់ព័ន្ធនឹងជនល្មើសបរទេស និងនៅក្នុងតុលាការអន្តរជាតិជាជាងរឿងក្តីក្នុងស្រុក ។ ទោះជាយ៉ាងណាក្តី ខ្សែអាត់ថតសំឡេងនៅតែត្រូវបានប្រើប្រាស់ដើម្បីកាត់បន្ថយចំនួនដងដែលកុមារត្រូវនិយាយរៀបរាប់រឿងរបស់ពួកគេម្តងទៀតក្នុងដំណាក់កាលផ្សេងទៀតក្នុងគោលបំណងបន្ថយបទពិសោធន៍ប៉ះទង្គិចផ្លូវចិត្តរបស់ពួកគេ និងបង្ការការរងគ្រោះឡើងវិញ។ មជ្ឈមណ្ឌលតស៊ូមតិសម្រាប់កុមារនៅប៉ាតាយ៉ា ត្រូវបានបង្កើតឡើងក្នុងឆ្នាំ ២០១៧ ច្រើនឆ្នាំបន្ទាប់ពីមជ្ឈមណ្ឌលច្រកចេញចូលតែមួយ ដែលដឹកនាំដោយរដ្ឋាភិបាលត្រូវបានបង្កើតឡើងនៅតាមមន្ទីរពេទ្យរដ្ឋ ហើយក្រុមពហុជំនាញដែលឆ្លើយតបទៅនឹងអំពើហិង្សាលើស្រ្តី និងកុមារគឺជាក្រុមឆ្លើយតបរួមមួយក្នុងការជួយជនរងគ្រោះ ។ មជ្ឈមណ្ឌលតស៊ូមតិសម្រាប់កុមារនៅប៉ាតាយ៉ាបានបង្ហាញពីជោគជ័យជាច្រើនក្នុងការឆ្លើយតបចំពោះកុមារ ដោយការអនុវត្តបែបកុមារមេត្រី និងសិទ្ធិទទួលបានយុត្តិធម៌បែបកុមារមេត្រីត្រូវបានលើកកម្ពស់។

86 UN Women, Press Release April 10, 2013, “ Thailand Launches One Stop Crisis Centre to Respond to Violence Against Women” https://www.unwomen.org/en/news/stories/2013/4/thailand-launches-one-stop-crisis-centre-to-respond-to-violence-against-women#:~:text=The%20One%20Stop%20Crisis%20Centre,coordinate%20responses%20between%20Government%20agencies.

87 ibid

# ប្រទេសកម្ពុជា

ទោះបីមិនទាន់មានផែនការរបស់រដ្ឋាភិបាល ក្នុងការបង្កើតមជ្ឈមណ្ឌលច្រកចេញចូលតែមួយជាពិសេសសម្រាប់កុមារក៏ដោយ ក៏ការបង្កើតមជ្ឈមណ្ឌលច្រកចេញចូលតែមួយស្ថិតក្នុងការពិចារណាក្នុងគោលបំណងឆ្លើយតបទៅនឹងស្ត្រី និងក្មេងស្រីរងគ្រោះដោយសារអំពើហិង្សាកាលពីអតីតកាលហើយត្រូវបានដាក់បញ្ចូលជាយុទ្ធសាស្ត្រមួយនៅក្នុងផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រី ២០១៤-២០១៨ ។ ប៉ុន្តែមជ្ឈមណ្ឌលច្រកចេញចូលតែមួយស្ថិតក្នុងដំណើរការពិចារណាឡើងវិញ ដោយសារតែមណ្ឌលសុខភាពមានទំហំតូច កង្វះការគាំទ្រផ្នែកហិរញ្ញវត្ថុ និងចំនួនករណីមានកម្រិតទាបនៅក្នុងខេត្តមួយចំនួន ដែលចោទជាសំណួរថាជាការសម្រេចត្រឹមត្រូវ ឬអត់ក្នុងការចាត់តាំងបុគ្គលិកពិសេសសម្រាប់គោលបំណងបែបនោះនៅពេលបុគ្គលិកមានចំនួនតិចរួចស្រាប់ទៅហើយ [88] ។

នៅក្នុងការស្រាវជ្រាវមួយដែលធ្វើឡើងដោយអង្គការ RHAC អ្នកតំណាងមកពីក្រសួងសុខាភិបាលបានលើកឡើងថា "ប្រសិនបើយើងបង្កើតមជ្ឈមណ្ឌលច្រកចេញចូលតែមួយ យើងត្រូវពិចារណាថាតើវានឹងផ្តល់ប្រសិទ្ធភាពដល់សហគមន៍យ៉ាងដូចម្តេចពីព្រោះមានតែពីរបីករណីប៉ុណ្ណោះ ក្នុងរយៈពេលពីរបីខែហើយយើងត្រូវការចំណាយលើមន្ត្រីជាច្រើនមកពីវិស័យផ្សេងៗគ្នាដើម្បីប្រចាំការនៅទីនោះជារៀងរាល់ថ្ងៃ"[89] ។

ថ្វីបើពុំមានមជ្ឈមណ្ឌលច្រកចេញចូលតែមួយ ដែលដឹកនាំដោយរដ្ឋាភិបាល ដើម្បីដោះស្រាយសេចក្តីត្រូវការរបស់កុមារដែលរងផលប៉ះពាល់ដោយអំពើហិង្សាក៏ដោយ ក៏អង្គការក្រៅរដ្ឋាភិបាលដូចជាមូនិធិ A21 បានសាកល្បងដំណើរការមជ្ឈមណ្ឌលតស៊ូមតិសម្រាប់កុមារដំបូងគេនៅកម្ពុជាក្នុងឆ្នាំ ២០១៩ ដែលជាការព្យាយាមមួយក្នុងការផ្តល់សេវាកម្មពហុជំនាញដល់កុមាររងគ្រោះដោយអំពើហឹង្សានិងការជួញដូរដើម្បីបន្តស្វែងរកយុត្តិធម៌។ មជ្ឈមណ្ឌលនេះគឺជាទីតាំងដែលដឹកនាំដោយអង្គការក្រៅរដ្ឋាភិបាល ដែលមានបំពាក់បរិក្ខារ



## មជ្ឈមណ្ឌលតស៊ូមតិ សម្រាប់កុមារដំបូងគេ

### ត្រូវបានសាកល្បងក្នុងឆ្នាំ ២០១៩

យ៉ាងល្អ រួមមានបន្ទប់ជាច្រើនដែលត្រូវបានរៀបចំសម្រាប់ដំណាក់កាលផ្សេងៗគ្នានៃការឆ្លើយតបចំពោះកុមារក្នុងនីតិវិធីយុត្តិធម៌ព្រហ្មទណ្ឌ។ បន្ទប់ទាំងនេះរួមបញ្ចូលទាំង៖

- **បន្ទប់ព្យាបាល** ជាបន្ទប់ដំបូងដែលកុមារចូលកន្លែងដែលបុគ្គលិកសង្គមនឹងវាយតម្លៃស្ថានភាពកុមារនិងថាតើពួកគេអាចផ្តល់បទសម្ភាសន៍បានដែរឬទេ។ បុគ្គលិកសង្គមនឹងធ្វើការដើម្បីបន្ធូរបន្ថយភាពតានតឹងរបស់កុមារ និងធានាថាពួកគេមានអារម្មណ៍ស្រួលចិត្ត។
- **បន្ទប់សម្ភាសន៍** ដែលជាកន្លែងបទសម្ភាសន៍ជាមួយកុមារត្រូវបានធ្វើឡើងដោយអ្នកឯកទេសដែលបានបណ្តុះបណ្តាលអំពីបច្ចេកទេសធ្វើបទសម្ភាសន៍បែបកុមារមេត្រី និងត្រូវបំពាក់ជាមួយឧបករណ៍ថតសំឡេង។ បន្ទប់នេះត្រូវបានតុបតែងជាមួយប្រដាប់ប្រដាក្មេងលេង និងគ្រឿងសង្ហារឹមដែលសមស្របតាមអាយុ និងការអភិវឌ្ឍរបស់កុមារ។
- **បន្ទប់ស៊ើបអង្កេត** ដែលត្រូវបានភ្ជាប់ជាមួយបន្ទប់សម្ភាសន៍ដោយអេក្រង់ ដើម្បីអនុញ្ញាតឱ្យអ្នកអនុវត្តច្បាប់ តួរអង្គយុត្តិធម៌ ដូចជាមន្ត្រីអនុវត្តច្បាប់ ព្រះរាជអាជ្ញា ឬអាណាព្យាបាលកុមារមើលការសម្ភាសន៍ដែលបានធ្វើឡើងជាមួយកុមារ។
- **បន្ទប់ប្រជុំ** ដើម្បីឱ្យក្រុមពហុភាពីពិភាក្សាគ្នាអំពីរឿងក្តីជាមួយគ្នា និងវាយតម្លៃអំពីវិធីល្អបំផុតក្នុងការបន្តទៅមុខ និងសេវាបញ្ជូនបន្តដែលចាំបាច់។

88 RHAC (2018) “Sexual and Gender Based Violence: A Monitoring Assessment against National Strategic Framework and National Action Plan 2014-2018 of Ministry of Women’s Affairs in Cambodia” https://arrow.org.my/wp-content/uploads/2019/04/RHAC-final-ICPD25-Monitoring-and-Research-Report-Jan-28-2018-RS.pdf

89 ibid

បុគ្គលិកដែលត្រូវបានជួលដោយអង្គការមិនមែនរដ្ឋាភិបាល ភាគច្រើនបម្រើការជាបុគ្គលិកសង្គមកិច្ច ដើម្បីជួយដល់តម្រូវការខាងចិត្តសាស្ត្រ ខណៈពេលដែលពួកគេសហការជាមួយដៃគូដទៃទៀតសម្រាប់សេវាកម្មផ្នែកច្បាប់និងភ្ជាប់ទំនាក់ទំនងជាមួយមន្ត្រីអនុវត្តច្បាប់ និងតួអង្គយុត្តិធម៌។ នៅក្នុងទីតាំង ពុំមានជម្រើសផ្តល់ការថែទាំវេជ្ជសាស្ត្រនោះទេ ដូចនេះពេលខ្លះកុមារនឹងត្រូវនាំទៅមន្ទីរពេទ្យដោយបុគ្គលិកដែលបានចាត់តាំងប្រសិនបើត្រូវការការពិនិត្យវេជ្ជសាស្ត្រ ។

ទោះបីជាមានសក្តានុពលខ្លាំងសម្រាប់មជ្ឈមណ្ឌលតស៊ូមតិសម្រាប់កុមារនៅខេត្តសៀមរាប ដើម្បីធ្វើឱ្យប្រសើរឡើងនូវសិទ្ធិទទួលបានយុត្តិធម៌ និងផ្តល់សេវាកម្មឆ្លើយតបកាន់តែប្រសើរសម្រាប់កុមារក៏ដោយ ក៏ចាប់តាំងពីការបង្កើតមជ្ឈមណ្ឌលមក ពួកគេបានជួបប្រទះបញ្ហាប្រឈមជាច្រើនដែលបង្អាក់មជ្ឈមណ្ឌលពីការសម្រេចគោលដៅរបស់ខ្លួន។ បញ្ហាប្រឈមចម្បងមួយគឺកិច្ចសហប្រតិបត្តិការមានកម្រិតរបស់មន្ត្រីអនុវត្តច្បាប់ និងតួអង្គយុត្តិធម៌ក្នុងដំណើរការ ហើយពួកគេមិនពេញចិត្តនឹងការធ្វើបទសម្ភាសន៍ដែលត្រូវបានថតទុកឡើយ ។ មន្ត្រីអនុវត្តច្បាប់ជាធម្មតាចូលចិត្តធ្វើបទសម្ភាសន៍នៅក្នុងទីតាំងដែលងាយស្រួលសម្រាប់ពួកគេជាជាងសម្របសម្រួលពេលវេលាសមស្របមួយ ដែលសមនឹងមកដល់មជ្ឈមណ្ឌលតស៊ូមតិសម្រាប់កុមារ ជាពិសេសដោយសារពួកគេត្រូវបានតម្រូវដោយច្បាប់ឲ្យធ្វើការបទសម្ភាសន៍ជាមួយកុមារមិនយូរជាង ៧២ម៉ោង គិតចាប់ពីពេលកសាងសំណុំរឿង និងឃាត់ខ្លួនជនសង្ស័យ។

ឧបសគ្គខ្លះៗចំពោះកិច្ចសហប្រតិបត្តិការគឺ មន្ត្រីអនុវត្តច្បាប់ និងតួអង្គយុត្តិធម៌នឹងធ្វើប្រតិបត្តិការតែនៅពេលមានការអនុញ្ញាតពីរដ្ឋាភិបាល ហើយដោយសារមជ្ឈមណ្ឌលតស៊ូមតិសម្រាប់កុមារត្រូវបានដឹកនាំដោយអង្គការមិនមែនរដ្ឋាភិបាល ដូចនេះពួកគេមិនមានឆន្ទៈក្នុងការសហការនោះទេ នៅពេលដែលចំណាត់ការរបស់ពួកគេមិនត្រូវបានទទួលស្គាល់យោងតាមនីតិវិធីរបស់រដ្ឋាភិបាល[90]។ ភាគីពាក់ព័ន្ធមកពីស្ថាប័នរាជរដ្ឋាភិបាល និងមិនមែនរដ្ឋាភិបាលបានសម្តែងថាមជ្ឈមណ្ឌលច្រកចេញចូលតែមួយត្រូវតែដឹកនាំដោយរដ្ឋាភិបាលដើម្បីធានាបាននូវការចូលរួមរបស់អ្នកដែលពាក់ព័ន្ធ ខណៈពេលដែលចាត់ទុកអង្គការមិនមែនរដ្ឋាភិបាលជាដៃគូសហការដែលអាចជាប្រភពធនធានបច្ចេកទេស និងហិរញ្ញវត្ថុ។

ថ្វីបើមានការអះអាងពីការគាំទ្រគំនិតនៃការឆ្លើយតបពហុភាគីក៏ដោយ ក៏ក្នុងបទសម្ភាសន៍មួយជាមួយស្នងការរងនៃស្នងការដ្ឋាននគរបាលខេត្តសៀមរាប នាងក៏បានបង្ហាញពីការលំបាកដែលត្រូវផ្លាស់ប្តូរនីតិវិធីបច្ចុប្បន្ន៖




នៅដំណាក់កាលសម្ភាសន៍ដំបូង តើយើងត្រូវអញ្ជើញភាគីពាក់ព័ន្ធផ្សេងទៀតមកចូលរួមដែរឬទេ? យើងមិនចង់ធ្វើដូចនោះទេ។ ចំពោះបទសម្ភាសន៍ដំបូងជាមួយនគរបាល ប្រសិនបើភាគីពាក់ព័ន្ធផ្សេងទៀតចូលរួមហើយយើងមិនបានបញ្ចប់នីតិវិធីរបស់យើងនោះទ តើព្រះរាជអាជ្ញាអាចមក យ៉ាងដូចម្តេច ជាឧទាហរណ៍?

បញ្ហាប្រឈមផ្សេងទៀតជាមួយនឹងការអនុវត្តមជ្ឈមណ្ឌលតស៊ូមតិសម្រាប់កុមារ រួមមានការលំបាកក្នុងការទទួលបាន និងថែរក្សាឧបករណ៍ ក៏ដូចជាយឺតយ៉ាវក្នុងការបណ្តុះបណ្តាលបុគ្គលិកសំខាន់ៗដែលត្រូវធ្វើការសម្ភាសកុមារបែបកុមារមេត្រី និងសម្រាប់ផ្តល់ជំនាញឯកទេសក្នុងដំណើរការព្យាបាល។ បញ្ហាប្រឈមមួយទៀតដែលបានលើកឡើងគឺការលំបាកក្នុងការធានាឲ្យបានថាកុមារដែលពួកគេជួយត្រូវបានកំណត់អស់ ដោយសារកុមារនិងគ្រួសារជាច្រើនចង់ដោះស្រាយក្រៅតុលាការជាជាងបន្តនីតិវិធីច្បាប់។

90 At the time of writing this report, A21 was in the process of signing an MoU with MoI and MoJ and was further advocating for the approval of recordings to be considered as evidence in court with the hope that this will strengthen cooperation of law enforcement and justice actors.

# កិច្ចពិភាក្សា



ដូចដែលរបកគំហើញនៃការស្រាវជ្រាវនេះបានបង្ហាញ ទោះបីមានការប្រសើរឡើងចំពោះការបញ្ចូលនូវការគោរពសិទ្ធិរបស់កុមារនៅក្នុងនីតិវិធីយុត្តិធម៌ព្រហ្មទណ្ឌនៅប្រទេសកម្ពុជាក៏ដោយ ក៏គម្លាតនិងចន្លោះខ្វះខាតដែលមានទំហំធំនៅតែមានដដែល។ ខណៈពេលដែលគំរូមជ្ឈមណ្ឌលច្រកចេញចូលតែមួយគឺជាដំណោះស្រាយដែលគេទទួលស្គាល់ថាត្រូវបានប្រើដើម្បីពង្រឹងដំណើរនីតិវិធីក្នុងការតុលាការ គាំទ្រកុមារយ៉ាងពេញលេញ ប៉ុន្តែប្រសិទ្ធភាពនៃការអនុវត្តនៅតែអាស្រ័យទៅលើភាពខ្លាំង និងប្រសិទ្ធភាពនៃប្រព័ន្ធច្បាប់ នីតិវិធី ប្រព័ន្ធ និងឆន្ទៈរបស់ភាគីពាក់ព័ន្ធទាំងអស់។

**ការបង្កើតមជ្ឈមណ្ឌលច្រកចេញចូលត្រូវការធនធានច្រើន ដែលទាមទារឱ្យមានកិច្ចសហប្រតិបត្តិការ និងការលើកទឹកចិត្តពីទីភ្នាក់ងារ និងអ្នកផ្តល់សេវាផ្សេងៗក្រោមយន្តការដែលមានការសម្របសម្រួលល្អមួយ។ ឆន្ទៈ និងការលើកទឹកចិត្តចំពោះប្រព័ន្ធបែបកុមារមេត្រីដែលធានាការការពារសិទ្ធិគ្រប់ដំណាក់កាលនៃនីតិវិធីគឺជាកត្តាចាំបាច់ដែលត្រូវមានជាមុន។**

ឧទាហរណ៍ ផ្ទះគំរូ Barnahus ដែលត្រូវបានបង្កើតឡើងនៅ Scandinavia អាចបញ្ជាក់ពីភាពជោគជ័យរបស់ខ្លួនបានក៏អាចមកពីប្រព័ន្ធការពារកុមារដែលរឹងមាំ ដែលសិទ្ធិរបស់កុមារត្រូវបានគេទទួលស្គាល់ និងផ្តល់អាទិភាពនៅក្នុងនីតិវិធីជាតិ។ ការអនុវត្តគំរូគឺជាជំហានចុងក្រោយនៃដំណើរការរយៈពេលវែងទាំងកម្រិតវប្បធម៌ និងកម្រិតសមត្ថភាពស្ថាប័នឆ្លើយតបនឹងអំពើហិង្សា និងការរំលោភបំពានលើកុមារ។ គំរូនេះមិនមែនជាអ្វីដែលបានបង្កើតការផ្លាស់ប្តូរក្នុងការឆ្លើយតបចំពោះកុមារទេ ប៉ុន្តែបានធ្វើជាកត្តាជម្រុញការផ្តល់ការគាំទ្រផ្នែកច្បាប់ និងការផ្លាស់ប្តូរកំរិតស្ថាប័នដែលដែលត្រូវបានអនុវត្តរួចហើយ [៩១]។

ឧទាហរណ៍ដែលបានផ្តល់ពីប្រទេសថៃ និងហ្វីលីពីនបង្ហាញថាប្រទេសទាំងពីរបានបង្កើតមជ្ឈមណ្ឌលច្រកចេញចូលតែមួយលើកដំបូងមុនពេលសមត្ថភាពស្ថាប័នមានភាពរឹងមាំគ្រប់គ្រាន់ ហើយមុនពេលឥរិយាបថចំពោះនីតិវិធីបែបកុមារមេត្រីមានលក្ខណៈសមស្របត្រឹមត្រូវ ។ ការនេះបានជះឥទ្ធិពលដោយផ្ទាល់ទៅលើប្រសិទ្ធភាពនៃការអនុវត្តក្នុងឆ្នាំដំបូងៗ។ ខណៈពេលបច្ចុប្បន្នអត្រាជោគជ័យនៃមជ្ឈមណ្ឌលច្រកចេញចូលតែមួយ និងការឆ្លើយតបរបស់ពហុភាគីនៅក្នុងប្រទេសទាំងនោះខ្ពស់ជាងមុន នេះគឺដោយសារតែកិច្ចខិតខំប្រឹងប្រែងអស់ជាច្រើនឆ្នាំ និងការវិនិយោគជាយុទ្ធសាស្ត្រឆ្ពោះទៅរកការផ្លាស់ប្តូរគោលនយោបាយ នីតិវិធី និងការពង្រឹងសមត្ថភាពក្នុងការអនុវត្តនីតិវិធីឱ្យកាន់តែមានប្រសិទ្ធភាព។

---

91 Johansson, S. (2019) “Policy-making for the Diffusion of Social Innovations: the Case of the Barnahus Model in the Nordic Region and the Broader European Context” https://www.researchgate.net/publication/332129769_Policy-making_for_the_diffusion_of_social_innovations_the_case_of_the_Barnahus_model_in_the_Nordic_region_and_the_broader_European_context

ដោយសារភស្តុតាងនៃការសិក្សានេះបង្ហាញថា នៅតែមានឧបសគ្គជាច្រើនទាក់ទងនឹងនិតិវិធីយុត្តិធម៌ព្រហ្មទណ្ឌ និងសមត្ថភាពស្ថាប័ននៅក្នុងប្រទេសកម្ពុជា នោះមជ្ឈមណ្ឌលច្រកចេញចូលតែមួយប្រហែលលមិនអាចទទួលបាននូវលទ្ធផលដែលចង់បាននោះទេ លើកលែងតែឧបសគ្គទាំងនោះត្រូវបានដោះស្រាយ ។ រាជរដ្ឋាភិបាលកម្ពុជាបានបង្ហាញការប្តេជ្ញាចិត្តឆ្ពោះទៅរកការលើកកម្ពស់ការទប់ស្កាត់អំពើហិង្សាលើកុមារដល់ថ្នាក់កំពូលនៃរបៀបវារៈរបស់ពួកគេដែលមានលក្ខណៈជាការជម្រុញទឹកចិត្ត ប៉ុន្តែបច្ចុប្បន្ននេះការផ្តោតលើការរំលោភបំពាន និងកេងប្រវ័ញ្ចផ្លូវភេទកុមារនៅមានកម្រិតហើយការអនុវត្តច្បាប់ និងនីតិវិធីដូចជាការដាក់បញ្ចូលការអនុវត្តបែបកុមារមេត្រីនៅក្នុងនីតិវិធីយុត្តិធម៌កំពុងតែមានការយឺតៗយ៉ាវនៅឡើយ ។

ធនធានមនុស្ស ធនធានហិរញ្ញវត្ថុ និងចំណេះដឹងបច្ចេកទេសដែលមានបច្ចុប្បន្ននៅតែជាឧបសគ្គចម្បង។ ទោះបីជាអង្គការមិនមែនរដ្ឋាភិបាលអាចផ្តល់ជំនួយផ្នែកហិរញ្ញវត្ថុ និងបច្ចេកទេសមួយចំនួនយោងទៅតាមជំនាញក៏ដោយ ក៏នៅតែមានការខ្វះខាតធនធានមនុស្ស និងបុគ្គលិកជំនាញដែលមានចំណេះដឹងផ្នែកបច្ចេកទេសក្នុងផ្នែកដោះស្រាយបញ្ហាទាក់ទងនឹងកុមារដែលរងផលប៉ះពាល់ដោយការរំលោភបំពាន និងកេងប្រវ័ញ្ចផ្លូវភេទ នៅគ្រប់ផ្នែកទាំងអស់នៃនីតិវិធីយុត្តិធម៌ព្រហ្មទណ្ឌនិងសេវាគាំទ្រនានា ចាប់ពីមន្ត្រីអនុវត្តច្បាប់ បុគ្គលិកពេទ្យបុគ្គលិកសង្គម និងតួអង្គច្បាប់និងយុត្តិធម៌។ កង្វះបុគ្គលិកស្រីនៅក្នុងមុខតំណែងទាំងនេះក៏ជាបញ្ហាមួយដែលតែងកើតមានផងដែរ។

ឧទាហរណ៍នៃមជ្ឈមណ្ឌលតស៊ូមតិសម្រាប់កុមារ ដែលបានបង្កើតឡើងនៅសៀមរាបបន្តបង្ហាញពីបញ្ហាប្រឈមនិងគម្លាតព្រមទាំងភាពខ្វះចន្លោះផ្សេងៗ ដែលអាចរំខានដល់កិច្ចខិតខំប្រឹងប្រែងក្នុងការបង្កើតមជ្ឈមណ្ឌលច្រកចេញចូលតែមួយនៅក្នុងប្រទេសកម្ពុជា ជាពិសេសប្រសិនបើមជ្ឈមណ្ឌលច្រកចេញចូលតែមួយត្រូវបានផ្តោតជាពិសេសទៅលើតម្រូវការរបស់កុមារ។ មជ្ឈមណ្ឌលច្រកចេញចូលតែមួយ ដែលដឹកនាំដោយរដ្ឋាភិបាលនៅកម្ពុជាទំនងជាឈានទៅរកការសហការល្អប្រសើរពីសំណាក់អ្នកពាក់ព័ន្ធជាងមជ្ឈមណ្ឌលច្រកចេញចូលតែមួយដែលដឹកនាំដោយអង្គការមិនមែនរដ្ឋាភិបាល ប៉ុន្តែដើម្បីទទួលបានជោគជ័យ យន្តការសម្របសម្រួលចាំបាច់ត្រូវពង្រឹង ដោយមានគោលការណ៍ណែនាំច្បាស់លាស់សម្រាប់ភាគីពាក់ព័ន្ធនីមួយៗដែលចូលរួម។

មជ្ឈមណ្ឌលច្រកចេញចូលតែមួយនៅតាមមន្ទីរពេទ្យអាចជាជម្រើសដែលអំណោយផលជាង ដោយសារតែការតម្រូវឲ្យកុមារដែលរងផលប៉ះពាល់ពីការរំលោភបំពានផ្លូវភេទ និងកេងប្រវ័ញ្ចធ្វើការពិនិត្យកោសល្យវិច្ច័យនៅក្នុងមន្ទីរពេទ្យបង្អែកដែលបានកំណត់ ការធ្វើបែបនោះនឹងកាត់បន្ថយការចំណាយក្នុងការបង្កើតកន្លែងដាច់ដោយឡែកសម្រាប់គោលបំណងនេះ។ ទោះយ៉ាងណា មន្ទីរពេទ្យបង្អែកបច្ចុប្បន្នខ្វះខាតកន្លែងទំនេរនិងឧបករណ៍វេជ្ជសាស្ត្រសមស្រប ខ្វះបុគ្គលិក និងទទួលបានការបណ្តុះបណ្តាលតិចតួច ហើយប្រជាជនដែលរស់នៅតំបន់ជនបទមិនងាយទទួលបានសេវានោះ។

ទោះបីមានឧបសគ្គដូចបានលើកឡើងខាងលើក៏ដោយ ការវិនិយោគជាយុទ្ធសាស្ត្រឆ្ពោះទៅរកភាពប្រសើរឡើងដែលគួរត្រូវធ្វើឡើង ដើម្បីធានាឲ្យបានថាសមត្ថភាពស្ថាប័នត្រូវបានពង្រឹងតាមរបៀបមួយដែលនឹងអនុញ្ញាតឱ្យមានការបង្កើតមជ្ឈមណ្ឌលច្រកចេញចូលតែមួយនាពេលអនាគត។ ការប្តេជ្ញាចិត្តចំពោះដំណោះស្រាយដែលផ្តោតលើជនរងគ្រោះត្រូវតែបង្ហាញនៅក្នុងនីតិវិធី និងគោលការណ៍ណែនាំជាតិ។ កំណែទម្រង់គួរតែត្រូវបានធ្វើឡើង ដើម្បីធានាថាការថតសំឡេងក្នុងពេលសម្ភាសន៍អាចត្រូវបានទទួលស្គាល់ជាភស្តុតាង និងធានាថាការសម្ភាសន៍ផ្តល់អាទិភាពដល់ការគោរពសិទ្ធិកុមារជាជាងផ្តោតលើការទទួលបានភស្តុតាង។ ការអនុវត្តបែបកុមារមេត្រីគួរតែក្លាយជាបទដ្ឋានមួយ និងគួរត្រូវបានពង្រឹងនៅក្នុងគោលការណ៍ណែនាំ និងពិធីសារច្បាស់លាស់បន្ថែមលើការបណ្តុះបណ្តាលជាប់លាប់ដល់បុគ្គលិកជំនាញដែលពាក់ព័ន្ធនឹងនីតិវិធីយុត្តិធម៌ព្រហ្មទណ្ឌសម្រាប់កុមារ។ បើគ្មានការផ្តល់អាទិភាពលើឧត្តមប្រយោជន៍របស់កុមារ និងការកែទម្រង់ដើម្បីធានាឱ្យបានការគោរព និងគិតគូរពីឧត្តមប្រយោជន៍នោះទេ អ្នកប្រតិបត្តិក្នុងនីតិវិធីយុត្តិធម៌ នឹងបន្តអនុវត្តតាមវិធីសាស្ត្រដែលផ្តោតលើ ប្រតិបត្តិការ ទោះបីជាក្រុមពហុភាគីត្រូវបានបង្កើតឡើងក៏ដោយ។

# សេចក្តីបញ្ចប់ និងអនុសាសន៍



របកគំហើញនៃការស្រាវជ្រាវនេះបានបង្ហាញថាគម្លាត និងចន្លោះខ្វះខាតនៃការឆ្លើយតបចំពោះកុមារមានទំហំធំ ហើយទាមទារឱ្យមានចំណាត់ការជាបន្ទាន់ឆ្ពោះទៅរកដំណោះស្រាយដែលផ្តល់អាទិភាពដល់ឧត្តមប្រយោជន៍របស់កុមារ ក្នុងនីតិវិធីយុត្តិធម៌ព្រហ្មទណ្ឌទាំងមូល។ ទោះបីជាមជ្ឈមណ្ឌលច្រកចេញចូលតែមួយមាន

សក្តានុពលក្នុងការដោះស្រាយសេចក្តីត្រូវការមួយចំនួនរបស់កុមារក្នុងដំណើរការយុត្តិធម៌ព្រហ្មទណ្ឌក៏ដោយ ក៏សមត្ថភាពបច្ចុប្បន្នរបស់ស្ថាប័ន ក្នុងការគាំទ្រដល់មជ្ឈមណ្ឌលច្រកចេញចូលតែមួយនៅក្នុងប្រទេសកម្ពុជានៅមានកម្រិតនៅឡើយ ដោយហានិភ័យអាចមានទៅលើប្រសិទ្ធភាពនៃការអនុវត្ត និងសមត្ថភាពក្នុងការទទួលទ្ធផលខ្ពស់។ ដើម្បីឱ្យមជ្ឈមណ្ឌលច្រកចេញចូលតែមួយទទួលបានជោគជ័យ ការបំពេញនូវចន្លោះខ្វះខាតទាក់ទងនឹងសមត្ថភាពស្ថាប័ន និងការពង្រឹងប្រព័ន្ធការពារកុមារជាមុនគឺមានភាពចាំបាច់បំផុត។ នៅពេលដែលសមត្ថភាពស្ថាប័នត្រូវបានពង្រឹង វាក៏នឹងក្លាយជាមូលដ្ឋានគ្រឹះប្រសើរជាងមុនក្នុងការបង្កើតមជ្ឈមណ្ឌលច្រកចេញចូលតែមួយ និងធានាថាមជ្ឈមណ្ឌលច្រកចេញចូលតែមួយមានផលជះធំធេង ។

# អនុសាសន៍សម្រាប់សកម្មភាព៖

## ១ ការកសាងសមត្ថភាព និងការបែងចែកធនធាន

ការវិនិយោគគួរតែត្រូវបានធ្វើឡើង ក្នុងគោលបំណងបង្កើនចំនួនពលរដ្ឋដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ទៅចុះឈ្មោះចូលរៀនជំនាញផ្សេងៗគ្នា ដូចជាបុគ្គលិកសង្គម គ្រូពេទ្យព្យាបាល មេធាវី ចៅក្រម វេជ្ជបណ្ឌិត និងមន្ត្រីនគរបាល ដែលមានជំនាញលើកិច្ចការពារកុមារ។ ការលើកទឹកចិត្តគួរតែត្រូវបានផ្តល់ជាពិសេសដល់អ្នកជំនាញស្ត្រីនៅក្នុងវិស័យទាំងនេះ។ ការវិនិយោគអាចរាប់បញ្ចូលទាំងការបែងចែកធនធានលើការអប់រំរបស់ពួកគេ រួមទាំងការផ្តល់អាហារូបករណ៍ និងការបន្ថែមអត្ថប្រយោជន៍រដ្ឋ ដែលត្រូវផ្តល់សម្រាប់អ្នកដែលជ្រើសរើសផ្តោតលើវិជ្ជាជីវៈទាំងនេះ។

ការបណ្តុះបណ្តាលឯកទេស និងពហុជំនាញ ដែលផ្តោតលើការឆ្លើយតបដ៏សមស្របចំពោះជនរងគ្រោះដោយអំពើរំលោភបំពាននិងកេងប្រវ័ញ្ចផ្លូវភេទ នីតិវិធីបែបកុមារមេត្រីគួរតែជាប្រធានបទនៃការបណ្តុះបណ្តាលយូរៗម្តង និងទៀងទាត់សម្រាប់អ្នកជំនាញធ្វើការជាមួយកុមារក្នុងដំណើរការនីតិវិធីយុត្តិធម៌ព្រហ្មទណ្ឌ។ ទាំងនេះរួមបញ្ចូលតួនាទីរបស់អ្នកគ្រប់គ្រង និងមន្ត្រីប្រតិបត្តិជាដើម ។ ការបណ្តុះបណ្តាលទាំងនេះគួរតែត្រូវបានធ្វើឡើងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិដោយមានការចូលរួមពីអ្នកជំនាញនៅថ្នាក់ឃុំ ស្រុក និងខេត្តផងដែរ។ វគ្គបណ្តុះបណ្តាលគួររួមបញ្ចូលតម្រូវការជាក់ស្តែងតាមភេទ និងយេនឌ័រ ដើម្បីគូសបញ្ជាក់ភាពស្រដៀងគ្នា និងភាពខុសគ្នាពេលឆ្លើយតបចំពោះតម្រូវការទាំងរបស់កុមារា និងកុមារី ដោយរួមបញ្ចូលទាំងក្រុមកុមារដែលមានពិការភាពផងដែរ។ ការកសាង និងតាក់តែងមេរៀនសម្រាប់ក្រុមពហុភាគី ត្រូវធានានូវប្រធានបទពាក់ព័ន្ធស្តីពីនីតិវិធីសមស្របពាក់ព័ន្ធនឹងកិច្ចសហប្រតិបត្តិការ និងកិច្ចសម្របសម្រួលអាចសម្រេចបានក្នុងពេលវេលាកំណត់ជាក់លាក់។

ធនធានហិរញ្ញវត្ថុបន្ថែមគួរតែត្រូវបែងចែកសម្រាប់ថវិកាជាតិ ដោយផ្តោតលើការលើកកម្ពស់សិទ្ធិកុមារក្នុងប្រព័ន្ធយុត្តិធម៌ និងដើម្បីធានាថាកុមាររងគ្រោះដោយអំពើហិង្សាទទួលបានការគាំទ្រ និងការព្យាបាល។ ការតស៊ូមតិគួរត្រូវបានពង្រឹងក្នុងចំណោមភាគីពាក់ព័ន្ធមកពីស្ថាប័នក្រសួង និងរាជរដ្ឋាភិបាល។ ក្រៅពីអាទិភាពទាំងនេះដែលមានសារៈសំខាន់សម្រាប់ជាប្រយោជន៍ដល់កុមារ វាសំខាន់ដែលត្រូវចងចាំថាអំពើហិង្សាលើកុមារជាបន្ទុកហិរញ្ញវត្ថុយ៉ាងធ្ងន់ធ្ងរដល់ប្រទេស ហើយរាល់ការវិនិយោគហិរញ្ញវត្ថុលើកិច្ចការពារកុមារនឹងជួយសម្រាលបន្ទុកនេះក្នុងរយៈពេលវែង។

ការពិនិត្យ និងកែសម្រួលប្រាក់ឈ្នួលអប្បបរមារបស់ភាគីពាក់ព័ន្ធរបស់រាជរដ្ឋាភិបាល ជាពិសេសរាប់ក្រុមដែលធ្វើការពាក់ព័ន្ធនឹងកុមាររងគ្រោះដោយអំពើហិង្សា គួរតែត្រូវបានធ្វើឡើងយូរៗម្តងដើម្បីធានាថាពួកគេអាចសម្របទៅនឹងការប្រែប្រួលនៃថ្លៃទ្រទ្រង់ជីវភាពគោល និងមិនធ្វើឱ្យប៉ះពាល់ដល់គុណភាពសេវាដែលត្រូវផ្តល់ដោយបុគ្គលិក។ ភាគីពាក់ព័ន្ធដូចជាមន្ត្រីអនុវត្តច្បាប់គួរតែទទួលបានថវិកាសមស្របដែលត្រូវផ្តល់ជាពិសេសដើម្បីទូទាត់លើចំណាយប្រតិបត្តិការមូលដ្ឋានដែលរ៉ាប់រងលើចំណាយដូចជាចំណាយលើការធ្វើដំណើរ សម្ភារនៅតាមនាយកដ្ឋានជាដើម ដើម្បីបង្ការស្ថានភាពដែលពួកគេបង្ខំឱ្យទូទាត់ប្រាក់សម្រាប់ការចំណាយទាំងនេះដោយប្រើប្រាក់ខែរបស់ពួកគេផ្ទាល់។

# ២ ពង្រឹងកិច្ចសម្របសម្រួល និង ការធ្វើឱ្យប្រសើរលើការបញ្ជូនបន្ត

យន្តការសម្របសម្រួលរវាងទីភ្នាក់ងារនានាចាំបាច់ត្រូវធ្វើឱ្យប្រសើរឡើង។ ទោះបីជាមជ្ឈមណ្ឌលច្រកចេញចូលតែមួយមិនទាន់ស្ថិតក្នុងការពិចារណាក៏ដោយ យោងតាមទីភ្នាក់ងារនីមួយៗដែលពាក់ព័ន្ធនឹងនីតិវិធីយុត្តិធម៌ព្រហ្មទណ្ឌគួរតែមានការតែងតាំងបុគ្គលិក ដែលត្រូវបានចាត់តាំងជាពិសេសសម្រាប់រឿងក្តីនានាដែលពាក់ព័ន្ធនឹងកុមារដែលរងគ្រោះដោយអំពើហិង្សាជាមួយនឹងលក្ខខណ្ឌយោងនិងគោលការណ៍ច្បាស់លាស់ទាក់ទងនឹងតួនាទី និងទំនួលខុសត្រូវរបស់ពួកគេ។ នេះក៏គួរតែរួមបញ្ចូលទាំងនីតិវិធីជាក់លាក់ ការសម្របសម្រួលទាន់ពេលវេលាលើការផ្ទេរ និងបញ្ជូនព័ត៌មាន និងសេវាគាំទ្ររវាងទីភ្នាក់ងារផ្សេងៗគ្នា រួមជនបង្គោលសំរាប់ទំនាក់ទំនងដែលត្រូវបានគេស្គាល់យ៉ាងច្បាស់ក្នុងចំណោមទីភ្នាក់ងារ។ ការជូនដំណឹងពិសេសទាក់ទងនឹងការសម្របសម្រួលនៃលទ្ធផលពិនិត្យកោសល្យវិច្ច័យ វេជ្ជសាស្ត្រគួរតែត្រូវបានផ្តល់ទៅកាន់តួអង្គច្បាប់ដើម្បីធានាឱ្យបាននូវប្រសិទ្ធភាព។

ប្រព័ន្ធបញ្ជូនបន្តគួរតែត្រូវបានពង្រឹងដើម្បីធានាថាកុមារទទួលបានការយកចិត្តទុកដាក់ខាងផ្នែកវេជ្ជសាស្ត្រ ចិត្តសាស្ត្រសង្គម និងផ្លូវច្បាប់ទាន់ពេលវេលា។ ការវាយតំលៃអំពីតម្រូវការគួរតែត្រូវបានធ្វើឡើងទូទាំងប្រទេសដើម្បីកំណត់ភាពខ្វះចន្លោះពាក់ព័ន្ធនឹងសេវាកម្មដែលមានស្រាប់ រួមបញ្ចូលទាំងការកំណត់ភាគី ឬសេវាសំរាប់ការបញ្ជូនកុមារពីកំរិតសហគមន៍ដល់កំរិតជាតិ ។ គោលនយោបាយ និងគោលការណ៍ណែនាំគួរតែត្រូវបានរៀបចំឡើងដើម្បីបញ្ជាក់អំពីពេលវេលា និងលក្ខខណ្ឌនៃករណី ឬដែលកុមារគួរត្រូវបញ្ជូនទៅសេវាគាំទ្រណាក្នុងនីតិវិធីទាំងមូល។

ក្រុមការងារបច្ចេកទេសថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិដែលផ្តោតតែលើការពង្រឹងយន្តការការពារកុមារ និងការឆ្លើយតបចំពោះកុមាររងគ្រោះដោយអំពើហិង្សាគួរត្រូវបានបង្កើត។ ក្រុមការងារបច្ចេកទេសគួរតែរួមមានបុគ្គលិកមកពីវិស័យពាក់ព័ន្ធនីមួយៗ ដើម្បីធ្វើឱ្យមានភាពប្រសើរឡើងនូវការសម្របសម្រួលព័ត៌មានរវាងវិស័យទាំងឡាយ និងការផ្តល់សេវាកម្មនានា។

ដោយគិតគូរថាមជ្ឈមណ្ឌលចេញចូលតែមួយជាទិសដៅវែងឆ្ងាយ ក្រុមការងារបច្ចេកទេសគួរត្រូវបានបង្កើតឡើង ឬដាក់បញ្ចូលការគិតគូរអំពីការអភិវឌ្ឍផែនការសកម្មភាពជាក់លាក់សំរាប់ការបង្កើតនេះ ផ្តោតការគិតគូរជាចម្បងដល់ការឆ្លើយតបចំពោះតម្រូវការកុមារ។ ជាអនុសាសន៍ ក្រុមការងារបច្ចេកទេស នឹងត្រូវបញ្ចូលភាគីពាក់ព័ន្ធសំខាន់ៗមកពីស្ថាប័នអង្គការមិនមែនរដ្ឋាភិបាល និងស្ថាប័នរាជរដ្ឋាភិបាល ម្ចាស់ជំនួន និងដៃគូជាយុទ្ធសាស្ត្រដើម្បីជាជំនួយក្នុងការធ្វើផែនការ និងការផ្ទេរធនធានតាមតម្រូវការចាំបាច់។ វគ្គបណ្តុះបណ្តាល និងការកសាងសមត្ថភាពដោយអ្នកជំនាញអន្តរជាតិ ដែលមានបទពិសោធន៍ក្នុងការធ្វើផែនការ ការបង្កើត និងការអនុវត្តមជ្ឈមណ្ឌលចេញចូលតែមួយគួរតែរៀបចំ និងផ្តល់ជូនដល់សមាជិកនៃក្រុមការងារបច្ចេកទេស។

# ៣ ពង្រឹងសិទ្ធិក្នុងការទទួលបានយុត្តិធម៌ និងនីតិវិធីកុមារមេត្រី

ការសម្ភាសន៍កុមារក្នុងដំណើរការនីតិវិធីយុត្តិធម៌ព្រហ្មទណ្ឌទាំងមូលគួរតែត្រូវបានធ្វើឡើងដោយបុគ្គលិកដែលបានទទួលការបណ្តុះបណ្តាលបច្ចេកទេសសម្ភាសន៍បែបកុមារមេត្រី និងបុគ្គលិកទទួលស្គាល់ថាជាអ្នកជំនាញ និងមានចំណេះដឹងទាក់ទងនឹងនីតិវិធីបែបកុមារមេត្រីប៉ុណ្ណោះ។ សិទ្ធិ និងឧត្តមប្រយោជន៍កុមារគួរត្រូវបានផ្តល់អាទិភាពពេញលេញក្នុងដំណើរការទាំងមូល។ ការសំខាន់គួរផ្តោតលើការធានាឱ្យបាននូវការគាំទ្រសមស្រប និងពេញលេញចំពោះក្រុមគោលដៅដែលមានពិការភាព ហើយក្រុមនេះគួរត្រូវបានសម្ភាសដោយអ្នកជំនាញផ្នែកនេះប៉ុណ្ណោះព្រោះវាជាការធានានូវការទទួលបានលក្ខខណ្ឌដែលអាចបំពេញតម្រូវការពិសេសរបស់ពួកគេ។

គោលការណ៍ណែនាំច្បាស់លាស់អំពីទីតាំងនៃការសម្ភាសន៍គួរតែត្រូវបានកំណត់សំរាប់រាល់ការសម្ភាសន៍ជៀសវាងការជ្រើសរើសខុសៗគ្នា ហើយទីតាំងនោះគប្បីគិតពិចារណាឱ្យបានខ្ពស់បំផុតអំពីបរិយាការសមស្របសំរាប់កុមារ និងធានាបាននូវឯកជនភាព និងការសម្ងាត់ ដែលអាចជាផ្នែកមួយនៃការប្រមូលភស្តុតាងដែលរឹងមាំ។

គួរជៀសវាង កោះហៅកុមារឱ្យផ្តល់បទសម្ភាសន៍ម្តងហើយម្តងទៀតទោះក្នុងតម្លៃណាក៏ដោយ លើកលែងតែចាំបាច់ប៉ុណ្ណោះ។ ដើម្បីជៀសវាងបញ្ហានេះ វិធីសាស្ត្រផ្សេងទៀតគួរតែត្រូវបានប្រើ ដូចជាការ សម្ភាសន៍ដំបូងត្រូវធ្វើឡើងដោយអ្នកជំនាញដែលត្រូវបានបណ្តុះបណ្តាល ក៏ដូចជាការសម្ភាសន៍គួរត្រូវបានថតទុកដោយប្រព័ន្ធឌីជីថល ហើយការថតចម្លងបទសម្ភាសន៍ជាលាយលក្ខណ៍អក្សរយ៉ាងលម្អិតក៏ត្រូវបានធ្វើឡើងផងដែរ។ ខ្សែអាត់សំឡេង និងកំណត់ត្រាចម្លងចេញជាលាយលក្ខណ៍អក្សរគួរតែត្រូវបានប្រើនៅក្នុងជំហានបន្ទាប់នៃនីតិវិធីយុត្តិធម៌ព្រហ្មទណ្ឌ ដោយគិតគូរលើការរក្សាការសម្ងាត់របស់កុមារទាក់ទងនឹងព័ត៌មានដែលផ្ទេរពីភាគីពាក់ព័ន្ធមួយទៅភាគីមួយទៀត ។

ខ្សែអាត់សំឡេងនៃការសម្ភាសន៍គួរតែត្រូវបានចាត់ទុកថាជាភស្តុតាងផ្លូវច្បាប់នៅក្នុងតុលាការ និងត្រូវបានប្រើក្នុងករណីដែលការកោះហៅកុមារឱ្យផ្តល់សក្ខីកម្មមិនមែនជាផលប្រយោជន៍ដ៏ល្អបំផុតសំរាប់ពួកគេ។ កិច្ចខិតខំខាងតស៊ូមតិដោយភាគីពាក់ព័ន្ធគួរត្រូវធ្វើឡើងដើម្បីបញ្ជាក់អំពីផលប្រយោជន៍នៃការប្រើប្រាស់ការអាត់សំឡេងសំរាប់ជាភស្តុតាងសំដៅបំរើផលប្រយោជន៍ដល់កុមារ និងដល់ការផ្តន្ទាទោសជនល្មើសផងដែរ។

គប្បីបន្តការខិតខំអនុវត្តប្រកាសស្តីអំពីការប្រើប្រាស់បន្ទប់តភ្ជាប់បណ្តាញទូរទស្សន៍នៅតុលាការ។ បន្ទប់តបណ្តាញទូរទស្សន៍គួរត្រូវបានប្រើជាទូទៅគ្រប់ករណីពាក់ព័ន្ធនឹងកុមារ ហើយកុមារមិនត្រូវផ្តល់សក្ខីកម្មនៅចំពោះមុខជនជាប់ចោទនៅតុលាការនោះទេ។

វិសោធនកម្មច្បាប់គួរតែត្រូវបានធ្វើឡើង ដើម្បីធានាថាការតំណាងស្របច្បាប់នៅក្នុងតុលាការត្រូវបានផ្តល់អាទិភាពសម្រាប់កុមាររងគ្រោះ និងសាក្សី ដោយមិនត្រឹមតែសម្រាប់កុមារទំនាស់នឹងច្បាប់ប៉ុណ្ណោះនោះទេ ហើយជំនួយផ្នែកច្បាប់គួរតែត្រូវបានផ្តល់ដល់អ្នកដែលត្រូវការទាំងអស់។ លក្ខណៈវិនិច្ឆ័យក្នុងការផ្តល់ជំនួយផ្នែកច្បាប់សម្រាប់កុមារគួរពិចារណាលើសូចនាករកាន់តែទូលាយជាងមុនទាក់ទងនឹងតម្រូវការ ជាជាងពិចារណាលើថាតើពួកគេមានប័ណ្ណក្រីក្រឬអត់ដោយអនុវត្តតាមការវាយតម្លៃហិរញ្ញវត្ថុមួយរបស់កុមារ និងគ្រួសាររបស់ពួកគេដើម្បីកំណត់បញ្ហាហិរញ្ញវត្ថុរបស់ពួកគេ។

តុលាការកុមារគួរត្រូវបង្កើតឡើងដើម្បីធានានូវការទទួលបានយុត្តិធម៌បែបកុមារមេត្រីនៅក្នុងនីតិវិធីតុលាការ។ បើទោះបីជាធនធានមានកំរិត ការពិចារណាគប្បីធ្វើឡើងចំពោះថ្ងៃជាក់លាក់ដែលតុលាការអាចដោះស្រាយរឿងក្តីដែលពាក់ព័ន្ធនឹងកុមារ។ ក្នុងថ្ងៃដែលបានកំណត់នេះ មានតែកុមារ និងគ្រួសារទេ ដែលត្រូវតុលាការកោះហៅឱ្យចូលរួមឆ្លើយបំភ្លឺ។

# ៤ ធ្វើឲ្យប្រសើរឡើងនូវសិទ្ធិទទួលបានការថែទាំវេជ្ជសាស្ត្រ និងនីតិវិធី

កុមារគួរតែអាចធ្វើការពិនិត្យកោសល្យវិច្ច័យនៅតាមទីតាំងវេជ្ជសាស្ត្រណាមួយ ដែលបំពេញតម្រូវការរបស់គេបានល្អបំផុត រួមជាមួយនឹងការធ្វើវិសោធនកម្មច្បាប់ដើម្បីធានាថាភស្តុតាងដែលបានមកពីការពិនិត្យនឹងត្រូវបានចាត់ទុកថាជាភស្តុតាងស្របច្បាប់នៅក្នុងតុលាការ ទោះបីវាមិនបានធ្វើនៅក្នុងមន្ទីរពេទ្យបង្អែករដ្ឋក៏ដោយ តែការពិនិត្យកោសល្យវិច្ច័យនៅតែធ្វើឡើងនៅក្នុងមន្ទីរពេទ្យដែលមានកេរ្តិ៍ឈ្មោះ។

ឧបករណ៍វេជ្ជសាស្ត្រចាំបាច់សម្រាប់ធ្វើការពិនិត្យវេជ្ជសាស្ត្រកោសល្យវិច្ច័យសមស្រប និងការប្រមូលភស្តុតាងនៃការរំលោភបំពានគួរតែមាននៅតាមមន្ទីរពេទ្យបង្អែកទូទាំងប្រទេស។ នេះរួមមានទាំងឧបករណ៍ និងការតុបតែងបែបកុមារមេត្រី ឧបករណ៍ដើម្បីរក្សាទុកភស្តុតាង និងការបង្កើតបន្ទប់ពិសោធន៍សំរាប់ការវិភាគភស្តុតាងកោសល្យវិច្ច័យដោយអ្នកជំនាញទទួលបានការបណ្តុះបណ្តាលលើផ្នែកទាញយក និងវិភាគលទ្ធផល។

ការប្រើប្រាស់ទូរស័ព្ទចល័តផ្ទាល់ខ្លួនសម្រាប់ថតរូបក្នុងពេលពិនិត្យគួរតែត្រូវបានហាមឃាត់ដាច់ខាត ហើយគោលការណ៍ណែនាំច្បាស់លាស់គួរតែត្រូវបានផ្តល់ជូនសម្រាប់គ្រប់គ្រងទិន្នន័យ និងព័ត៌មានសម្ងាត់របស់អតិថិជនជាពិសេសជនរងគ្រោះជាកុមារ។

គ្រូពេទ្យដែលធ្វើការពិនិត្យវេជ្ជសាស្ត្រគួរតែត្រូវបានបណ្តុះបណ្តាលឱ្យបានពេញលេញក្នុងការកំណត់សញ្ញាណនៃការរំលោភបំពានលើកុមារដែលលើសពីការពិនិត្យតែលើសន្ធះព្រហ្មចារី។ ការកំណត់សញ្ញាណនៃការរំលោភបំពានលើក្មេងប្រុសគួរតែត្រូវបានបញ្ចូលក្នុងវគ្គបណ្តុះបណ្តាលទាំងនេះ។

បុគ្គលិកដែលទទួលការចាត់តាំង និងទទួលបានវគ្គបណ្តុះបណ្តាលគួរធ្វើការសម្ភាសន៍កុមារអំពីការរំលោភបំពាន ពេលដែលបុគ្គលិកផ្សេងទៀតដូចជាវេជ្ជបណ្ឌិតដែលមិនពាក់ព័ន្ធនឹងករណី ឬគិលានុប្បដ្ឋាយិការគួរកំណត់ប្រភេទសំណួរឱ្យត្រឹមតែដែនសមត្ថកិច្ចរបស់ខ្លួនដើម្បីជៀសវាងពីការឱ្យកុមារនិយាយពីរឿងរំលោភបំពានដដែលៗ។

វគ្គបណ្តុះបណ្តាលស្តីពីការកំណត់សញ្ញាណរងគ្រោះគួរត្រូវបានរៀបចំបន្ថែម ដើម្បីជម្រុញការកំណត់ជនរងគ្រោះឱ្យបានទាន់ពេលវេលា។

ពង្រឹងការផ្តួចផ្តើមលើការលើកកម្ពស់ការយល់ដឹងនៅក្នុងសហគមន៍អំពីសារៈសំខាន់នៃការពិនិត្យកោសល្យវិច្ច័យវេជ្ជសាស្ត្រក្នុងរយៈពេល ៤៨ ម៉ោងក្រោយពីការរំលោភបំពានផ្លូវភេទកើតឡើង ជាពិសេសការរំលោភសេពសន្ថវៈដើម្បីទទួលបានភស្តុតាង និងការព្យាបាលបន្ទាន់ និងចាំបាច់។

# ៥ បង្កើនសិទ្ធិទទួលបានការគាំទ្រផ្នែកចិត្តសាស្រ្តសង្គម និងការគាំពារ

នៅពេលដែលមានករណីរំលោភបំពានលើកុមារកើតឡើង ការវាយតម្លៃបឋមនិងបន្ទាន់ដោយអ្នកជំនាញមកពីមន្ទីរសង្គមកិច្ច ឬមន្ទីរកិច្ចការនារីត្រូវធ្វើឱ្យបានឆាប់ដើម្បីកំណត់តម្រូវការខាងចិត្តសង្គម និងសុខភាពរបស់កុមារ និងធានាថាពួកគេត្រូវបានបញ្ជូនទៅរកការថែទាំត្រឹមត្រូវទាន់ពេលវេលា។ នេះអាចត្រូវបានផ្តល់ជា "កញ្ចប់សេវាកម្ម" ដំបូងដែលរួមមានការប្រឹក្សាផ្នែកចិត្តសាស្ត្រសង្គមនិងការផ្តល់ព័ត៌មានអំពីសិទ្ធិរបស់ពួកគេ អំពីសេវាបញ្ជូនសមស្រប និងជម្រើសសំរាប់ជំហានបន្ទាប់ និងការគាំពារបន្ថែម។

បុគ្គលិកសង្គមដែលអមកុមារនៅគ្រប់ដំណាក់កាលទាំងមូលនៃនីតិវិធីយុត្តិធម៌ព្រហ្មទណ្ឌ គួរតែខិតខំប្រឹងប្រែង ដើម្បីធានាថាសិទ្ធិរបស់កុមារត្រូវបានគោរពក្នុងដំណើរការទាំងមូល ហើយកុមារបានដឹងច្បាស់ពីសិទ្ធិរបស់ពួកគេ ។

ការវិនិយោគគួរតែត្រូវបានធ្វើឡើងលើការបង្កើនសិទ្ធិទទួលបានការថែទាំសុខភាពផ្លូវចិត្ត និងការព្យាបាល។ នេះរួមមានទីតាំងបន្ថែមដែលអាចប្រើប្រាស់បានទាំងនៅទីក្រុង និងជនបទដែលមានអ្នកជំនាញដែលទទួលបានការបណ្តុះបណ្តាល និងការបង្កើនការយល់ដឹងអំពីសារៈសំខាន់នៃការទទួលជំនួយ និងការព្យាបាលបន្ទាប់ពីការរំលោភបំពាន ។

គួរបង្កើតកន្លែងស្នាក់នៅបណ្តោះអាសន្ន និងកន្លែងស្នាក់នៅសំចតបន្ថែមទៀតដើម្បីឱ្យកុមាររងគ្រោះបន្ទាប់ពីការរំលោភបំពានស្នាក់នៅ រួមទាំងកន្លែងស្នាក់នៅសម្រាប់ក្មេងប្រុសផងដែរ។ ជម្រើសនៃការថែទាំក្នុងសហគមន៍ ឬតាមគ្រួសារគួរត្រូវបានផ្តល់អាទិភាពគ្រប់ពេលដែលអាចធ្វើទៅបាន។ សហគមន៍ ឬឪពុកម្តាយ ឬអ្នកថែទាំគួរទទួលបានវគ្គបណ្តុះបណ្តាលសមស្របដើម្បីធានាថាពួកគេអាចផ្តល់ការគាំទ្រ និងការមើលថែសមស្របសំរាប់កុមារ។

# ៦ ទិន្នន័យ និង ការតាមដាននីតិវិធី

ការពិនិត្យឡើងវិញនូវនីតិវិធី និងគោលនយោបាយគួរតែត្រូវបានធ្វើឡើងយូរៗម្តងជាមួយនឹងការតាមដានសមស្រប លើការងាររបស់ភាគីពាក់ព័ន្ធផ្សេងៗដែលធ្វើការជាមួយកុមារ ដើម្បីធានាថាការអនុវត្តបែបកុមារមេត្រីត្រូវបានប្រើប្រាស់នៅក្នុងជំហាននីមួយៗនៃដំណើរការ។ អ្នកជំនាញគួរតែទទួលខុសត្រូវចំពោះសកម្មភាពរបស់ពួកគេប្រកបដោយតម្លាភាព ដើម្បីធានាថាឧត្តមប្រយោជន៍របស់កុមារតែងតែត្រូវបានចាត់ទុកថាជាអាទិភាព។

ការពិនិត្យ និងវាយតម្លៃជាទៀងទាត់ជាមួយកុមារ និងគ្រួសារគួរធ្វើឡើងដើម្បីដាក់បញ្ចូលការយល់ឃើញរបស់ពួកគេ និងរៀនសូត្រអំពីបទពិសោធន៍របស់ពួកគេនៅគ្រប់ដំណាក់កាលនីតិវិធី។ ការផ្តោតចំបងគួរទៅលើសំលេងរបស់កុមារត្រូវបានគេស្តាប់និងទទួលយកនៅគ្រប់នីតិវិធី និងការចូលរួមរបស់កុមារអាចមានឥទ្ធិពលលើអ្វីដែលជាការប៉ះពាល់ដល់ពួកគេ។

ការបម្លែងទិន្នន័យតាមប្រព័ន្ធឌីជីថលគួរតែត្រូវបានពិចារណានៅតាមទីតាំងរដ្ឋ និងសាធារណៈ (មន្ទីរពេទ្យ តុលាការ។ ល។) ដើម្បីជម្រុញការប្រើប្រាស់បានរហ័សនូវព័ត៌មានរបស់កូនក្តី និងជម្រុញវិធីដែលមានប្រសិទ្ធិភាពក្នុងការរក្សាទុកទិន្នន័យរបស់កូនក្តី ខណៈពេលចាត់វិធានការដើម្បីធានាថាទិន្នន័យត្រូវបានរក្សាការសម្ងាត់។

ការសិក្សា និងការស្រាវជ្រាវបន្ថែមគួរតែត្រូវបានធ្វើឡើង ដើម្បីស្វែងយល់កាន់តែច្បាស់អំពីវិសាលភាពនៃស្ថានភាពរបស់កុមារដែលឆ្លងកាត់នីតិវិធីយុត្តិធម៌ព្រហ្មទណ្ឌ និងស្វែងយល់យុទ្ធសាស្ត្របំពេញចន្លោះខ្វះខាតក្នុងការឆ្លើយតប រួមទាំងចំពោះកុមារដែលរងការកេងប្រវ័ញ្ចផ្លូវភេទតាមអនឡាញ។ ការសិក្សាគួរផ្តោលើការស្វែងយល់អំពីនីតិវិធីព្រហ្មទណ្ឌសម្រាប់កុមារដែលមានពិការភាព រួចរងគ្រោះដោយអំពើរំលោភបំពាន និងកេងប្រវ័ញ្ចផ្លូវភេទ ដើម្បីធានាថាប្រព័ន្ធឆ្លើយតបត្រូវបានគេសម្របទៅតាមតម្រូវការរបស់ពួកគេ។

# ឧបសម្ព័ន្ធ

| វិស័យរបស់អ្នករាយការណ៍ | កូដបទសម្ភាសន៍ | ទីតាំង | តួអង្គគ្រប់គ្រង |
|---|---|---|---|
| ផ្នែកចិត្តសាស្ត្រសង្គម | S1 | សៀមរាប | អង្គការមិនមែនរដ្ឋាភិបាល |
| | S2 | សៀមរាប | អង្គការមិនមែនរដ្ឋាភិបាល |
| | S3 | សៀមរាប | អង្គការមិនមែនរដ្ឋាភិបាល |
| | S4 | ភ្នំពេញ | អង្គការមិនមែនរដ្ឋាភិបាល |
| | S5 | ភ្នំពេញ | អង្គការមិនមែនរដ្ឋាភិបាល |
| | S6 | ភ្នំពេញ | រដ្ឋាភិបាល |
| | S7 | ភ្នំពេញ | រដ្ឋាភិបាល |
| | S8 | ភ្នំពេញ | រដ្ឋាភិបាល |
| មន្ត្រីអនុវត្តច្បាប់ | P1 | សៀមរាប | រដ្ឋាភិបាល |
| | P2 | សៀមរាប | រដ្ឋាភិបាល |
| | P3 | សៀមរាប | រដ្ឋាភិបាល |
| | P4 | កណ្ដាល | រដ្ឋាភិបាល |
| | P5 | កណ្ដាល | រដ្ឋាភិបាល |
| | P6 | ភ្នំពេញ | រដ្ឋាភិបាល |
| | P7 | ភ្នំពេញ | អង្គការមិនមែនរដ្ឋាភិបាល |
| ផ្នែកវេជ្ជសាស្ត្រ | M1 | សៀមរាប | រដ្ឋាភិបាល |
| | M2 | សៀមរាប | អង្គការមិនមែនរដ្ឋាភិបាល |
| | M3 | ភ្នំពេញ | រដ្ឋាភិបាល |
| | M4 | ភ្នំពេញ | រដ្ឋាភិបាល |
| | M5 | ភ្នំពេញ | រដ្ឋាភិបាល |
| ផ្នែកតុលាការ និងច្បាប់ | L1 | ភ្នំពេញ | អង្គការមិនមែនរដ្ឋាភិបាល |
| | L2 | ភ្នំពេញ | អង្គការមិនមែនរដ្ឋាភិបាល |
| | L3 | ភ្នំពេញ | អង្គការមិនមែនរដ្ឋាភិបាល |
| | L4 | ភ្នំពេញ | រដ្ឋាភិបាល |
| | L5 | ភ្នំពេញ | រដ្ឋាភិបាល |
| | L6 | ភ្នំពេញ | រដ្ឋាភិបាល |
| | L7 | ភ្នំពេញ | រដ្ឋាភិបាល |
| | L8 | ភ្នំពេញ | អង្គការមិនមែនរដ្ឋាភិបាល |



APLE


www.aplecambodia.org

/aplecambodia.org

/aple__cambodia.org

/aplecambodia